# ព្រះពោធិសត្វយាងទៅកាន់ទេវលោកដោយអត្តភាពជាមនុស្ស ៥ ជាតិ



នេះកាលព្រះបាទនេមិរាជយាងទតឋានសួគ៌


ដឹកនាំរៀបរៀងដោយ
ខ្ញុំព្រះករុណា ខ្ញុំបាទ

**កុល ផេង**


**ព.ស. ២៥៦៦**

# ព្រះពោធិសត្វយាងទៅកាន់
# ទេវលោកដោយអត្តភាព
# ជាមនុស្ស ៥ ជាតិ

រៀបរៀងដោយ

*បណ្ឌិត* **គុល ផេង**

សីល សមាធិ បញ្ញា

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**
**ព.ស. ២៥៦៦**

| | |
|---|---|
| *ឈ្មោះសៀវភៅ* | **ព្រះពោធិសត្វយាងទៅកាន់ទេវលោកដោយអត្តភាពជាមនុស្ស ៥ ជាតិ** |
| *រៀបរៀងដោយ* | **បណ្ឌិត គុល ផេង**<br>*ប្រធានពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យ*<br>*បញ្ញាសាស្ត្រកម្ពុជា* |
| *ទីតាំងធ្វើ* | *ពុទ្ធិកបណ្ឌិត្យសភា* |
| *ការផ្សាយ* | *របស់ពុទ្ធិកបណ្ឌិត្យសភា* |
| *រក្សាសិទ្ធិ* | *ពុទ្ធិកបណ្ឌិត្យសភា* |
| *កាលបរិច្ឆេទ* | *ថ្ងៃសុក្រ ១៥ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦*<br>*ថ្ងៃទី ០៦ ខែមករា ឆ្នាំ ២០២៣* |

**សូមថ្វាយព្រះពរ**
**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង**
**ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរព**
**ដ៏ខ្ពង់ខ្ពស់បំផុត**

***បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង***

*ក្នុងនាមទូលព្រះបង្គំជាខ្ញុំផ្ទាល់ ព្រមទាំងសមាជិក សមាជិកា នៃពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា សូមលំឱនកាយក្រាបថ្វាយបង្គំទូលថ្វាយព្រះសព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

*ទូលព្រះបង្គំជាខ្ញុំសូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំជាខ្ញុំបានដឹកនាំរៀបរៀងនូវសៀវភៅ "***ព្រះពោធិសត្វយាងទៅកាន់ទេវលោកដោយអត្តភាពជាមនុស្ស ៥ ជាតិ***" តម្កល់ទុកក្នុងព្រះពុទ្ធសាសនា ។ បពិត្រព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមព្រះករុណាជាអម្ចាស់ អនុមោទនានូវមហាកុសលនេះ ។ ដោយអំណាចគុណបុណ្យព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និងបារមីនៃអតីតៈព្រះមហាក្សត្រ ព្រះ*

មហាក្រត្រៃយានី គ្រប់ព្រះអង្គព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយក្នុងលោក សូមជួយអភិបាលថែរក្សា ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង **ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់មានព្រះរាជសុខភាពល្អ បរិបូណ៌ព្រះកាយពលមាំមួន ព្រះជន្មយឺនយូរ ព្រះបញ្ញាញាណវាងវៃ និងគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ដល់ប្រជានុរាស្ត្រ ដើម្បីទទួលបាននូវសេចក្តីសុខក្សេមក្សាន្តចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។

សេចក្តីគួរពុំគួរ សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,
ថ្ងៃសុក្រ ១៥ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ថ្ងៃទី០៦ ខែមករា ឆ្នាំ ២០២៣

**គុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# សូមថ្វាយព្រះរាជកុសល
# សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ
# ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត
# បពិត្រសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង

*តាងនាមសមាជិក សមាជិកា ពុទ្ធិកបណ្ឌិតសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា ក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយា ព្រមទាំងបុត្រ សូមលំឱនសិរសាដោយត្បូង ទូលព្រះរាជសព្ទសាធុការពរ បវរមហាប្រសើរ និងប្រកបដោយសិរីសួស្តី ជ័យមង្គល វិបុលសុខគ្រប់ប្រការ ថ្វាយ* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពស់ខ្ពស់បំផុត។*

*ទូលព្រះបង្គំ យើងខ្ញុំ សូមថ្វាយព្រះរាជកុសល ដែលទូលព្រះបង្គំ យើងខ្ញុំបានប្រែសម្រួល និងរៀបរៀងនូវសៀវភៅ* "**ព្រះពោធិសត្វយាងទៅកាន់ទេវលោកដោយអត្តភាពជាមនុស្ស ៥ ជាតិ**" *នេះ ដើម្បីតម្កល់ទុកក្នុងព្រះពុទ្ធសាសនា។*

*បពិត្រសម្តេចព្រះមហាក្សត្រី ជាអម្ចាស់ជីវិតតម្កល់លើត្បូង សូមទ្រង់អនុមោទនា នូវមហាកុសល ដោយព្រះរាជហឫទ័យជ្រះថ្លា ដ៏ខ្ពង់ខ្ពស់បំផុត។*

*សូមឧទ្ទិស ដល់បារមីនៃព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គដែលបានត្រាស់ដឹងក្នុងលោកកន្លងមក បារមីនៃព្រះសម្មាសម្ពុទ្ធដែលនឹងត្រាស់ក្នុងអនាគត អានុភាពគុណបុណ្យ ព្រះរតនត្រ័យ*

*ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ និង ព្រមទាំងវត្ថុសក្តិសិទ្ធិទាំងឡាយ ក្នុងបារមីនៃអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីគ្រប់ព្រះអង្គ ព្រមទាំងវត្ថុលោក សូមជួយអភិបាលរក្សា* **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត សូមព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ព្រះជន្មាយុយឺនយូរ ព្រះបញ្ញាញាណវាងវៃ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ នៃប្រជានុរាស្ត្រ ឱ្យទទួលបាននូវសេចក្តីសុខក្សេមក្សាន្ត ចម្រើនរុងរឿង ជានិច្ចនិរន្តរ៍តរៀងទៅ ។*

*សេចក្តីគួរពុំគួរ សូម* **សម្តេចព្រះមហាក្សត្រី** *ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានទោស ដោយព្រះរាជហឫទ័យអនុគ្រោះដ៏ខ្ពង់ខ្ពស់បំផុត ។*

*ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ,*
*ថ្ងៃសុក្រ ១៥ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦*
*ថ្ងៃទី០៦ ខែមករា ឆ្នាំ ២០២៣*

**គុល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
## *សម្តេចអគ្គមហាសេនាបតីតេជោ ជាទីគោរពដ៏ខ្ពង់ខ្ពស់*

*តាងនាមសមាជិក សមាជិកាពុទ្ធិកបណ្ឌិត្យសភានៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា និងក្នុងនាមខ្ញុំបាទផ្ទាល់ និងភរិយាខ្ញុំបាទ សូមគោរពជូនបុណ្យកុសល និងសព្ទសាធុការពរ បវរមហាប្រសើរ សិរីសួស្តី ជយមង្គល វិបុលសុខគ្រប់ប្រការជូនចំពោះ* **សម្តេច** *និង* **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** *ជាទីគោរពដ៏ខ្ពង់ខ្ពស់ ។*

*ខ្ញុំបាទសូមគោរពជូនមហាកុសល ដែលខ្ញុំបានដឹកនាំការរៀបរៀងចងក្រងនូវសៀវភៅ "* **ព្រះពោធិសត្វយាងទៅកាន់ទេវលោកដោយអត្តភាពជាមនុស្ស ៥ ជាតិ** *" តម្កល់ទុកក្នុងព្រះ ពុទ្ធសាសនានេះ ។ សូម* **សម្តេចទាំងពីរ** *មេត្តាទទួលអនុមោទនានូវមហាកុសលនេះ ។ ដោយតេជះគុណានុភាពនៃព្រះរតនត្រ័យ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ វត្ថុសក្តិសិទ្ធិក្នុងលោក ជួយបីបាច់ថែរក្សា និងប្រសិទ្ធិពរជ័យជូន* **សម្តេចទាំងពីរ** *ព្រមទាំង***បុត្រាបុត្រី** *និង***ចៅ** *ៗ ជាទីស្រឡាញ់របស់* **សម្តេច** *សូមមានសុខភាពល្អបរិបូណ៌ ជន្មាយុយឺនយូរ បញ្ញាញាណវាងវៃ*

ដើម្បីដឹកនាំប្រទេសជាតិ ឆ្ពោះទៅរកត្រើយសុខសន្តិភាព និងការអភិវឌ្ឍឲ្យសម្បូរសប្បាយរុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ ។

ខ្ញុំបាទសូមកោតសរសើរដោយសុទ្ធចិត្តនូវវិរិយភាពដ៏អង់អាចរបស់ **សម្តេច** ដែលបានបំពេញនូវបេសកកម្មដ៏លំបាកក្នុងការស្វែងរកសេចក្តីសុខជូនចំពោះប្រជាពលរដ្ឋ និងការអភិវឌ្ឍក្នុងព្រះរាជា-ណាចក្រកម្ពុជាយើង នាំមកនូវភាពចម្រើនរុងរឿង នាសម័យបច្ចុប្បន្ននេះ និងក្នុងអនាគតកាល ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ប្រកបដោយសិរីមង្គល វិបុលសុខ មហាប្រសើរ ព្រមទាំងទទួលបាននូវធម៌ដ៏ប្រសើរទាំង ៥ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

រាជធានីភ្នំពេញ,
ថ្ងៃសុក្រ ១៥ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
ថ្ងៃទី០៦ ខែមករា ឆ្នាំ ២០២៣

**ភួល ផេង**
**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**
**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# បុព្វកថា

កម្រងរឿង នៃព្រះពោធិសត្វ៥ព្រះអង្គដែលមាន នាម

១- ព្រះបាទមន្ធាតុចក្រពត្រាធិរាជ

២- ព្រះបាទសាធិនរាជ

៣- គុត្តិលវីណាវាទកព្រាហ្មណ៍

៤- ព្រះបាទនិមិមហារាជ ( នេមិមហារាជ)

៥- ព្រះបាទធម្មសោណ្ឌកមហារាជ

បានយាងទៅកាន់ទេវលោកដោយអត្តភាពជាមនុស្សនេះមាន សារៈសំខាន់ចំពោះយើងអ្នកគោរពព្រះពុទ្ធសាសនាព្រោះ តេជានុភាពនៃព្រះពោធិសត្វមួយអង្គៗសុទ្ធតែជាអ្នកមានសីលដ៏ បរិសុទ្ធ និងបារមីទាំង ៣០ជាកម្លាំងធ្វើឱ្យទេវតា និងសក្កទេវរាជ ចង់រៀនចង់ដឹងពីមនុស្សលោក ។

ការចងក្រងរឿងទាំង៥នេះ រក្សាអត្ថន័យ និងដំណើររឿងបែបប តាមអត្ថបទដើមទាំងស្រុងមានការសម្រួលសព្ទជាភាសាខ្មែរខ្លះ ដើម្បីងាយស្រួលដល់អ្នកសិក្សាសម័យបច្ចុប្បន្ន ។

ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះ **លោកគ្រូ ធម្មាចារ្យ សទ្ធម្មធរជោតិកៈ ហួយ វ៉ាន់ថន** ក្នុងកិច្ចការស្វែងរកឯកសារជំនួយដើម្បីបានរៀបជាសៀវភៅ១ក្បាលនេះឡើង ។ មិនត្រឹមតែប៉ុណ្ណោះ កិច្ចការបោះពុម្ពផ្សាយសៀវភៅផ្សេងៗទៀតដ៏ច្រើនក៏ជា

ការខិតខំប្រឹងប្រែងមួយចំណែកធំដោយលោកគ្រូ **សទ្ធម្មធរជោតិកៈ ហួយ វ៉ាន់ថន** ។ ម្យ៉ាងទៀតខ្ញុំសូមថ្លែងអំណរគុណ ដ៏ជ្រាលជ្រៅដល់ចៅ **មុនីបញ្ញោ ម៉ម ម៉ានិត** ដែលបានជួយកែសម្រួលអក្ខរាវិរុទ្ធ និងរៀបចំបោះពុម្ពផ្សាយ ។

សូមឧទ្ទិសបុញ្ញកុសលនេះជូនប្រជាពលរដ្ឋក្នុងព្រះរាជាណាចក្រកម្ពុជា និងលើពិភពលោកទាំងមូលគ្រប់ៗរូប សូមបានចំណែកបុណ្យស្មើៗគ្នា សុំកុំឱ្យមានការបៀតបៀនគ្នា សុំឱ្យរស់នៅប្រកបព្រមដោយសុខសន្តិភាព និងទីបំផុតសូមឱ្យបានសម្រេចនូវធម៌ជាន់ខ្ពស់គឺព្រះនិព្វាន។

រាជធានីភ្នំពេញ,

ថ្ងៃសុក្រ ១៥ កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ថ្ងៃទី០៦ ខែមករា ឆ្នាំ ២០២៣

**ភុល ផេង**

**ប្រធានក្រុមប្រឹក្សាភិបាលពុទ្ធិកបណ្ឌិត្យសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

# ព្រះពោធិសត្វយាងទៅកាន់ទេវលោក ដោយអត្តភាពជាមនុស្ស ៥ ជាតិ

**មាតិកា** **ទំព័រ**

**១.ប្រជុំ ២ នៃរឿងព្រះបាទមន្ធាតុ**.............................. ៣

១.១.មន្ធាតុជាតក ....................................................... ៣

១.២.មហាមន្ធាតុវត្ថុ ................................................ ១៨

**២.សាធិនជាតក**....................................................... ៣៩

**៣.គុត្តិលជាតក** ........................................................ ៦០

**៤.ប្រជុំ ៣ នៃរឿងព្រះបាទនេមិរាជ**......................... ៨៦

៤.១.មឃទេវសូត្រ .................................................... ៨៦

៤.២.នេមិរាជជាតក............................................ ១១៥

៤.៣.នេមិរាជចរិយា ........................................... ១៥៦

**៥.ធម្មសោណ្ឌកមហារាជវត្ថុ** ................................ ១៥៧

**ឯកសារយោង** ...................................................... ១៨៧

# ព្រះពោធិសត្វយាងទៅកាន់ទេវលោក ដោយអត្តភាពជាមនុស្ស ៥ ជាតិ

**<u>សួរថា</u>** *ព្រះពោធិសត្វយាងទៅកាន់ទេវលោកអស់វារៈប៉ុន្មានដង ដោយអត្តភាពជាមនុស្ស ?*

**<u>ឆ្លើយថា</u>** *ព្រះពោធិសត្វទៅកាន់ទេវលោកអស់វារៈ ៥ ដង ដោយអត្តភាពជាមនុស្ស គឺ ៖*

**១- មន្ធាតុរាជកាលេ** *ក្នុងកាលព្រះពោធិសត្វនៅជាព្រះបាទមន្ធាតុចក្រពត្រាធិរាជ។*

**២- សាធិនរាជកាលេ** *ក្នុងកាលនៅជាព្រះបាទសាធិនរាជ។*

**៣- គុត្តិលវីណាវាទកកាលេ** *ក្នុងកាលនៅជាគុត្តិលវីណាវាទកព្រាហ្មណ៍។*

**៤- និមិមហារាជកាលេ** *ក្នុងកាលនៅជាព្រះបាទនិមិមហារាជ (នេមិមហារាជ)។*

**៥- ធម្មសោណ្ឌកមហារាជកាលេ** *ក្នុងកាលនៅជាព្រះបាទធម្មសោណ្ឌកមហារាជ។*

*-ព្រះពោធិសត្វនោះ កាលនៅជាព្រះបាទមន្ធាតុ*

ទ្រង់អាស្រ័យនៅក្នុងទេវលោកអស់កាលចំនួនឆ្នាំប្រមាណមិនបាន ក្នុងពេលដែលព្រះអង្គនៅក្នុងទេវលោកនោះ សក្កទេវរាជចុតិអស់ ៣៦ អង្គ។

-កាលព្រះពោធិសត្វនៅជាព្រះបាទសាធិនរាជ ទ្រង់នៅទេវលោកអស់ ៧ ថ្ងៃក្នុងឋានតាវត្តិង្ស ត្រូវជា ៧០០ ឆ្នាំ ដោយការរាប់ឆ្នាំរបស់មនុស្ស។

-កាលព្រះពោធិសត្វនៅជាគុត្តិលវីណាវាទកព្រាហ្មណ៍ និង ព្រះបាទនិមិរាជ ទ្រង់នៅអស់ប្រមាណមួយរំពេច ត្រូវជា ៧ ថ្ងៃ ដោយការរាប់ថ្ងៃរបស់មនុស្សលោក។

-កាលនៅជាព្រះបាទធម្មសោណ្ឌកមហារាជ ទ្រង់នៅអស់កាលប្រមាណមួយរំពេច។

ក្នុងជាតិទាំង៥នេះ គម្ពីរបបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក រាជវគ្គ មឃទេវសូត្រ ពោល៤ជាតិ និងគម្ពីរមធុរសវាហិណីពោលបន្ថែម១ជាតិទៀត។

# ១.ប្រជុំ ២ នៃរឿងព្រះបាទមន្ធាតុ

## ១.១.មន្ធាតុជាតក

(តិកនិបាតជាតក សង្កប្បវគ្គទី១)




**សត្ថា** រីអង្គសម្តេចព្រះបរមសាស្តាចរិយាវង្ស កាលស្តេចទ្រង់សម្រេចសម្រាន្តព្រះឥរិយាបថ កំណត់នៅក្នុងព្រះវិហារជេតពនសុគន្ធកុដីស្រីមហាវិហារ អារព្ភ ទ្រង់ព្រះប្រារព្ធ ឧក្កណ្ឋិតភិក្ខុំ នូវភិក្ខុអ្នកអផ្សុកមួយរូប (ឲ្យជាហេតុ) កថេសិ ទើបទ្រង់សំដែង ឥទំ (ជាតកំ) នូវជាតកនេះ ឥតិ ដោយគាថាថា យាវតា ចន្ទិមសុរិយា ដូច្នេះជាដើមៗ

តិរ ដូចបានឮមកថាមានភិក្ខុ ១ រូបត្រាច់ទៅបិណ្ឌ-បាតក្នុងក្រុងសាវត្ថី បានឃើញស្ត្រីមានកាយប្រដាប់ដោយគ្រឿងអលង្ការ ក៏កើតចិត្តប្រតិព័ទ្ធក្នុងស្ត្រីនោះ ហើយមានសេចក្ដីអផ្សុកប្រាថ្នានឹងសឹកចេញជាយរាវាស។ ភិក្ខុទាំងឡាយដឹងរឿងនោះ ទើបនាំភិក្ខុនោះទៅគាល់សម្ដេចព្រះបរមលោកនាថ ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនេះជាអ្នកមានសេចក្ដីអផ្សុក"។

សម្ដេចព្រះបរមសាស្ដាមានព្រះពុទ្ធតម្រាស់សួរថា "ម្នាលភិក្ខុ បានឮថា អ្នកមានសេចក្ដីអផ្សុកពិតមែនឬ?"

ភិក្ខុនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអផ្សុកពិតមែន"។

ទើបមានព្រះពុទ្ធតម្រាស់ថា "ម្នាលភិក្ខុ បើអ្នកសឹកចេញទៅជាយរាវាស អ្នកនឹងអាចញុំាងសេចក្ដីប្រាថ្នាឲ្យពេញបានដែរឬ? ធម្មតាតណ្ហាគឺសេចក្ដីប្រាថ្នាក្នុងកាម-គុណទាំង ៥ នេះជារបស់ដែលបុគ្គលណាមួយមិនអាចឲ្យពេញបានឡើយ ប្រៀបដូចមហាសមុទ្រដ៏ធំទូលាយមិនងាយនឹងឲ្យពេញដោយវារីដែលហូរមកអំពីមហានទីទាំង

៥, សូម្បីព្រាហ្មណបណ្ឌិតទាំងឡាយ ដែលបានសោយសិរីរាជសម្បត្តិជាបរមចក្រពត្រាធិរាជមានអំណាចផ្សាយទៅក្នុងទ្វីបធំទាំង ៤ មានទ្វីបតូច ២ ពាន់ជាបរិវារ នឹងបានសោយទិព្វស្រីង្គារក្នុងជាន់ចាតុម្មហារាជិកា ទាំងបានសោយទិព្វសម្បត្តិក្នុងតាវត្តិង្សទេវលោក ឋិតនៅក្នុងវិមានសម្តេចសក្កទេវរាជអស់កាលយូរ រហូតសម្តេចមយវាកន្ទង់ទៅដល់ ៣៦ ព្រះអង្គ ក៏នៅតែមិនអាចញុំាងកាមតណ្ហាគឺសេចក្តីប្រាថ្នាក្នុងកាមគុណទាំង ៥ ឲ្យបរិបូណ៌ពេញទីបានដែរ ម្នាលភិក្ខុ អ្នកអាចនឹងធ្វើកាមតណ្ហាឲ្យបរិបូណ៌ពេញទីបានដែរឬ?" កាលមានព្រះពុទ្ធតម្រាស់ដូច្នេះហើយ ទើបទ្រង់នាំយករឿងក្នុងអតីតកាលមកត្រាស់ទេសនាដូចតទៅនេះ ៖

១- អតីតេ បឋមកប្បិកេសុ **មហាសម្មតោ** នាម រាជា អហោសិ ក្នុងអតីតកាលដ៏យូរលង់ណាស់ទៅហើយ ក្នុងគ្រាជាបឋមកប្ប មានព្រះរាជាព្រះនាម **មហាសម្មតៈ** ១ព្រះអង្គ។

២- តស្ស បុត្តោ **រោជោ** នាម ព្រះរាជឱរសរបស់

ព្រះអង្គនោះ បានជាក្សត្រទ្រង់ព្រះនាមថា ព្រះបាទ**រោជៈ**,

៣-តស្ស បុត្តោ **វររោជោ** ជាម ព្រះរាជឱរស ព្រះបាទរោជៈនោះ បានជាក្សត្រទ្រង់ព្រះនាមព្រះបាទ**វរ-រោជៈ**,

៤-តស្ស បុត្តោ **កល្យាណោ** ជាម ព្រះរាជ-ឱរសព្រះបាទវររោជៈនោះ បានជាក្សត្រទ្រង់នាមថា ព្រះបាទ**កល្យាណ**,

៥-តស្ស បុត្តោ **វរកល្យាណោ** ជាម ព្រះរាជ-ឱរសព្រះបាទកល្យាណនោះ បានជាក្សត្រទ្រង់ព្រះនាមថា ព្រះបាទ**វរកល្យាណ**,

៦-តស្ស បុត្តោ **ឧបោសថោ** ជាម ព្រះរាជ-ឱរសព្រះបាទវរកល្យាណ បានជាក្សត្រទ្រង់ព្រះនាមថា **ឧបោសថ**,

៧-តស្ស បុត្តោ **មន្ធាតុ** ជាម អហោសិ ព្រះរាជឱរសព្រះបាទឧបោសថ បានជាក្សត្រទ្រង់ព្រះនាមថា ព្រះបាទ**មន្ធាតុ**។

ព្រះបាទមន្ធាតុនោះប្រកបដោយរាជឫទ្ធិសក្តានុ-

*ភាព មានតេជះ បរិបូណ៌ដោយរតនៈពិសេស ៧ ប្រការ[១] ជាបរមចក្រពត្រាធិរាជ មានបុញ្ញានុភាពអស្ចារ្យ ក្នុងកាលដែលព្រះអង្គទ្រង់បត់ព្រះហស្តខាងឆ្វេង សណ្ដូកព្រះហស្តខាងស្តាំ ភ្លៀងរតនៈ ៧ ប្រការ[២] ក៏បង្អុរចុះមកប្រមាណត្រឹមជានុមណ្ឌល (ត្រឹមជង្គង់) ដូចជាភ្លៀងបង្អុរធ្លាក់ចុះមកអំពីអាកាស ព្រះបាទមន្ធាតុជាមនុស្សអស្ចារ្យយ៉ាងនេះ។ កាលព្រះអង្គទ្រង់វ័យនៅជាកុមារប្រកបដោយការលេងកំណត់កាលដ៏យូរបាន ៨ ម៉ឺន ៤ ពាន់ឆ្នាំ, ទ្រង់ធ្វើជាឧបរាជ អស់កាល ៨ ម៉ឺន ៤ ពាន់ឆ្នាំ, កាលបើសោយសិរីរាជសម្បត្តិជាបរមចក្រពត្រាធិរាជ កំណត់កាលបាន ៨ ម៉ឺន ៤ ពាន់ឆ្នាំ, ព្រះជន្មាយុរបស់ព្រះបាទមន្ធាតុនោះមាន*

---

[១]. *រតនៈ ៧ ប្រការរបស់ស្ដេចចក្រពត្តិ* *គឺ* ៖ ១- **ចក្ករតនៈ** (*ចក្ករតន៍*), ២- **ហត្ថិរតនៈ** (*ហត្ថិរតន៍*), ៣- **អស្សរតនៈ** (*អស្សរតន៍*), ៤- **មណិរតនៈ** (*មណិរតន៍*), ៥- **ឥត្ថិរតនៈ** (*ឥត្ថិរតន៍*), ៦- **គហបតិរតនៈ** (*គហបតិរតន៍*), ៧- **បរិណាយករតនៈ** (*បរិនាយករតន៍*)។

(២). *ភ្លៀងរតនៈ៧ប្រការគឺ* ៖ ១- **សុវណ្ណៈ** (*មាស*), ២- **រជតៈ** (*ប្រាក់*), ៣- **មុត្តា** (*កែវមុក្តា*), ៤- **មណិ** (*កែវមណី*), ៥- **វេឡុរិយៈ** (*កែវពិទូរ្យ, កែវភ្នែកឆ្មា*), ៦- **វជិរៈ** (*ពេជ្រ*), ៧- **បវាឡៈ** (*កែវប្រពាល*)។

កំណាត់បាន ១ អសង្ខេយ្យឆ្នាំ។

លុះតមកមានមួយថ្ងៃ ព្រះបាទមន្ធាតុបរមចក្រពត្រាធិរាជនោះ មិនអាចនឹងញុំាងកាមតណ្ហាឲ្យល្មមព្រះទ័យបាន ទើបទ្រង់សំដែងអាការៈដែលព្រះអង្គទ្រង់អផ្សុក គឺមិនត្រេកអរក្នុងរាជសម្បត្តិ។ ពួកអាមាត្យរាជបរិស័ទ ក្រាបបង្គំទូលសួរថា "បពិត្រព្រះអង្គជាសម្មិតទេព អាការៈដែលព្រះអង្គទ្រង់អផ្សុកនោះ បណ្តាលមកអំពីហេតុអ្វី?"

**ព្រះរាជាត្រាស់ថា** "នែ! អាមាត្យទាំងឡាយ យើងឃើញកម្លាំងបុណ្យរបស់យើងមានច្រើន សិរីរាជសម្បត្តិប៉ុណ្ណេះមិនល្មមដល់សេចក្តីត្រេកអររបស់យើងទេ សិរីរាជសម្បត្តិក្នុងឋានណាហ្ន៎ ទើបជាទីរីករាយជាងនេះ?"

**ពួកអាមាត្យឆ្លើយថា** "បពិត្រព្រះអង្គជាសម្មតិទេព ទេវលោក ទើបជាទីរមណីយដ្ឋាន សម្រាន្តព្រះទ័យជាងមនុស្សលោកនេះ"។

ព្រះបាទមន្ធាតុបរមចក្រពត្តិ បានទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ក៏ទ្រង់ធ្វើចក្រកែវឲ្យនាំទៅក្នុងខាងមុខ

ហើយស្តេចយាត្រាព្រមដោយរាជបរិស័ទតាមចក្រកែវនោះ ឡើងទៅកាន់**អាកាសវិថី**។

ចំណែកស្តេចចាតុម្មហារាជិកាទាំង ៤ ឃើញព្រះចៅមន្ធាតុបរមចក្រពត្តិ ស្តេចមកក៏កាន់**ទិព្វមាលា**មានក្លិនក្រអូបឈ្ងុយឈ្ងប់ នាំពួកទេពនិករទាំងឡាយជាបរិវារមកធ្វើ**បច្ចុគមនាការ** នាពាក់កណ្តាលមាគ៌ា អញ្ជើញស្តេចឡើងទៅប្រថាប់ក្នុងជាន់ចាតុម្មហារាជិកា ហើយក៏បង្ហើរសិរីសម្បត្តិក្នុងជាន់ចាតុម្មហារាជិកាថ្វាយព្រះចៅមន្ធាតុបរម-ចក្រពត្តិ។ ព្រះចៅមន្ធាតុសូម្បីបានសោយទិព្វសម្បត្តិក្នុងជាន់ចាតុម្មហារាជិកា ព្រមដោយរាជបរិស័ទនិងទេវបរិស័ទអស់កាលយូរ ក៏នៅមិនអាចនឹងធ្វើសេចក្តីប្រាថ្នាឲ្យពេញបាន ទើបសំដែងអាការៈដែលព្រះអង្គអផ្សុក ទ្រង់មិនបានត្រេកអរក្នុងទេវសម្បត្តិក្នុងជាន់ចាតុម្មហារាជិកានោះទៀត។

**សម្តេចចាតុម្មហារាជិកាទាំង ៤ ក៏ក្រាបទូលបង្គំទូលសួរថា** "បពិត្រមហារាជ ព្រះអង្គអផ្សុកដោយហេតុអ្វី?"

**ព្រះចៅមន្ធាតុបរមចក្រពត្តិត្រាស់ថា** "សិរីសម្បត្តិត្រឹមប៉ុណ្ណេះនៅមិនជាទីត្រេកអរល្មមដល់សេចក្តីប្រាថ្នា

របស់យើងទេ ហើយត្រាស់សួរថា "សិរីសម្បត្តិក្នុងទីណាហ្ន៎ ទើបជាទីត្រេកអរវិសេសជាងនេះទៀត?"

**សម្តេចចាតុម្មហារាជិកាទាំង ៤ ក្រាបបង្គំទូលថា** "បពិត្រមហារាជ ខ្ញុំព្រះអង្គទាំងឡាយនេះជាអ្នកទទួលធ្វើការក្រោមបង្គាប់ស្តេចនៃទេវតាទេ ទីដែលរមណីយដ្ឋានជាងនោះមានតែតាវត្តិង្សទេវលោកឯណោះ ទើបជាទីរីករាយទៅដោយកាមារម្មណ៍ដ៏ឧត្តមជាងជាន់ចាតុម្មហារា-ជិកានេះ"។

កាលព្រះចៅមន្ធាតុបរមចក្រពត្តិ បានទ្រង់ព្រះសណ្តាប់ដូច្នោះហើយ ទើបទ្រង់ធ្វើចក្កកែវឲ្យនាំទៅក្នុងខាងមុខ ព្រះអង្គព្រមដោយរាជបរិស័ទ ក៏ស្តេចបែរព្រះភក្រ្តចំពោះទៅតាវត្តិង្សទេវលោក។

លំដាប់នោះ សម្តេចសក្កទេវរាជទតព្រះនេត្រឃើញព្រះចៅមន្ធាតុបរមចក្រពត្តិស្តេចមក ទើបទ្រង់កាន់ទិព្វមាលាសុគន្ធជាតិ មានអមរទេវតាចោមរោមជាបរិវារស្តេចចេញទៅធ្វើបច្ចុគមនាការទទួល **ចាប់ព្រះហស្តព្រះ**ចៅមន្ធាតុបរមចក្រពត្តិហើយត្រាស់ថា "សូមអញ្ជើញស្តេច

យាងមកខាងណោះ ៕

លុះព្រះចៅមន្ធាតុរាជស្តេចទៅដល់សំណាក់ស្តេចមឃវាហើយ ពួករតនបរិវារយកពលកែវក៏នាំចក្កកែវព្រមទាំងរាជបរិស័ទត្រឡប់ចុះមកកាន់មនុស្សលោកវិញ។ ចំណែកសម្តេចមឃវាទេវរាជនោះ លុះនាំព្រះចៅមន្ធាតុបរមចក្រពត្តិមកដល់តាវត្តិង្សទេវភពហើយ ក៏បែងទិព្វសម្បត្តិថ្វាយព្រះចៅមន្ធាតុបរមចក្រពត្តិនោះពាក់កណ្តាលហើយឲ្យប្រថាប់នៅក្នុងតាវត្តិង្សទេវនគរ។

ចាប់ដើមអំពីនោះមក ព្រះរាជាទាំងពីរព្រះអង្គគឺព្រះចៅមន្ធាតុបរមចក្រពត្តិ និងសម្តេចកោសិយសក្កទេវរាជក៏សោយទិព្វសម្បត្តិរជ្ជសុខស្មើគ្នា ក្នុងតាវត្តិង្សទេវភពនោះ។ កំណត់កាលបាន ៣ កោដិ ៦០សែនឆ្នាំ លុះសម្តេចកោសិយសក្កទេវរាជអង្គនោះអស់ព្រះជន្មាយុចុតិទៅ សម្តេចសក្កទេវរាជអង្គថ្មីមកឧប្បត្តិជំនួសឡើងទៀត ហើយសោយរជ្ជសុខពាក់កណ្តាលដូចអង្គមុន កាលបើអស់អាយុ-ខ័យហើយចុតិទៅ សក្កទេវរាជដែលឧប្បត្តិឡើងនឹងចុតិទៅវិញដោយទំនងនេះ រាប់បាន ៣៦ព្រះអង្គ ចំណែកព្រះចៅ

មន្ធាតុបរមចក្រពត្តិនោះ មានព្រះសរីរកាយជាមនុស្សបាន
សោយទិព្វសុទ្ធាភោជន៍ដ៏បរិសុទ្ធទើបមិនចុតិចាកទេវស្ថាន។

(លុះដល់សម្តេចសក្កទេវរាជអង្គទី ៣៧ ឧប្បត្តិ
ឡើងក្នុងតាវត្តិង្សទេវភពទៀត ក៏បានសោយទិព្វសម្បត្តិរជ្ជ-
សុខពាក់កណ្តាលដូចអង្គមុនៗ) ឯព្រះចៅមន្ធាតុបរម-
ចក្រពត្តិមានសេចក្តីប្រាថ្នាក្នុងបញ្ចពិធកាមគុណ មិនមាន
ទីបំផុត ក៏កើតសេចក្តីខ្វល់ខ្វាយចិត្តមិនគាប់ព្រះទ័យក្នុង
រជ្ជសុខត្រឹមប៉ុណ្ណោះ ទើបទ្រង់ព្រះតម្រិះថា "ប្រយោជន៍អ្វី
ដែលមកសោយទិព្វសម្បត្តិតែត្រឹមពាក់កណ្តាលប៉ុណ្ណោះ
យើងនឹងផ្តាច់ព្រះជន្មជីពសម្តេចមឃវាអង្គថ្មីនេះចេញ
ហើយនឹងអាចសោយទិព្វសម្បត្តិក្នុងជាន់តាវត្តិង្សនេះឲ្យជា
បរមសុខ តែម្នាក់ឯង"។

តែទ្រង់មិនអាចនឹងផ្តាច់ព្រះជន្មជីពស្តេចមឃវា
នោះបានឡើយ កាលមិនបានសម្រេចព្រះរាជបំណងដូច
ទ្រង់ព្រះតម្រិះទុក ក៏កើតទុក្ខទោមនស្សតូចព្រះទ័យគ្រប់
ទិវារាត្រី។ ធម្មតាតណ្ហា គឺសេចក្តីប្រាថ្នាក្នុងកាមគុណនេះ
ជាមូលនៃសេចក្តីវិបត្តិ ព្រោះហេតុនោះ អាយុសង្ខាររបស់

ព្រះចៅមន្ធាតុបរមចក្រពត្តិក៏ត្រូវវិនាសទៅ ខណៈនោះជរាក៏ចូលមកបៀតបៀនព្រះសរីរកាយឲ្យគ្រាំគ្រាទ្រុឌទ្រោមទៅ តែធម្មតាសរីរវយវៈមនុស្សជាតិទាំងឡាយមិនដែលបែកធ្លាយក្នុងទេវលោកនោះឡើយ ព្រោះហេតុដូច្នោះ ព្រះចៅមន្ធាតុបរមចក្រពត្តិ ក៏ត្រូវធ្លាក់ចុះចាកទេវលោក មកនៅក្នុងព្រះរាជឧទ្យាន។

ចំណែកឧទ្យានបាល (អ្នករក្សាសួន) បានឃើញស្តេចមន្ធាតុស្តេចមកនៅក្នុងឧទ្យានដូច្នោះ នាំសេចក្តីនោះទៅក្រាបបង្គំទូលដល់រាជត្រកូលៗ ក៏នាំគ្នាមកតាក់តែងទីព្រះក្រឡាបន្ទំក្នុងព្រះរាជឧទ្យាន ថ្វាយព្រះចៅមន្ធាតុបរមចក្រពត្តិផ្ទំជាអនុដ្ឋានសេយ្យាសន៍។

**ក្នុងខណៈនោះ ពួកអាមាត្យទាំងឡាយនាំគ្នាក្រាបបង្គំទូលសួរថា** "បពិត្រព្រះអង្គជាសម្មតិទេវរាជ ឥឡូវនេះព្រះអង្គនឹងឲ្យខ្ញុំទូលបង្គំទាំងឡាយធ្វើដូចម្តេចក្នុងទីចំពោះព្រះភក្ត្រព្រះអង្គ?"

**ព្រះចៅមន្ធាតុបរមចក្រពត្តិត្រាស់ថា** "អ្នកទាំងឡាយចូរឲ្យដំណឹងនេះដល់មហាជនឲ្យបានដឹងគ្រប់

គ្នាថា ‵ព្រះចៅមន្ធាតុបរមចក្រពត្តិបានសោយរាជសម្បត្តិ ជាបរមចក្រពត្រាធិរាជ មានឥស្សរភាពផ្សាយទៅក្នុងទ្វីបធំទាំង៤ មានទ្វីបតូច ២ ពាន់ ជាបរិវារនឹងបានសោយទិព្វសម្បត្តិក្នុងជាន់ចាតុម្មហារាជិកាដ៏យូរអង្វែង ទាំងបានឡើងទៅសោយទិព្វសម្បត្តិក្នុងតាវត្តិង្សទេវលោក រហូតដល់អស់អាយុរបស់ព្រះឥន្រ្ទ ៣៦ ព្រះអង្គ ក៏នៅមិនអាចញ៉ាំងសេចក្តីត្រេកអរ សេចក្តីប្រាថ្នាក្នុងកាមារម្មណ៍ឲ្យពេញព្រះទ័យបាន ដល់ទីបំផុតក៏ត្រូវឃ្លាតចាកទេវលោកចុះមកផ្ទំក្នុងព្រះរាជឧទ្យាន ឥឡូវនេះ ស្តេចទិវង្គតហើយ″។

ព្រះបាទមន្ធាតុបរមចក្រពត្តិមានព្រះរាជតម្រាស់ផ្តាំដូច្នេះហើយ ក៏ស្តេចទិវង្គតទៅតាមយថាកម្មរបស់ព្រះអង្គ។

សត្ថា ឥមំ អតីតំ អាហរិត្វា សម្តេចព្រះបរម-សាស្តាចារ្យទ្រង់នាំព្រះធម្មទេសនា គឺជាតកនេះមកសំដែងហើយ ទើបត្រាស់នូវបទព្រះគាថាទាំងឡាយដូចតទៅនេះ

យាវតា ចន្ទិមសូរិយា,
បរិហរន្តិ ទិសា ភន្តិ វិរោចនា;
សព្វេវ ទាសា មន្ធាតុ,

យេ ចាណា បជាវិស្សិតា។

ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយ (ដើរក្រឡឹង) ភ្នំសិនេរុ ទិសទាំងឡាយភ្លឺរុងរឿង រហូតទីមានកំណត់ត្រឹមណា សត្វទាំងឡាយណា ដែលអាស្រ័យលើផែនដី សត្វទាំងអស់នោះ ជាទាសៈរបស់ស្តេចមន្ធាតុ រហូតទីមានកំណត់ត្រឹមណោះ។

ន កហាបណវស្សេន,
តិត្តិ កាមេសុ វិជ្ជតិ;
អប្បស្សាទា ទុខា កាមា,
ឥតិ វិញ្ញាយ បណ្ឌិតោ។

ការឆ្អែតក្នុងកាមទាំងឡាយ រមែងមិនមានដោយភ្លៀងកហាបណៈទេ បណ្ឌិតបានដឹងថា កាមទាំងឡាយមានសេចក្តីសុខតិច មានសេចក្តីទុក្ខ (ច្រើន)។

អបិ ទិព្វេសុ កាមេសុ,
រតិំ សោ នាធិគច្ឆតិ;
តណ្ហាក្ខយរតោ ហោតិ,
សម្មាសម្ពុទ្ធសាវកោ។

ព្រោះហេតុនោះ សាវ័កនៃព្រះសម្មាសម្ពុទ្ធនោះ មិនបានត្រេកអរក្នុងកាមទាំងឡាយសូម្បីជាទិព្យ ជាអ្នកត្រេកអរតែក្នុងធម៌ ជាគ្រឿងអស់ទៅនៃតណ្ហា។

**អធិប្បាយគាថា**

បានសេចក្ដីថា ព្រះចន្ទនិងព្រះអាទិត្យទាំងឡាយកាលរះឡើងដើរវិលវង់ក្បែរភ្នំសិនេរុរាជ មានរស្មីដ៏ភ្លឺស្វាងរុងរឿងផ្សាយទៅក្នុងទិសទាំង ១០ ដោយទីមានកំណត់ត្រឹមណា សត្វគឺមនុស្សទាំងឡាយដែលអាស្រ័យនៅលើផែនដីក្នុងទីមានកំណត់ត្រឹមណោះ ជាខ្ញុំព្រះចៅមន្ធាតុរាជទាំងអស់ ព្រះចៅមន្ធាតុរាជកាលទ្រង់មានព្រះរាជបំណងនឹងសង្គ្រោះដល់មនុស្ស ដែលជាខ្ញុំទាំងនោះ ទ្រង់ទះព្រះហស្តក្នុងកាលណា ក្នុងកាលនោះ ភ្លៀងកែវទាំង ៧ ប្រការក៏**បវត្តនាការ**ធ្លាក់ចុះមក សូម្បីយ៉ាងនោះ សេចក្ដីឆ្អែតក្នុងវត្ថុកាមនិងកិលេសកាម ក៏នៅមិនល្មមដល់ព្រះចៅមន្ធាតុ-រាជនោះ ក៏បណ្ឌិតកាលដឹងច្បាស់ថា កាមទាំងឡាយមានសេចក្ដីត្រេកអរតិច គឺមានសេចក្ដីសុខតិច ប្រកបទៅដោយសេចក្ដីទុក្ខច្រើនដូច្នេះ ក៏មិនមានសេចក្ដីត្រេកអរក្នុងកាម

ទាំងឡាយ។ មួយទៀតសាវករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ លោកក៏មិនមានសេចក្តីប្រាថ្នានឹងត្រេកអរក្នុងកាមដ៏ជាទិព្វ នោះឡើយ លោកប្រាថ្នាត្រេកអរតែក្នុងព្រះនិព្វានធម៌ ដែលជាទីអស់ទៅនៃតណ្ហា ដោយចំណែកមួយប៉ុណ្ណោះ។

**ជាតកាវសាន**

កាលសម្តេចព្រះបរមសាស្តាចារ្យ ទ្រង់នាំអតីតនិទានមកត្រាស់ទេសនាយ៉ាងនេះហើយ ទើបទ្រង់ប្រកាសនូវអរិយសច្ចទាំងឡាយ លុះចប់អរិយសច្ចហើយ ភិក្ខុដែលអផ្សុកនោះក៏បានសម្រេចសោតាបត្តិផល ព្រមទាំងភិក្ខុទាំងឡាយដទៃក៏បានសម្រេចផលមានសោតាបត្តិផលជាដើម ទើបសម្តេចព្រះលោកុត្តមាចារ្យទ្រង់ប្រជុំជាតកថា

-តទា មន្ធាតុរាជា អហមេវ អហោសិំ ព្រះបាទមន្ធាតុបរមចក្រពត្តិក្នុងគ្រានោះគឺ**តថាគត**ហ្នឹងឯង ។

មន្ធាតុជាតក ចប់។

(ជាតកដ្ឋកថា តិកនិបាត សង្កប្បវគ្គ មន្ធាតុជាតកវណ្ណនា)

## ១.២.មហាមន្ធាតុវត្ថុ
(ចាកគម្ពីរមធុរសវាហិណី ប្រែដោយសម្តេច
ព្រះធម្មលិខិត ល្វី - ឯម)

*តិរ បានឮរឿង ៗ មកក្នុងទីបំផុតនៃកប្ប ៩១ អំពីភទ្ទកប្បយើងនេះ មានព្រះសម្មាសម្ពុទ្ធមួយព្រះអង្គ ទ្រង់ព្រះនាម**វិបស្សី** ព្រះអង្គបានត្រាស់បរមាភិសេកសម្ពោធិ-ញាណ ជាព្រះពុទ្ធប្រាកដក្នុងលោកព្រះអង្គមានព្រះធម៌ដ៏ប្រសើរ បីដូចជាកង់ចក្របានឲ្យប្រព្រឹត្តទៅហើយ ក្នុងលោក គឺសត្វលោកទាំងឡាយ ព្រមទាំងទេវតា បានបូជានមស្ការព្រះអង្គហើយ ព្រះអង្គគង់នៅក្នុង**នគរពន្ធុមតី**ក្នុងកាលនោះឯង។*

*គ្រានោះ ព្រះបាទមន្ធាតុ បានកើតជាជាងដុសសំពត់[១] ក្នុងនគរនោះឯង ជាអ្នកទាល់ក្ររកស៊ីចិញ្ចឹមជីវិតដោយ**តុន្និកម្ម** (អំពើធ្វើការឈ្នួលដុសសំពត់) ឲ្យគេ យកថ្លៃឈ្នួលចិញ្ចឹមជីវិតជានិច្ច។ ឯមនុស្សទាំងឡាយដែលនៅក្នុងនគរទាំងអស់ ក៏បាននិមន្តព្រះភិក្ខុសង្ឃជាច្រើនមានព្រះពុទ្ធជាប្រធាន បានថ្វាយនូវមហាទានក្នុងកាលនោះឯង។*

---

[១]-*អតីតជាតិរបស់ព្រះបាទមន្ធាតុ។*

ឯបុរសកម្សត់នោះ ក៏បានរំពឹងគិតពិចារណាថា "មនុស្សដែលនៅក្នុងព្រះនគរទាំងអស់ គេបានចាត់ចែងឲ្យមហាទានដល់ព្រះភិក្ខុសង្ឃមានអង្គព្រះពុទ្ធជាប្រធាន ឯអាត្មាអញជាមនុស្សសេសសល់ពីគេតែម្នាក់ឯងផ្តេសផ្តាស ព្រោះអញជាអ្នកកម្សត់ បើអាត្មាអញមិនបានដាំពូជបុណ្យទុកក្នុងព្រះពុទ្ធសាសនានេះទេ អញនឹងពុំបានដោះខ្លួនឲ្យរួចអំពីសេចក្តីទុក្ខលំបាកទាល់ក្រនេះឡើយ តទៅជាតិខាងមុខ អញរឹងរឹតតែកម្សត់ដ៏ក្រៃលែងជាងនេះទៀតដោយពិត" ។

បុរសកម្សត់នោះបានគិតយ៉ាងនេះហើយ ក៏ខំដើរស្វែងរក**តុន្និកម្ម**ស៊ីឈ្នួលដុសសំពត់ឲ្យគេដោយឆាប់រួសរាន់ បាននូវប្រាក់បន្តិចចំនួនមួយមាសកៈ។ កាលបើបានឱកាសល្មមឲ្យទានដល់ភិក្ខុមួយរូប ដោយប្រាក់មួយមាសកៈនោះ ហើយក៏ដើរចូលទៅកាន់រានផ្សារ បានទិញយកនូវសណ្តែករាជមាស បានចំនួនមួយដើងពានតូច ហើយកាន់យកចូលទៅកាន់រោងភត្តដែលជាទីប្រជុំនៃព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ហើយរំពឹងគិតដូច្នេះថា "ឥឡូវនេះ

អញពុំមានឱកាសនឹងដាក់ចុះនូវសណ្ដែករាជមាសក្នុង
បាត្រនៃភិក្ខុបានឡើយ សូម្បីតែភិក្ខុមួយរូបក៏អញឲ្យពុំបាន
សេចក្ដីពិតត្រូវតែអញបាចសណ្ដែករាជមាសទាំងឡាយ
នេះ ទៅលើអាកាសទើបបាន ឯសណ្ដែករាជមាសទាំង
ឡាយនោះ កាលបើធ្លាក់ចុះអំពីអាកាសមកហើយ ក៏គង់
មានសណ្ដែកមួយគ្រាប់ពីរគ្រាប់ ធ្លាក់ចុះក្នុងបាត្រភិក្ខុមួយ
រូបពុំលែងឡើយ សណ្ដែកដែលបានធ្លាក់ចុះក្នុងបាត្រភិក្ខុ
មួយរូបប៉ុណ្ណោះ ក៏មានផលានិសង្ស អាចនាំមកនូវ
ប្រយោជន៍និងសេចក្ដីសុខសេចក្ដីចម្រើនដល់អញអស់
កាលជាយូរអង្វែងទៅអនាគតដោយពិត"។

បុរសនោះបានគិតយ៉ាងនេះហើយ ក៏មានចិត្តជ្រះ
ថ្លាមានសទ្ធាជឿជាក់ឧស្សាហ៍កើតឡើងក៏ចាប់សណ្ដែករាជ
មាសទាំងឡាយបាចទៅលើអាកាស ដើម្បីនឹងឲ្យបានធ្លាក់
ចុះក្នុងបាត្រនៃព្រះភិក្ខុសង្ឃទាំងអស់ មានបាត្រព្រះពុទ្ធជា
ប្រធាន។ ឯគ្រាប់សណ្ដែករាជមាសទាំងឡាយនោះ កាល
អណ្ដែតទៅលើអាកាសជាអស្ចារ្យ ហើយធ្លាក់ចុះពីអាកាស
នោះ ក៏ពុំបានធ្លាក់ចុះខុសបាត្រទៅខាងក្រៅឡើយ សឹង

ធ្លាក់ចុះក្នុងបាត្រនៃព្រះភិក្ខុសង្ឃទាំងអស់ មានបាត្រព្រះមានព្រះភាគជាដើម ដោយតេជានុភាពនៃទេវតាទាំងឡាយផង នៃព្រះមានព្រះភាគផង ដោយវិសេសពិត។ ឯបុរសកម្សត់នោះ បានឃើញនូវសេចក្ដីអស្ចារ្យនោះហើយ មានចិត្តប្រកបដោយបីតិសោមនស្សជ្រះថ្លាពន់ពេក លើកអញ្ជលីផ្គងឡើងលើសិរសា ហើយតាំងនូវសេចក្ដីប្រាថ្នាយ៉ាងនេះថា:

១. ឥមិនា មេ អធិការេន, បសាទេន យតិស្សរេ;
កាមភោគីនហំ អគ្គោ, ភវេយ្យំ ជាតិជាតិយំ។

២. បហាវិត្វា យថា ធាណឹ,
ឱលោកេមិ នភោតលំ;
សត្តរតនសម្បន្នំ,
វស្សំ វស្សតុ សព្វទាតិ។

“ដោយអធិការដែលខ្ញុំបានធ្វើបូជាដ៏ក្រៃលែងនេះ ទៅអនាគតកាលខ្ញុំសូមប្រាថ្នាឲ្យបានជាបុគ្គលដ៏ប្រសើរ ជាធំបំផុតជាងបុគ្គលទាំងឡាយ ដែលជាអ្នកបរិភោគនូវកាមគុណក្នុងលោក បើខ្ញុំអន្ទោលទៅកើតក្នុងជាតិទាំងពួងក្នុង

កពហើយ ខ្ញុំលើកដៃឡើងទះសម្លឹងមើលនូវអាកាសក្នុងកាលឯណា សូមផ្ទៃអាកាសបណ្ដាលកើតឡើងជាភ្លៀងកែវ ៧ប្រការ ចង្អុរធ្លាក់ចុះមកសព្វកាលទាំងពួង"។

ចាប់ដើមតាំងតែពីកាលនោះមក បុរសកម្សត់នោះបានតាំងសេចក្ដីប្រាថ្នាយ៉ាងនេះហើយ ក៏ខំរកស៊ីចិញ្ចឹមជីវិតដោយសុចរិតទៀងត្រង់ល្អដរាបដល់អស់ជីវិតទៅ ក៏បានអន្ទោលទៅអន្ទោលមកតែក្នុងស្ថានមនុស្ស និងទេវតាទាំងឡាយ តែងសោយនូវទិព្វសម្បត្តិដ៏ប្រសើរ។

**១-ឥមស្មឹ កប្បេ អាទិម្ហិ មហាសម្មតោ នាម រាជា អហោសិ** លុះមកដល់ភទ្ទកប្បនេះ មានព្រះបរមក្សត្រិយ៍មួយព្រះអង្គ ទ្រង់ព្រះនាមព្រះបាទ**មហាសម្មតរាជ** ជាក្សត្រិយ៍ខាងដើមវង្សក្នុងកប្បនេះ។

**២-តស្ស បុត្តោ រោជោ នាម** ស្ដេចមហាសម្មតរាជនោះ មានព្រះរាជបុត្រាមួយព្រះនាម **រោជៈ** បានសោយរាជ្យតវង្សមក,

**៣-តស្ស បុត្តោ វររោជោ នាម** ព្រះរាជបុត្ររបស់ស្ដេចរោជៈនោះព្រះនាម**វររោជៈ**,

៤-តស្ស បុត្តោ **កល្យាណោ** ជាម *ព្រះរាជបុត្ររបស់ស្ដេចវររោជៈនោះព្រះនាមកល្យាណៈ*,

៥-តស្ស បុត្តោ **វរកល្យាណោ** ជាម *ព្រះរាជបុត្ររបស់ស្ដេចកល្យាណៈនោះ ព្រះនាម**វរកល្យាណ***,

៦-*វរកល្យាណស្ស* បុត្តោ **ឧបោសថោ** ជាម *ព្រះរាជបុត្ររបស់ស្ដេចវរកល្យាណៈនោះ ព្រះនាម* ***ឧបោសថ***,

៧-ឧបោសថស្ស បុត្តោ **មន្ធាតា** ជាម ហុត្វា **និព្វត្តិ** *រាជបុត្ររបស់ស្ដេចឧបោសថនោះ ព្រះនាម***មន្ធាតុ**។

*ព្រះបាទ***មន្ធាតុ** *គឺបុរសកម្សត់ដែលបានឲ្យទានសណ្ដែករាជមាសក្នុងសាសនាព្រះពុទ្ធវិបស្សីនោះឯង។ ដោយអំណាចផលានិសង្សដែលបានឲ្យទានសណ្ដែករាជ-មាសស្ងោរនោះ ក៏បង្កើតជាអស្ចារ្យពន់ពេកណាស់។ កាលនៅជាកុមារលេងអាចម៍ដី, កាលបើសប្បាយព្រះទ័យ លើកដៃខាងឆ្វេងឡើងទះដោយដៃខាងស្ដាំកាលណា ស្រាប់តែមានផ្ទៃអាកាសបណ្ដាលឡើងជាភ្លៀងកែវ ៧ ប្រការ ធ្លាក់ចុះមកមួយរំពេច នឹងប្រមាណពុំបានឡើយ ក្នុងកាលនោះ*

ឯង ដែលនៅរត់លេងជាកុមារចំនួនប្រាំបីម៉ឺនបួនពាន់ឆ្នាំ, ដល់បានឡើងទីជាព្រះមហាឧបរាជបានប្រាំបីម៉ឺនបួនពាន់ឆ្នាំទៀត, បានទទួលរាជាភិសេកជាស្តេចព្រះបរមចក្រពត្តិ ប្រកបដោយរាជឫទ្ធិទាំងបួន និងចក្រទាំង៧ ប្រការ មានចក្រកែវជាដើម សោយរាជសម្បត្តិក្នុងទ្វីបធំទាំងបួន មានទ្វីបតូចពីរពាន់ជាបរិវារ ទ្រង់ព្រះនាមព្រះបាទ **មន្ធាតុព្រះបរមចក្រ** សឹងមានពួកមហាក្សត្រិយ៍សុទ្ធក្នុងទ្វីបធំទាំងបួនដាក់វេណបម្រើ ក្នុងមួយថ្ងៃ ៗ ប្រាំបីម៉ឺនបួនពាន់ព្រះអង្គ ពុំដែលដាច់ឡើយ។

ចំណែកឯអាយុមនុស្សទាំងឡាយក្នុងកាលនោះ កំណត់មួយអសង្ខេយ្យដោយពិត។

ឯព្រះបាទមន្ធាតុព្រះបរមចក្រនោះ ព្រះអង្គបានសោយរាជ្យជាស្តេចចក្រពត្តិបានចំនួនប្រាំបីម៉ឺនបួនពាន់ឆ្នាំហើយ មានសម័យថ្ងៃមួយ ព្រះអង្គពុំអាចឆ្អែតឆ្អន់នឹងកាមតណ្ហា សេចក្តីប្រាថ្នាក្នុងកាមគុណឲ្យពេញព្រះទ័យបានឡើយ ហើយព្រះអង្គសម្តែងនូវអាការៈអផ្សុកជាទុក្ខព្រួយព្រះទ័យដ៏មានព្រះភក្ត្រក្រៀមក្រំសៅហ្មងក្នុងកាលនោះឯង។

ឯអាមាត្យទាំងឡាយ បានឃើញព្រះបរមក្សត្រិយ៍ ព្រះអង្គមានព្រះភក្ត្រសៅហ្មងដូច្នោះហើយ ក៏ក្រាបទូលសួរថា "បពិត្រព្រះសម្មតិទេព ! ព្រះអង្គទ្រង់អផ្សុក ព្រួយព្រះទ័យដូចម្តេច ?"។

**ឯព្រះបាទមន្ធាតុព្រះបរមចក្រនោះ ព្រះអង្គត្រាស់ថា** "អ្នកទាំងឡាយដ៏ចម្រើន ! កាលអញពិចារណាមើលនូវបុញ្ញកម្មរបស់អញជាអស្ចារ្យ អញយល់ឃើញថា 'រាជសម្បត្តិនេះ មិនល្មមសមគួរដល់បុណ្យអញឡើយ' ទីឯណាដែលជាទីតម្រេកដោយវិសេសជាងទីនេះ មានដែរឬទេ?"

**អាមាត្យទាំងឡាយក្រាបទូលថា** "បពិត្រមហារាជ ! ទីដែលជាទីតម្រេកដោយវិសេស មានតែក្នុងស្ថានចាតុម្មហារាជិកាទេវលោកទើបមាន សូមព្រះអង្គជ្រាប"។

ឯព្រះបាទមន្ធាតុបរមចក្រនោះ ព្រះអង្គទ្រង់ព្រះសណ្តាប់ហើយក៏ស្តេចចាប់ចក្រកែវគ្រវីតាមប្រាថ្នាព្រះអង្គ ដោយឥទ្ធានុភាព ចក្រកែវក៏បណ្តាលកើតឡើងយានជំនិះមួយរំពេច ស្តេចក៏ឡើងគង់លើរាជយានព្រមទាំងបរិស័ទ

ហោះអណ្ដែតទៅលើអាកាសវេហាស៍ បានទៅដល់ទេវ-លោកឈ្មោះចាតុម្មហារាជិកាមួយរំពេចនោះឯង។

ចំណែកឯស្ដេចធំទាំងឡាយបួនព្រះអង្គ សឹងមានដៃកាន់នូវផ្កាកម្រង និងគ្រឿងក្រអូបដ៏ជាទិព្យ ដ៏មានពួកទេវតាទាំងឡាយចោមរោមជាបរិវារ ចេញទៅទទួលដំណើរព្រះបរមពោធិសត្វ ហើយបាននាំព្រះអង្គព្រមទាំងបរិវារចូលទៅកាន់ស្ថានចាតុម្មហារាជិកាទេវលោក ហើយលើករាជសម្បត្តិដ៏ជាទិព្យថ្វាយដល់ព្រះបាទមន្ធាតុព្រះបរមចក្រ សោយរាជ្យក្នុងកាលនោះឯង។ កាលបើព្រះបាទមន្ធាតុព្រះបរមចក្របានឲ្យបរិស័ទត្រឡប់មកកាន់ស្ថានមនុស្សលោកវិញហើយ ព្រះអង្គទ្រង់សោយរាជ្យក្នុងស្ថានចាតុម្មហារាជិកានោះជាសុខក្សេមក្សាន្ត ដ៏កន្លងទៅអស់កាលយូរអង្វែង ចំនួនប្រាំបីម៉ឺនបួនពាន់ឆ្នាំមនុស្ស, ហើយព្រះអង្គពុំអាចនឹងញុំាងកាមតណ្ហា សេចក្ដីប្រាថ្នាក្នុងកាម-គុណ ឲ្យពេញព្រះទ័យបានក្នុងស្ថានចាតុម្មហារាជិកានោះឡើយ ស្ដេចមានសេចក្ដីអផ្សុកពុំសប្បាយព្រះទ័យ សម្ដែងនូវអាការៈដ៏មានព្រះភក្ត្រពុំរីករាយ ក្នុងវេលានោះឯង។

លំដាប់នោះ **ព្រះមហារាជទាំងឡាយបួនព្រះអង្គក៏បានក្រាបទូលសួរថា** "បពិត្រមហារាជ ! ព្រះអង្គទ្រង់ព្រួយព្រះរាជហឫទ័យកើតទុក្ខអផ្សុកដូចម្ដេច?"

**ព្រះបាទមន្ធាតុត្រាស់ថា** "ទីកន្លែងដែលជាទីត្រេកអរ ដោយវិសេសជាងទេវលោកនេះមានដែរឬទេ?"

**ស្ដេចលោកបាលទាំងបួន ក្រាបទូលតបថា** "បពិត្រព្រះសម្មតិទេព ! យើងទាំងឡាយអ្នកបម្រើព្រះអង្គក្នុងស្ថាននេះ ប្រហែលដូចជាមនុស្សដែរ មានតែស្ថានតាវត្តិង្ស-ទេវលោកទើបបានឈ្មោះថា ជាទីតម្រេកដោយវិសេសមួយរយគុណជាងស្ថានចាតុម្មហារាជិកានេះ ដោយពិត សូមព្រះអង្គទ្រង់ជ្រាប"។

ឯព្រះបាទមន្ធាតុទ្រង់ព្រះសណ្ដាប់ហើយ ក៏គ្រវីចក្រកែវដោយមហិទ្ធិឫទ្ធិហោះទៅលើអាកាសវេហាស៍មានទាំងទេវបរិស័ទចោមរោមជាបរិវារ មានព្រះកត្រ្តាឆ្ពោះទៅកាន់ស្ថានតាវត្តិង្សពិភព បានទៅដល់មួយរំពេចនោះឯង។

ចំណែកឯព្រះសក្កទេវិន្ទ្រាធិរាជ ដ៏មានព្រះហត្ថកាន់យកនូវផ្កាកម្រង និងគ្រឿងក្រអូបដ៏ជាទិព្វ ព្រមទាំង

ពួកទេវតាទាំងឡាយ ចោមរោមជាបរិវារ ចេញទៅទទួលដំណើរហើយនាំព្រះបាទមន្ធាតុបរមពោធិសត្វនោះ ចាប់ព្រះហស្តនាំចូលទៅក្នុងភពក្រាបទូលថា "បពិត្រមហារាជ! សូមព្រះអង្គយាងមកខាងនេះ"។

លុះដល់សម្តេចសក្កទេវរាជបាននាំព្រះបាទមន្ធាតុបរមពោធិសត្វទៅដល់សិរីភពរបស់ខ្លួនហើយក៏ធ្វើបែងចំណែកទេវតាទាំងឡាយឲ្យជាពីរចំណែក ហើយបែងចែកចំណែករាជសម្បត្តិទិព្វរបស់ខ្លួនពាក់កណ្តាលថ្វាយដល់ព្រះបាទមន្ធាតុ។ ព្រះបរមពោធិសត្វនោះ ទ្រង់សោយរាជ-សម្បត្តិដ៏ទិព្វពាក់កណ្តាល ក្នុងឋានតាវត្តិង្សទេវលោកនោះឯង។

ចាប់ដើមតែអំពីកាលនោះមក ព្រះបាទមន្ធាតុព្រះបរមចក្រព្រះអង្គបានសោយរាជសម្បត្តិជាសុខក្សេមក្សាន្តឥតមានសេចក្តីរង្កៀសឡើយ។

លុះដល់កាលកន្លងទៅយូរអង្វែងយ៉ាងនេះហើយ សក្កទេវរាជនោះបានសោយសម្បត្តិទិព្វពាក់កណ្តាល កំណត់អាយុបានបីកោដិប្រាំមួយលានឆ្នាំមនុស្ស ក៏ច្យុតទៅ

មានព្រះឥន្ទ្រាធិរាជដទៃទៀងទៅកើតក្នុងឋានតាវត្តិង្សទេវ-លោកនោះទៀត ព្រះឥន្ទ្រាធិរាជនោះបានសោយរាជ-សម្បត្តិទិព្វក្នុងឋានតាវត្តិង្សទេវលោកនោះឯង ដល់កំណត់អស់អាយុក៏ច្យុតចុះមកទៀត ដរាបដល់ព្រះឥន្ទ្រាទាំងឡាយ៣៦ ព្រះអង្គ តែងទៀងទៅកើត កំណត់អស់អាយុហើយច្យុត ដោយហេតុដូចបានអធិប្បាយមកខាងដើមនេះឯង។

ចំណែកឯព្រះបាទមន្ធាតុព្រះបរមចក្រ បានសោយរាជសម្បត្តិជាស្តេចនៃទេវតា កំណត់អាយុព្រះឥន្ទ្រាធិរាជ ៣៦ តំណ ដោយរាងកាយជាមនុស្សយ៉ាងនេះហើយ ក៏ព្រះអង្គមានកាមតណ្ហាសេចក្តីប្រាថ្នាក្នុងកាមគុណមិនចេះពេញ ចេះតែខ្វះជានិច្ច រឹងរឹតតែមានកាមតណ្ហាចម្រើនកើតជំក្រៃលែងឡើងទៀត ហើយទ្រង់ព្រះចិន្តាពិចារណាថា "រាជសម្បត្តិទិព្យពាក់កណ្តាលនេះ មិនជាប្រយោជន៍អ្វីដល់អញឡើយ ត្រូវតែអញសម្លាប់ព្រះឥន្ទ្រាធិរាជនេះចោល ហើយសោយរាជសម្បត្តិក្នុងឋានតាវត្តិង្សទេវលោកនេះតែម្នាក់ឯង ទើបល្មមនឹងបុណ្យអញដោយពិត"។

ព្រះបាទមន្ធាតុព្រះបរមចក្រទ្រង់គិតដូច្នេះហើយ ក៏ពុំអាចនឹងសម្លាប់នូវសក្កទេវរាជនោះបានឡើយ។ ឯកាមតណ្ហាដែលកើតឡើងយ៉ាងនេះគ្រាន់តែជាឫសគល់នៃសេចក្ដីវិបត្តិ ខូចខាតប្រយោជន៍ខ្លួនតែម្យ៉ាង។ សេចក្ដីពិតដូច្នេះ បានជាព្រះអរហន្តទាំងឡាយលោកពោលជាបទគាថាទាំងឡាយថា:

វរមតិសុខញ្ញាកា,
អតិច្ឆាវិហាតោ នរោ;
ឥធ វា បរត្ត វា កិញ្ចិ,
ន សា តំ វន្ទតេ សទា។

សេចក្ដីសុខដ៏ប្រសើរក្រៃលែង ទើបអាចធ្វើឲ្យផុតចាកកង់ទុក្ខទាំងពួងបាន ឯនរជនតែបណ្ដោតបណ្ដោយឲ្យសេចក្ដីឥច្ឆាប្រាថ្នាលោភច្រើនដ៏ក្រៃលែងគ្របសង្កត់ខ្លួនបានហើយ សេចក្ដីឥច្ឆាប្រាថ្នាដ៏ក្រៃលែងនោះពុំបានញ៉ាំងនរជននោះ ឲ្យបាននូវសេចក្ដីសុខដ៏ប្រសើរនោះតិចតួចក្នុងលោកនេះ ឬលោកខាងមុខ ក្នុងកាលទាំងពួងឡើយ។

តណ្ហាយ ជាយតេ សោកោ,

តណ្ហាយ ជាយតេ ភយំ;
តណ្ហាយ វិប្បមុត្តស្ស,
នត្ថិ សោកោ កុតោ ភយំ។

*សេចក្ដីសោកស្រណោះអាឡោះអាល័យក្ដៅក្រហាយដែលនឹងកើតឡើង ក៏កើតមកតែពីសេចក្ដីប្រាថ្នាក្នុងកាមគុណពិត សេចក្ដីភ័យអន្តរាយក៏កើតតែពីសេចក្ដីប្រាថ្នាក្នុងកាមគុណពិត កាលបើបុគ្គលមានចិត្តរួចស្រឡះចេញចាកតណ្ហាហើយ សេចក្ដីសោកក្ដៅក្រហាយ នឹងភយន្តរាយកើតមានមកពីទីឯណា។*

តណ្ហាធាសោ ជនោ ឃត្ថ,
រាជចោរាទិសម្ភវំ;
ហាត្វច្ឆេទាទិកំ ទុក្ខំ,
ចាបុណាតិ វិហញ្ញតិ។

*នរជនដែលលុះអំណាចនៃតណ្ហា ជាខ្ញុំបម្រើតណ្ហាហើយ តែងលំបាកដល់នូវសេចក្ដីទុក្ខជាទម្ងន់ មានត្រូវទោសកាត់ដៃជើងជាដើម កើតឡើងព្រមអំពីសត្រូវមានសេចក្ដីរឹបជាន់និងចោរលួចប្លន់ជាដើម ក្នុងលោកនេះ។*

យេន លោភេន ជាតេន,
លទ្ធា ជិយន្តិ ចាណិនោ
ខេត្តវត្ថុហិរញ្ញំ វា,
គវាស្ស ទាសបោរិសំ
សព្វថាមេន សោ លោភោ,
មហាតព្វោ ច វិញ្ញុនា។

*សត្វទាំងឡាយដែលបានស្រែចម្ការ និងមាសប្រាក់ច្រើនក្តី បានគោសេះ និងបុរសជាខ្ញុំបម្រើច្រើនក្តី ហើយទំនងនឹងវិនាសទៅវិញដោយសេចក្តីលោភតណ្ហាឯណាដែលកើតឡើង ហើយសេចក្តីលោភតណ្ហានោះ គឺអ្នកប្រាជ្ញដែលចេះដឹងពិត ត្រូវប្រព្រឹត្តលះបង់ចោលចេញឲ្យដាច់ ដោយកម្លាំងនៃញាណ ដែលមានកម្លាំងដោយប្រការទាំងពួងពិត។*

*ឯអាយុសង្ខារនៃព្រះបរមពោធិសត្វ ដែលមានសេចក្តីឥច្ឆាប្រាថ្នាច្រើនក្រៃពេក គ្របសង្កត់ចិត្តហើយ ក៏សាបសូន្យថយចុះទៅក្នុងកាលនោះឯង សេចក្តីចាស់ជរាក៏ប្រហារនូវសរីរៈឲ្យទ្រុឌទ្រោមគ្រាំគ្រាទៅមួយរំពេច ឯសរីរៈ*

របស់មនុស្សក៏ប្រាកដឡើង ពុំបានលាយច្រឡំដោយសរីរៈនៃទេវតាក្នុងឋានទេវលោកឡើយ។

គ្រាកាលនោះ ព្រះបាទមន្ធាតុព្រះបរមចក្រពត្រាធិរាជ ទ្រង់របូតធ្លាក់ចុះមកចាកឋានទេវលោក បានមកឋិតនៅក្នុងព្រៃឧទ្យានរបស់ព្រះអង្គដូចកាលមុនវិញ។

ឯបុរសដែលជាអ្នករក្សានូវឧទ្យានបានដឹងហើយ ក៏នាំយកសេចក្ដីដែលព្រះបាទមន្ធាតុព្រះបរមចក្រនោះស្ដេចត្រឡប់មកពីស្ថានសួគ៌វិញហើយ ចូលទៅក្រាបទូលក្នុងរាជត្រកូលទាំងអស់ ឲ្យបានជ្រាបសព្វគ្រប់ក្នុងវេលានោះឯង។ ឯស្ដេចដែលជាធំក្នុងរាជត្រកូល ក៏បានចេញមកអំពីរាជត្រកូលហើយ ចាត់ចែងសេវកាមាត្យទាំងឡាយឲ្យក្រាលរាជាសនៈដ៏ប្រសើរក្នុងសួនឧទ្យាននោះ។

លំដាប់នោះ ព្រះបាទមន្ធាតុព្រះបរមចក្រព្រះអង្គក៏ឡើងផ្ទំលើរាជាសនៈដ៏ប្រសើរ ដែលសេវកាមាត្យក្រាលថ្វាយហើយ ព្រះអង្គផ្ទំស្រេចជាអនុដ្ឋានសេយ្យា គឺផ្ទំពុំបានក្រោកឡើងវិញឡើយ។ វេលានោះអាមាត្យទាំងឡាយក៏បានចូលមកជួបជុំ ហើយថ្វាយបង្គំក្រាបទូលសួរថា "បពិត្រ

ព្រះសម្មតិទេព ! ពីកាលមុនរៀងមកយើងទាំងឡាយត្រូវពោលដូចម្ដេចខ្លះ?”

ឯព្រះបាទមន្ធាតុព្រះបរមចក្រ ព្រះអង្គទ្រង់ព្រះសណ្ដាប់ហើយក៏ត្រាស់ថា “ម្នាលអ្នកទាំងឡាយដ៏ចម្រើន ! អ្នកត្រូវសម្ដែងប្រាប់ពាក្យបណ្ដាំរបស់អញពីកាលមុនរៀងមកថា ‘ព្រះបាទមន្ធាតុជាស្ដេចធំដ៏ប្រសើរ ព្រះអង្គបានសោយរាជសម្បត្តិជាស្ដេចចក្រពត្តិក្នុងទ្វីបធំទាំងបួន មានទ្វីបតូចពីរពាន់ជាប់រិវារ ជាអស្ចារ្យពន់ពេកណាស់ មិនតែប៉ុណ្ណោះព្រះអង្គបានឡើងទៅសោយសម្បត្តិទិព្យ ក្នុងឋានចាតុម្មហារាជិកាកំណត់បានប្រាំបីម៉ឺនបួនពាន់ឆ្នាំមនុស្ស ហើយស្ដេចបានឡើងទៅសោយរាជ្យសម្បត្តិទិព្វ ក្នុងឋានតាវត្តិង្សទេវលោក អស់កាលជាអំឡុងយូរពន់ពេក ដោយកំណត់នៃអាយុព្រះឥន្ទទាំងឡាយ៣៦ តំណ ទើបព្រះអង្គបានធ្វើមរណកាលក្សិណក្ស័យព្រះជន្មទៅ’”។

ឯព្រះបាទមន្ធាតុព្រះបរមពោធិសត្វនោះ ព្រះអង្គមានព្រះបន្ទូលតែប៉ុណ្ណោះហើយ ក៏ទ្រង់សោយព្រះទិវង្គតទៅ ហើយបានទៅតាមយថាកម្មរបស់ព្រះអង្គហោង។

ឥមមត្ថំ បកាសេតុំ ភគវា ចតុមហាបរិសមជ្ឈេ ឥមា គាថាយោ អាហ *បពិត្រអើយ ! អង្គស្តេចព្រះលោកុត្តរាចារ្យដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គទ្រង់ត្រាស់សម្តែងរឿងនេះចប់ស្រេចហើយ ក៏ពោលបទព្រះគាថាទាំងឡាយនេះថា ៖*

យាវតា ចន្ទិមសូរិយា,
បរិហរន្តិ ទិសា ភន្តិ វិរោចនា;
សព្វេវ ទាសា មន្ធាតុ,
យេ ចាណា បថវិស្សិតា។

*ព្រះអាទិត្យ និងព្រះចន្ទទាំងឡាយ ដែលភ្លឺស្វាងរុងរឿង ញុំាងទិសទាំង៤ ឲ្យភ្លឺច្បាស់ ផ្សាយទៅក្នុងទីមានប្រមាណត្រឹមណា សត្វទាំងឡាយណា ដែលនៅអាស្រ័យនឹងផែនដី ក្នុងទីមានប្រមាណប៉ុណ្ណោះ សត្វទាំងនោះសុទ្ធតែជាទាសីទាសាជាខ្ញុំបម្រើព្រះបាទមន្ធាតុព្រះបរមចក្រទាំងអស់ ដោយពិត។*

ន កហាបណវស្សេន,
តិត្តិ កាមេសុ វិជ្ជតិ;

អប្បស្សាទា ទុខា កាមា,
ឥតិ វិញ្ញាយ បណ្ឌិតោ។

*បណ្ឌិតជាតិ ជាអ្នកប្រាជ្ញអាចមានបញ្ញា ត្រូវពិចារណាឲ្យដឹងដូច្នេះថា សេចក្តីឆ្អែតពេញប្រាថ្នាក្នុងកាមគុណទាំងឡាយ ដោយអំណាចតែកហាបណៈមានប្រមាណច្រើនក៏ពុំមានឡើយ កាមគុណទាំងឡាយរមែងនាំមកនូវសេចក្តីទុក្ខលំបាក មានសេចក្តីជ្រះថ្លាតិចស្តួចស្តើងណាស់។*

អបិ ទិព្វេសុ កាមេសុ,
រតឹ សោ នាធិគច្ឆតិ;
តណ្ហាក្ខយរតោ ហោតិ,
សម្មាសម្ពុទ្ធសាវកោ។

*ចំណែកឯព្រះបាទមន្ធាតុព្រះបរមចក្រនោះ ព្រះអង្គពុំបានសម្រេចនូវសេចក្តីតម្រេកត្រេកអរក្នុងកាមគុណដ៏ជាទិព្យឡើយ ព្រោះហេតុដូចនោះ បានជាសម្មាសម្ពុទ្ធសាវ័ក លោកមានតែតម្រេកត្រេកអរក្នុងចិត្តដែលអស់សូន្យទៅនៃតណ្ហា ដោយចំណែកមួយដោយពិត។*

មហាជនទាំងឡាយ បានស្ដាប់នូវព្រះគាថានោះ ហើយក៏បានសម្រេចនូវមគ្គ និងផលមានសោតាបត្តិមគ្គជាដើម ក្នុងកាលនោះឯង។

ព្រោះហេតុដូច្នេះ បានជាព្រះអរហន្តទាំងឡាយលោកសំដែងបទគាថាដូច្នេះថា ៖

ឥតិ និយតគតិំ ពោធិយាធិមត្តានំ,
សការសមុបនេត្វា នេតិ ទុក្ខានិ តណ្ហា;
អនិយតគតិកានំ កា កថា មានិសានំ,
បជហាថា ឥតិ មន្ត្វា ភោ ភវេ តន្តិ វត្ថុំ។

តណ្ហាអាចប្រមូលដឹកនាំមហាបុរសទាំងឡាយដែលមានព្យាយាមមាំក្នុងពោធិញាណ មានគតិទៀងទាត់នេះឲ្យចូលទៅជិតកាន់អំណាចរបស់ខ្លួនបាន ហើយប្រគល់ឲ្យនូវសេចក្ដីទុក្ខលំបាកឥតគណនាយ៉ាងដូច្នេះ ចាំបាច់និយាយទៅថ្វីដល់បុគ្គលប្រាកដស្មើដោយយើងទាំងឡាយ ដែលប្រកបដោយគតិមិនទៀងយ៉ាងនេះ ម្នាលអ្នកទាំងឡាយដ៏ចម្រើន ! បើអ្នកបានពិចារណាដឹងច្បាស់យ៉ាងនេះហើយ ត្រូវតែលះបង់ចោលនូវតណ្ហានោះ ដែលជាវត្ថុ

ជាគ្រឿងត្រេកអរក្នុងកពឲ្យស្រឡះចេញ ទើបបានសេចក្ដីសុខក្សេមក្សាន្តពិតប្រាកដហោង។

សំដែងរឿងព្រះមហាមន្ធាតុបរមចក្រជាគម្រប់ ៨ ក្នុងវគ្គទីមួយក៏ចប់សេចក្ដីដោយសង្ខេបតែប៉ុណ្ណោះឯង។

(គម្ពីរមធុរសវាហិណីប្រែដោយសម្ដេចព្រះធម្មលិខិត ល្វីឯម)

************

## ២.សាធិនជាតក
(បកិណ្ណកនិបាតជាតក បិដកលេខ ៦០ ទំព័រ ៤៤ និងអដ្ឋកថា)



*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធឧបាសកទាំងឡាយដែលសមាទានឧបោសថ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា "***អច្ឆេរំ វត លោកស្មឹ*** " ដូច្នេះជាដើម។*

*គ្រានោះ ព្រះសាស្តាត្រាស់ថា "*ឧបាសកា បោរាណកបណ្ឌិតា អត្តនោ ឧបោសថកម្មំ និស្សាយ

**មនុស្សសរីរេនេវ ទេវលោកំ គន្ត្វា ចិរំ វសឹសុ** ម្នាល ឧបាសកទាំងឡាយ បោរាណកបណ្ឌិតបានអាស្រ័យ ឧបោសថកម្មរបស់ខ្លួន ហើយទៅកាន់ទេវលោកដោយសរីរៈ ជារបស់មនុស្ស និងនៅអស់កាលដ៏យូរ" ដូច្នេះហើយ ទ្រង់ ដែលឧបាសកទាំងឡាយនោះសូមអង្វរហើយ ទើបនាំអតីត និទានមកសម្តែងថា

ក្នុងអតីតកាល ព្រះរាជាព្រះនាម **សាធិនៈ** សោយ រាជសម្បត្តិ ប្រកបដោយធម៌ ក្នុងនគរ**មិថិលា**។ ព្រះរាជា នោះឲ្យគេកសាងសាលាធទាន ៦ កន្លែង គឺ ត្រង់ទ្វារនគរ ៤ កន្លែង, ត្រង់កណ្តាលនគរ ១ កន្លែង និង ទ្រង់ទ្វារ និវេសន៍ ១ កន្លែង ទ្រង់ធ្វើជម្ពូទ្វីបទាំងមូលឲ្យលើកនង្គល ឡើង (រក្សានង្គ័លលែងភ្ជួររាស់) ញុំាងមហាទានឲ្យប្រព្រឹត្ត ទៅ ដោយចំណាយព្រះរាជទ្រព្យ ៦០០,០០០ រាល់ៗថ្ងៃ ទ្រង់រក្សាសីល ៥ និង ឧបោសថ។ សូម្បីអ្នកដែនក៏ឋិតនៅ ក្នុងឱវាទរបស់ព្រះរាជានោះ ធ្វើបុណ្យទាំងឡាយមានឲ្យ ទានជាដើម កាលធ្វើកាលកិរិយាហើយបានកើតក្នុងទេវន- គរ។ ទេវតាទាំងឡាយដែលអង្គុយត្រៀបត្រាក្នុងសុធម្មទេវ-

សភា នាំគ្នាពណ៌នាសីលគុណជាដើម របស់ព្រះរាជាសា-ធិនៈ។ សូម្បីទេវតាដ៏សេសស្តាប់ពាក្យនោះហើយជាអ្នកប្រាថ្នានឹងឃើញព្រះរាជានោះ។

**សក្កទេវរាជបានដឹងចិត្តរបស់ទេវតាទាំងនោះហើយពោលថា** "អ្នកទាំងឡាយប្រាថ្នានឹងឃើញនូវសាធិន-រាជឬ ?"

**ពួកទេវតាពោលថា** "ព្រះករុណា ទេវរាជ"។

**ស្តេចសក្កៈបញ្ជាមាតលីថា** "អ្នកចូរទៅ ដោយប្រកបវេជយន្តរថ ហើយនាំសាធិនរាជ មក"។

**ព្រះមាតលីទទួលថា** "សាធុ" ហើយប្រកបនូវរថទៅកាន់វិទេហរដ្ឋ ពេលនោះជាថ្ងៃពេញបូណ៌មី។

ព្រះមាតលីបររថឲ្យទៅជាមួយនឹងមណ្ឌលព្រះចន្ទក្នុងកាលដែលមនុស្សទាំងឡាយបរិភោគអាហារពេលល្ងាចរួច អង្គុយប្រជុំគ្នាពោលកថា ដែលជាសុខត្រង់ទ្វារផ្ទះ។

**មនុស្សទាំងឡាយពោលថា** "ព្រះចន្ទ ២ ដួងតាំងឡើង" ពេលឃើញរថដែលកំពុងមក ដោយការលះបង់

មណ្ឌលព្រះចន្ទហើយ ទើបពោលម្ដងទៀតថា "នេះមិនមែនព្រះចន្ទទេ នោះគឺជារថ ប្រាកដជាទេវបុត្រនាំរថជាទិព្វ ដែលប្រកបដោយសិទ្ធពមនោម័យមក ដើម្បីអ្នកណា មិនដើម្បីអ្នកដទៃឡើយ ដើម្បីព្រះរាជារបស់យើង ព្រោះថាព្រះរាជារបស់យើងជាធម្មិករាជ ជាធម្មរាជា" ដូច្នេះហើយ មានសេចក្ដីសោមនស្ស ផ្គងអញ្ជលី ពោលគាថាទី ១ ថា

**អច្ឆេរំ វត លោកស្មឹ,**
**ឧប្បជ្ជិ លោមហំសនោ;**
**ទិព្វោ រថោ បាតុរហុ,**
**វេទេហស្ស យសស្សិនោ។**

ចម្លែកណាស់តើ គួរឲ្យព្រឺរោម កើតឡើងក្នុងលោក រថជាទិព្យបានកើតប្រាកដដល់ស្ដេចវិទេហៈ ព្រះអង្គមានយស។

គាថានោះមានសេចក្ដីថា ឱហ្ន៎! អស្ចារ្យណាស់ ព្រះរាជារបស់យើង ការព្រឺរោមកើតឡើងក្នុងលោក រថជាទិព្វរមែងប្រាកដដល់ព្រះបាទវិទេហៈដ៏ទ្រង់យស។

ចំណែកព្រះមាតលីនាំរថនោះមកហើយ កាល

មនុស្សទាំងឡាយបូជា ដោយគ្រឿងក្រអូបនិងកម្រងផ្កាជាដើម ក៏ធ្វើប្រទក្សិណនគរ ៣ ជុំ រួចទៅកាន់ទ្វាររាជនិវេសន៍របស់ព្រះរាជា ញ៉ាំងរថឲ្យបែរត្រឡប់ ទើបឋិតនៅត្រង់ធរណីទ្វារសីហបញ្ជរ ដោយចំណែកខាងក្រោយ ធ្វើការត្រៀមដំណើរ។ ថ្ងៃនោះ សូម្បីព្រះរាជា កាលទ្រង់សម្ទឹងសាលាទានជាដើម បានបញ្ជាថា "អ្នកទាំងឡាយចូរឲ្យទានដោយនិយាមនេះ" ហើយទ្រង់សមាទានឧបោសថ ញ៉ាំងថ្ងៃឲ្យកន្លងទៅ ទ្រង់ឡោមព័ទ្ធដោយពួកអាមាត្យ ប្រថាប់ដោយបែរព្រះភក្ត្រឆ្ពោះទៅសីហបញ្ជរទិសខាងកើត សម្ដែងកថាប្រកបដោយធម៌ ក្នុងសាលាដែលគេប្រដាប់តាក់តែងហើយ។ លំដាប់នោះ ព្រះមាតលីទូលអញ្ជើញព្រះអង្គឲ្យឡើងលើរថ ហើយនាំទៅ។

ព្រះបរមសាស្ដាកាលប្រកាសសេចក្ដីនោះ បានត្រាស់ព្រះគាថាទាំងឡាយថា

**ទេវបុត្តោ មហិទ្ធិកោ,**
**មាតលិ ទេវសារថិ;**
**និមន្តយិត្ថ រាជានំ,**

វេទេហំ មិថិលគ្គហំ។

*ទេវបុត្រឈ្មោះមាតលី ជាទេវសារថី មានឫទ្ធិច្រើន បានអញ្ជើញព្រះបាទវិទេហៈ ព្រះអង្គគ្រប់គ្រងក្រុងមិថិលាថា*

ឯហិមំ រថមារុយ្ហ,
រាជសេដ្ឋ ទិសម្បតិ;
ទេវា ទស្សនកាមា តេ,
តាវតឹសា សឥន្ទកា;
សរមានា ហិ តេ ទេវា,
សុធម្មាយំ សមច្ឆរេ។

*បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គយាងឡើងកាន់រថនេះ ទេវតាទាំងឡាយជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ ចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយរលឹកព្រះអង្គ នៅរង់ចាំក្នុងរោងឈ្មោះសុធម្មា។*

តតោ ច រាជា សាធិនោ,
វេទេហោ មិថិលគ្គហោ;
សហស្សយុត្តមារុយ្ហ,
អគា ទេវាន សន្តិកេ;

តំ ទេវា បដិនន្ទិំសុ,
ទិស្វា រាជានមាគតំ។

លំដាប់នោះឯង ព្រះបាទវិទេហៈ ព្រះនាមសាធិន ព្រះអង្គគ្រប់គ្រងក្រុងមិថិលា ទ្រង់យាងឡើងកាន់រថ ទឹមដោយសេះច្រើន ហើយបានយាងទៅក្នុងសំណាក់នៃទេវតាទាំងឡាយ (ព្រះរាជាជាធំ ទ្រង់ប្រថាប់លើទិព្វយានឈ្មោះហយវាហី ដែលទឹមដោយសេះច្រើន កំពុងយាងទៅក៏បានទតឃើញទេវសភានេះ) ពួកទេវតាបានឃើញព្រះរាជានោះមកដល់ហើយ ក៏ត្រេកអរស្មោះចំពោះថា

ស្វាគតំ តេ មហារាជ,
អថោ តេ អទុរាគតំ;
និសីទ ទានិ រាជីសិ,
ទេវរាជស្ស សន្តិកេ។

បពិត្រមហារាជ ព្រះអង្គយាងមកស្រួលហើយ មិនមែនយាងមកដោយមិនស្រួលទេ បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ប្រសើរ ឥឡូវនេះ សូមព្រះអង្គទ្រង់គង់ក្នុងសំណាក់នៃទេវរាជចុះ។

សក្កោបិ បដិនន្ទិត្វា,
វេទេហំ មិថិលគ្គហំ;
និមន្តយិត្ថ កាមេហិ,
អាសនេន ច វាសវោ។

*ឯព្រះឥន្ទ្រក៏ទទួលរាក់ទាក់ចំពោះព្រះបាទវិទេហៈ ព្រះអង្គគ្រប់គ្រងក្រុងមិថិលា ព្រះឥន្ទ្របានអញ្ជើញដោយកាមទាំងឡាយផង ដោយអាសនៈផងថា*

សាធុ ខោសិ អនុប្បត្តោ,
អាវាសំ វសវត្តិនំ;
វស ទេវេសុ រាជីសិ,
សព្វកាមសមិទ្ធិសុ;
តាវតឹសេសុ ទេវេសុ,
ភុញ្ជ កាមេ អមានុសេ។

*ប្រពៃណាស់ហើយ ព្រះអង្គបានដល់អាវាសរបស់ទេវតាទាំងឡាយ ដែលញុំាងគេឲ្យប្រព្រឹត្តក្នុងអំណាចខ្លួន បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ប្រសើរ សូមព្រះអង្គគង់នៅក្នុងពួកទេវតាដែលសម្រេចនូវកាមគ្រប់យ៉ាងបាន*

*សូមព្រះអង្គសោយនូវកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្ស ក្នុងពួកទេវតាជាន់តាវត្តិង្សចុះ។*

*បណ្តាបទទាំងនោះ បទថា* **សមច្ឆរេ** *សេចក្តីថា នៅរង់ចាំ។ បទថា* **អគា ទេវាន សន្តិកេ** *សេចក្តីថា ទៅកាន់សម្នាក់ទេវតា។ ក្នុងពេលនោះ កាលព្រះរាជាឡើងកាន់រថហើយបិតនៅ រថបានស្ទុះទៅកាន់អាកាស ព្រះរាជានោះ ដែលមហាជនកំពុងមើល ក៏បានបាត់ទៅ។ ព្រះមាតលីនាំព្រះរាជាទៅកាន់ទេវលោក។ ទេវតា និងស្តេចសក្កៈបានឃើញព្រះរាជាហើយ មានចិត្តត្រេកអរ នាំគ្នាក្រោកទទួល និងធ្វើបដិសណ្ឋារៈ។ ដើម្បីសម្តែងសេចក្តីនោះ លោកទើបពោលថា* **តំ ទេវ** *ដូច្នេះជាដើម។ បទថា* **បដិនន្ទិំសុ** *សេចក្តីថា ត្រេកអររឿយៗ។ បទថា* **អាស-នេន ច** *សេចក្តីថា ព្រះឥន្ទឱបព្រះរាជា ហើយអញ្ជើញដោយ***បណ្ឌុកម្ពលសិលាសនៈ** *និងដោយកាមទាំងឡាយរបស់ខ្លួនថា សូមអង្គុយទីនេះ រួចហើយក៏បែងចែករាជ-សម្បត្តិពាក់កណ្តាល ឲ្យព្រះរាជាអង្គុយលើអាសនៈជាមួយគ្នា។*

*កាលព្រះបាទសាធិនៈសោយរាជសម្បត្តិ ដែលសក្កទេវរាជបែងចែកទេវនគរ ដែលមានទំហំ ១០,០០០ យោជន៍ ស្រីទេពអប្សរ ២ កោដិកន្លះ និងវេជយន្តប្រាសាទពាក់កណ្តាល ប្រទានឲ្យ អស់កាល ៧០០ ឆ្នាំដោយការរាប់ឆ្នាំមនុស្ស ឲ្យកន្លងទៅៗ ព្រះអង្គនៅក្នុងទេវលោកដោយអត្តភាពនោះ កាលអស់បុណ្យហើយ ក៏កើតសេចក្តីមិនត្រេកអរ ព្រោះហេតុនោះ កាលចរចាជាមួយនឹងស្តេចសក្កៈទើបពោលគាថា ថា*

អហំ បុរេ សគ្គគតោ រមាមិ,
នច្ចេហិ គីតេហិ ច វាទិតេហិ;
សោ ទានិ អជ្ជ ន រមាមិ សគ្គេ,
អាយុំ នុ ខីណោ មរណំ នុ សន្តិកេ;
ឧទាហុ មូឡ្ហោស្មិ ជនិន្ទសេដ្ឋ។

*កាលពីដើម ខ្ញុំមកនៅក្នុងឋានសួគ៌ រីករាយដោយរបាំ ចម្រៀង និងប្រគំទាំងឡាយ ឥឡូវនេះ ក្នុងថ្ងៃនេះ ខ្ញុំមិនត្រេកអរក្នុងឋានសួគ៌ទេ បពិត្រព្រះជនិន្ទដ៏ប្រសើរ អាយុ (របស់ខ្ញុំ) នឹងអស់ឬ ឬសេចក្តីស្លាប់ (ឋិតនៅ) ក្នុងទី*

ជិត ឬក៏ខ្ញុំជាបុគ្គលវង្វេង។

បណ្ដាបទទាំងនោះ បទថា **អាយុំ នុ ខីណោ** សេចក្ដីថា ព្រះបាទសាធិនៈសួរថា ជីវិតិន្ទ្រិយក្នុងសរីរៈរបស់ខ្ញុំអស់ហើយឬ ឬថា ជីវិតិន្ទ្រិយនឹងកើតក្នុងទីជិតនៃមរណៈដោយអំណាចនៃឧបច្ឆេទកកម្ម។ បទថា **ជនិន្ទសេដ្ឋ** សេចក្ដីថា បពិត្រព្រះអង្គដែលប្រសើរជាងជន និងទេវតាទាំងឡាយ។

លំដាប់នោះ ស្ដេចសក្កៈពោលថា

**ន តាយុ ខីណំ មរណញ្ច ទូរេ,**
**ន ចាបិ មូឡ្ហោ នរវីរសេដ្ឋ;**
**តុយ្ហញ្ច បុញ្ញានិ បរិត្តកានិ,**
**យេសំ វិបាកំ ឥធ វេទយិត្ថោ។**

បពិត្រព្រះអង្គដ៏ប្រសើរ មានព្យាយាមជាងជន អាយុរបស់ព្រះអង្គមិនទាន់អស់ទេ ទាំងសេចក្ដីស្លាប់របស់ព្រះអង្គ (ក៏បិតនៅ) ក្នុងទីឆ្ងាយ មួយវិញទៀត ព្រះអង្គមិនមែនជាមនុស្សវង្វេងទេ តែថា ព្រះអង្គសោយនូវផលនៃបុណ្យណា ក្នុងទេវលោកនេះ បុណ្យរបស់ព្រះអង្គតិច។

**វស នេវានុភាវេន,**

**រាជសេដ្ឋ ទិសម្បតិ;**
**តាវតឹសេសុ ទេវេសុ,**
**កុញ្ជ កាមេ អមានុសេ។**

*បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គគង់នៅដោយទេវានុភាពចុះ សូមព្រះអង្គសោយនូវកាមទាំងឡាយ មិនមែនជារបស់មនុស្ស ក្នុងទេវលោកជាន់តាវត្តិង្សចុះ។*

*បណ្តាបទទាំងនោះ បទថា* **បរិត្តកានិ** *សេចក្តីថា សក្កទេវរាជពោលសំដៅយកបុណ្យទាំងឡាយដែលឲ្យវិបាក ក្នុងទេវលោកដោយអត្តភាពនោះ តែថាបុណ្យដទៃទៀតរបស់ព្រះបាទសាធិនៈច្រើនប្រមាណមិនបានបីដូចជាធូលីក្នុងផែនដី។ បទថា* **វស ទេវានុភាវេន** *សេចក្តីថា សក្កទេវរាជលួងលោមព្រះពោធិសត្វដោយពោលថា ខ្ញុំចែកបុណ្យទាំងឡាយពាក់កណ្តាលរបស់ខ្ញុំដល់ព្រះអង្គ សូមព្រះអង្គនៅដោយទេវានុភាពរបស់ខ្ញុំចុះ។*

*លំដាប់នោះ ព្រះមហាសត្វកាលហាមឃាត់ ទើបពោលថា*

យថា យាចិតកំ យានំ,
យថា យាចិតកំ ធនំ;
ឯវំសម្បទមេវេតំ,
យំ បរតោ ទានបច្ចយា។

*យានដែលខ្ចីគេ និងទ្រព្យដែលខ្ចីគេ មានឧបមា យ៉ាងណាមិញ ទ្រព្យណាដែលគេបាន ព្រោះបុគ្គលដទៃឲ្យ ជាបច្ច័យ ទ្រព្យនុ៎ះឯង ក៏មានឧបមេយ្យយ៉ាងនោះដែរ។*

ន ចាហមេតមិច្ឆាមិ,
យំ បរតោ ទានបច្ចយា;
សយំកតានិ បុញ្ញានិ,
តំ មេ អាវេណិកំ ធនំ។

*ទ្រព្យណាដែលគេបាន ព្រោះបុគ្គលដទៃឲ្យជា បច្ច័យ ខ្ញុំមិនចង់បានទ្រព្យនុ៎ះឡើយ បុណ្យទាំងឡាយ ដែលខ្ញុំបានធ្វើហើយដោយខ្លួនឯង បុណ្យនោះទុកជាទ្រព្យ របស់ខ្ញុំជាប់តាមខ្លួន។*

សោហំ គន្ត្វា មនុស្សេសុ,
កាហាមិ កុសលំ ពហុំ;

ទានេន សមចរិយាយ,
សំយមេន ទមេន ច;
យំ កត្វា សុខិតោ ហោតិ,
ន ច បច្ឆានុតប្បតិ។

ខ្ញុំនោះនឹងទៅធ្វើកុសលច្រើនក្នុងពួកមនុស្ស ដោយឲ្យទានផង កិរិយាប្រព្រឹត្តធម៌ស្មើផង កិរិយាសង្រួមដោយសីលផង កិរិយាទូន្មាននូវឥន្ទ្រិយផង ព្រោះថា បុគ្គលធ្វើកុសលហើយ រមែងដល់នូវសេចក្តីសុខ ទាំងមិនក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយ។

លំដាប់នោះ សក្កទេវរាជបានស្តាប់ពាក្យរបស់ព្រះរាជានោះហើយ ទើបបញ្ជាមាតលីថា "ម្នាលអ្នក ចូរទៅហើយនាំសាធិនរាជទៅកាន់ក្រុងមិថិលា ឲ្យស្តេចចុះក្នុងឧទ្យាន"។ ព្រះមាតលីក៏បានធ្វើយ៉ាងនោះ។ ព្រះរាជាយាងចង្រ្កមក្នុងឧទ្យាន។

គ្រានោះ នាយឧទ្យានបាល ឃើញព្រះរាជាហើយទូលសួរ រួចហើយក៏ទៅប្រាប់ដល់ព្រះបាទនារទៈ។ ព្រះបាទនារទៈនោះ ស្តាប់នូវការមករបស់ព្រះរាជាហើយ

ទ្រង់បញ្ជូនឧទ្យានបាលថា "អ្នកចូរទៅមុនចុះ ចូររៀបចំឧទ្យាន និងចាត់ចែងអាសនៈ ២ សម្រាប់យើង និងព្រះរាជាសាធិនៈ"។ នាយឧទ្យានបាលបានធ្វើយ៉ាងនោះ។

លំដាប់នោះ ព្រះរាជាសាធិនៈសួរឧទ្យានបាលថា "អ្នករៀបចំអាសនៈ ២ ដើម្បីអ្នកណា?"

ឧទ្យានបាលពោលថា "ដើម្បីព្រះអង្គ ១ ដើម្បីព្រះរាជារបស់ខ្ញុំ ១"។

ព្រះរាជាពោលថា "សត្វដទៃណា នឹងអង្គុយលើអាសនៈក្នុងសម្នាក់យើង" ដូច្នេះហើយ ទើបទ្រង់អង្គុយលើអាសនៈមួយ ហើយដាក់ព្រះបាទលើអាសនៈមួយ។

ព្រះបាទនារទៈយាងមកហើយ ថ្វាយបង្គំព្រះបាទរបស់ព្រះបាទសាធិនៈ រួចក៏អង្គុយនៅកន្លែងមួយ។ បានឮមកថា ព្រះបាទនារទៈនោះត្រូវជាចៅ (ជំនាន់) ទី ៧ របស់ព្រះបាទសាធិនៈ បានឮមកទៀតថា ក្នុងសម័យនោះ ជាកាលនៃមនុស្សដែលមានអាយុ ១០០ ឆ្នាំ។ ចំណែកព្រះមហាសត្វបានញ៉ាំងកាលដែលមានប្រមាណប៉ុណ្ណោះ ឲ្យកន្លងទៅ ដោយកម្លាំងបុណ្យរបស់ខ្លួន។ ព្រះពោធិសត្វ

*កាន់ដៃព្រះបាទនារទៈ ហើយត្រាច់ទៅក្នុងឧទ្យាន រួចក៏ពោល ៣ គាថា ថា*

**ឥមានិ តានិ ខេត្តានិ,**
**ឥមំ និក្ខំ សុកុណ្ឌលំ;**
**ឥមា តា ហរិតានូបា,**
**ឥមា នជ្ជោ សវន្តិយោ។**

*ស្រែទាំងឡាយនេះផង ទទឹកប្រកបដោយកុណ្ឌលដ៏ល្អនេះផង ផែនដីដ៏ដេរដាស ដោយស្មៅពណ៌ខៀវនេះផង ស្ទឹងទាំងឡាយដែលកំពុងហូរនេះផង។*

**ឥមា តា បោក្ខរណី រម្មា,**
**ចក្កវាកបកូជិតា;**
**មន្ទាលកេហិ សញ្ឆន្នា,**
**បទុមុប្បលកេហិ ច;**
**យស្សិមានិ មមាយិំសុ,**
**កឹ នុ តេ ទិសតំ គតា។**

*ស្រះបោក្ខរណីទាំងឡាយ ជាទីរីករាយ មានសត្វចាក្រពាកយំហើយ ដ៏ដេរដាសដោយចង្កុលណី ដោយ*

ផ្កាឈូក និងផ្កាឧប្បលនេះផង ពួកជនណា រាប់អានទូវទី
ទាំងឡាយនេះថាជារបស់អញ អស់ផងទាំងនោះ ទៅកាន់
ទិសណាហ្ន៎។

តានីធ ខេត្តានិ សោ ភូមិភាគោ,
តេយេវ អារាមវនូបចារា;
តមេវ មយ្ហំ ជនតំ អបស្សតោ,
សុញ្ញំវ មេ នារទ ខាយតេ ទិសា។

ម្នាលនារទៈ ស្រែទាំងឡាយ នៅជាស្រែទាំងនោះ
ដដែល ភូមិភាគនៅជាភូមិភាគដដែល ឧបចារៈនៃសួនច្បារ
ទាំងឡាយ ក៏នៅជាឧបចារៈនោះដដែល តែថាកាលយើង
មិនឃើញនូវជនទាំងនោះ ទិសប្រាកដដល់យើង ហាក់ដូច
ជាសូន្យឈឹង។

លំដាប់នោះ ព្រះបាទនារទៈពោលថា "បពិត្រព្រះ
សម្មតិទេព ឥឡូវនេះ ជា ៧០០ ឆ្នាំ នៃកាលដែលព្រះអង្គ
យាងទៅកាន់ទេវលោក ខ្ញុំត្រូវជាចៅជំនាន់ទី ៧ របស់ព្រះ
អង្គ ឧបដ្ឋាក និងអ្នករស់នៅក្នុងវាំងទាំងឡាយរបស់ព្រះ
អង្គ បានដល់មាត់នៃសេចក្ដីស្លាប់ នេះជារាជសម្បត្តិក្នុង

*សម្នាក់របស់ខ្លួនព្រះអង្គ សូមទ្រង់យាងសោយរាជ្យចុះ”។*

*ព្រះរាជាសាធិនៈ ពោលថា “ម្នាលថៅនាវទៈ យើងកាលមកក្នុងទីនេះ មិនមែនមកដើម្បីប្រយោជន៍ដល់រាជសម្បត្តិទេ យើងមកក្នុងទីនេះដើម្បីធ្វើបុណ្យ យើងនឹងធ្វើបុណ្យប៉ុណ្ណោះ” ដូច្នេះហើយ ទ្រង់ទើបពោលគាថាថា*

ទិដ្ឋា មយា វិមានានិ,
ឱភាសេន្តា ចតុទ្ទិសា;
សម្មុខា ទេវរាជស្ស,
តិទសានញ្ច សម្មុខា។

*វិមានទាំងឡាយ ញុំាងទិសទាំង ៤ ឲ្យភ្លឺចិញ្ចែង ចំពោះមុខទេវរាជផង ចំពោះមុខទេវតាជាន់ត្រៃត្រិង្សផង យើងបានឃើញហើយ។*

វុត្ថំ មេ ភវនំ ទិព្យំ,
ភុត្តា កាមា អមានុសា;
តាវតិំសេសុ ទេវេសុ,
សព្វកាមសមិទ្ធិសុ។

*ភពជាទិព្យយើងបាននៅរួចហើយ កាមទាំងឡាយ*

*មិនមែនជារបស់មនុស្ស យើងបានបរិភោគរួចហើយក្នុងពួកទេវតាជាន់តាវត្តិង្ស អាចសម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងបាន។*

សោហំ ឯតាទិសំ ហិត្វា,
បុញ្ញាយម្ហិ ឥធាគតោ;
ធម្មមេវ ចរិស្សាមិ,
នាហំ រជ្ជេន អត្ថិកោ។

*យើងនោះបានលះបង់សម្បត្តិទិព្យប្រាកដដូច្នោះហើយ មកក្នុងទីនេះ ដើម្បីធ្វើបុណ្យ យើងនឹងប្រព្រឹត្តធម៌តែម្យ៉ាង យើងមិនមានសេចក្តីត្រូវការដោយរាជសម្បត្តិទេ។*

អទណ្ឌាវចរំ មគ្គំ,
សម្មាសម្ពុទ្ធទេសិតំ;
តំ មគ្គំ បដិបជ្ជិស្សំ,
យេន គច្ឆន្តិ សុព្វតា។

*ព្រះពុទ្ធទាំងឡាយដែលមានវត្តល្អ ស្តេចយាងទៅតាមផ្លូវណា យើងនឹងដើរទៅតាមផ្លូវនោះ ដែលព្រះសម្មាសម្ពុទ្ធសំដែងហើយ ជាផ្លូវដែលបុគ្គលមិនមានអាជ្ញា*

គប្បីត្រាច់ទៅ។

ព្រះពោធិសត្វពោលគាថាទាំងឡាយនេះ ដាក់ចុះក្នុងសព្វញ្ញុតញ្ញាណ ដោយប្រការយ៉ាងនេះ។

**ព្រះបាទនារទៈពោលទៀតថា** "បពិត្រព្រះសម្មតិទេព សូមព្រះអង្គគ្រងរាជសម្បត្តិ"។

**ព្រះពោធិសត្វត្រាស់ថា** "នែចៅ យើងមិនត្រូវការដោយរាជសម្បត្តិ យើងទៅអស់កាល ៧០០ ឆ្នាំ ដូច្នេះយើងប្រាថ្នានឹងឲ្យទានដោយ ៧ ថ្ងៃ"។

ព្រះបាទនារទៈ ទទួលពាក្យរបស់ព្រះរាជានោះថា "សាធុ" ហើយ ឲ្យគេចាត់ចែងមហាទាន។

ព្រះរាជាសាធិនៈឲ្យទានអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់ក៏ធ្វើកាលកិរិយា ហើយកើតក្នុងភពត្រៃត្រិង្សនោះឯង។

## ជាតកភាវសាន

ព្រះសាស្តាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់សម្តែងថា "ឈ្មោះថាឧបោសថកម្ម គឺអ្នកទាំងឡាយគប្បីប្រកបយ៉ាងនេះ" ដូច្នេះហើយ ទើបព្រះអង្គប្រកាសសច្ចៈទាំងឡាយ និងប្រជុំជាតក ក្នុងកាលជាទីបញ្ចប់នៃ

សច្ចៈ បណ្តាឧបាសកទាំងឡាយដែលប្រកបដោយឧបោសថនោះ ពួកខ្លះតាំងនៅក្នុងសោតាបត្តិផល, ពួកខ្លះបានតាំងនៅក្នុងសកទាគាមិផល, ពួកខ្លះបានតាំងនៅក្នុងអនាគាមិផល។

**-តទា ជារទេរាជា សារិបុត្តោ អហោសិ**

ព្រះបាទនារទៈក្នុងកាលនោះបានមកជាព្រះសារីបុត្រ។

**-មាតលិ អានន្ទោ** មាតលីបានមកជាព្រះអានន្ទ។

**-សក្កោ អនុរុទ្ធោ** ស្តេចសក្កៈបានមកជាព្រះអនុរុទ្ធ។

**-សាធិនរាជា បន អហមេវ អហោសិំ**

ចំណែកព្រះបាទសាធិនរាជ គឺ**តថាគត**នេះឯង។

ចប់ សាធិនរាជជាតក ។

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បកិណ្ណកនិបាត បិដកលេខ ៦០ ទំព័រ ៤៤)

# ៣.គុត្តិលជាតក



ព្រះសាស្តា កាលស្តេចគង់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធទេវទត្ត បានត្រាស់ព្រះធម្មទេសនានោះ មានពាក្យថា "**សត្តតន្តឹ សុមធុរំ**" ដូច្នេះជាដើម។

សេចក្តីសង្ខេបថា ក្នុងកាលនោះ ភិក្ខុទាំងឡាយពោលនឹងទេវទត្តថា "នៃអាវុសោទេវទត្ត ព្រះសម្មាសម្ពុទ្ធជា

អាចារ្យរបស់លោក លោកអាស្រ័យព្រះសម្មាសម្ពុទ្ធ រៀនព្រះត្រៃបិដក ធ្វើឈានទាំង ៤ ឲ្យកើតឡើង ការដែលធ្វើខ្លួនឲ្យជាសត្រូវដល់លោកគ្រូអាចារ្យយ៉ាងនេះ មិនសមគួរឡើយ"។

ទេវទត្តពោលថា "នែអាវុសោទាំងឡាយ ព្រះសមណគោតមជាអាចារ្យរបស់ខ្ញុំឬ ព្រះត្រៃបិដកខ្ញុំរៀនដោយកម្លាំងខ្លួនឯងមិនមែនឬ ឈានទាំង ៤ ខ្ញុំក៏ធ្វើឲ្យកើតដោយកម្លាំងរបស់ខ្លួនទាំងអស់ មិនមែនឬ"។

ភិក្ខុទាំងឡាយអង្គុយសន្ទនាគ្នាក្នុងសាលាធម្មសភាថា "ម្នាលអាវុសោទាំងឡាយ ទេវទត្តអាស្រ័យព្រះសម្មាសម្ពុទ្ធជាអាចារ្យហើយ ត្រឡប់ជាសត្រូវនឹងព្រះអង្គបានដល់នូវសេចក្ដីវិនាសហើយ"។

ព្រះសាស្ដាយាងមកកាន់រោងធម្មសភា ទ្រង់ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយអង្គុយប្រជុំសន្ទនាគ្នា ដោយរឿងអ្វី?"

កាលភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ដោយរឿងនេះ"។

ទើបព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទេវទត្តមិនមែនបដិសេធអាចារ្យ ជាសត្រូវចំពោះតថាគត ហើយដល់នូវសេចក្តីវិនាសតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនក៏ដល់នូវសេចក្តីវិនាសដែរ" ហើយទ្រង់នាំយករឿងក្នុងអតីតមកសម្តែងដូចតនេះ

ក្នុងអតីតកាល ព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិនៅក្នុងនគរពារាណសី ព្រះបរមពោធិសត្វបដិសន្ធិក្នុងត្រកូលអ្នកចម្រៀង។ មាតាបិតាដាក់ឈ្មោះឲ្យថា **គុត្តិល-កុមារ**។

គុត្តិលកុមារនោះ លុះចម្រើនវ័យហើយ សម្រេចសិល្បៈផ្នែកខាងចម្រៀង បានជាអ្នកច្រៀងដ៏កំពូល ក្នុងជម្ពូទ្វីបទាំងមូល ប្រាកដឈ្មោះថា **គុត្តិលគន្ធព្វ**។ កុមារនោះ មិនមានភរិយា ចិញ្ចឹមមាតាបិតាដែលងងឹតភ្នែក។ ក្នុងកាលនោះ ពួកឈ្មួញអ្នកនគរពារាណសីទៅជួញឯក្រុងឧជ្ជេនី កាលគេប្រកាសថា "មានមហោស្រព ទើបរៃអង្គាសគ្នា រកផ្កាឈើ គ្រឿងក្រអូប គ្រឿងលាប និងគ្រឿងបរិភោគជាដើមយ៉ាងច្រើន" ប្រជុំគ្នានៅក្នុងទីលានកីឡា ឲ្យ

ថ្ងៃឈ្នួលហើយពោលថា "អ្នកទាំងឡាយ ចូរនាំអ្នកចម្រៀងម្នាក់មកចុះ"។

ក្នុងសម័យនោះ ក្រុងឧជ្ជេនីមានអ្នកចម្រៀងដ៏ល្បីម្នាក់ ឈ្មោះ **មុសិលៈ**។ ពួកឈ្មួញក៏យកបុរសនោះមកឲ្យសម្ដែងនិងច្រៀងឲ្យខ្លួនស្ដាប់។ មុសិលៈនោះមុននឹងដេញពិណ ក៏តម្លើងខ្សែសំឡេងឯកហើយទើបដេញ ការដេញរបស់មុសិលៈនោះ បានប្រាកដដូចសំឡេងអេះកន្ទេលផែងដល់ពួកឈ្មួញទាំងនោះ ព្រោះពួកឈ្មួញទាំងនោះ ជាអ្នកធ្លាប់ត្រចៀកក្នុងការស្ដាប់សំឡេងពិណរបស់គុត្តិលគន្ធព្វ ទើបមិនបានសម្ដែងការពេញចិត្តសូម្បីតែម្នាក់។

មុសិលៈនោះ កាលពួកឈ្មួញទាំងនោះ មិនសម្ដែងអាការពេញចិត្តសូម្បីតែម្នាក់ ក៏គិតថា "ប្រហែលជាអញដេញពិណតឹងពេកទេដឹង" ទើបបន្ថយសំឡេងចុះមកពាក់កណ្ដាល ដេញដោយសំឡេងពាក់កណ្ដាល។

ឈ្មួញទាំងនោះក៏នៅតែមិនយកចិត្តទុកដាក់នឹងសំឡេងពិណនោះ។ ពេលនោះ មុសិលៈនោះគិតថា "ឈ្មួញទាំងនេះគង់មិនដឹងអ្វី" ទើបក្លែងធ្វើជាមិនដឹងរឿង

ខ្លួនឯង ដេញពិណាដោយខ្សែធូរៗ។ ពួកឈ្មួញក៏មិនបានថា អ្វីៗ មុសិលៈនោះក៏ពោលនឹងឈ្មួញទាំងនោះថា "នែអ្នកឈ្មួញដ៏ចម្រើន កាលខ្ញុំដេញពិណា ពួកលោកមិនពេញចិត្តឬ?"

**ឈ្មួញទាំងនោះពោលថា** "តើអ្នកដេញពិណាអ្វី ពួកយើងមិនយល់ថា អ្នកតម្លើងសំឡេងពិណាដេញទេ"។

**មុសិលៈសួរថា** "តើពួកលោកស្គាល់អាចារ្យដែលពូកែជាងខ្ញុំឬ បានមិនត្រេកអរ ព្រោះខ្លួនមិនចេះស្ដាប់?"

**ឈ្មួញទាំងនោះពោលថា** "ពួកយើងធ្លាប់ស្ដាប់សំឡេងពិណារបស់គុត្តិលគន្ធព្វ ឯនគរពារាណសី សំឡេងពិណារបស់គាត់ គេស្ដាប់ទៅដូចសំឡេងស្ត្រីបំពេកូន"។

**មុសិលៈពោលថា** "បើដូច្នោះ ចូរលោកយកប្រាក់របស់លោកទៅវិញចុះ ខ្ញុំមិនត្រូវការទេ ប៉ុន្តែកាលលោកត្រឡប់ទៅកាន់នគរពារាណសីជួយនាំខ្ញុំទៅផង"។

**ពួកឈ្មួញពោលថា** "ប្រពៃហើយ ពួកខ្ញុំយល់ព្រម"។

ពេលត្រឡប់ទៅវិញ បាននាំមុសិលៈនោះទៅកាន់នគរពារាណសី ហើយប្រាប់ថា "នេះគឺលំនៅរបស់គុត្តិល-

គន្ធព្វ”។ មុសិលៈក៏ដើរទៅកាន់ផ្ទះ របស់ព្រះបរម-ពោធិសត្វ ឃើញពិណរបស់ព្រះបរមពោធិសត្វ ក៏ចាប់យកមកដេញ ។

ពេលនោះ មាតាបិតារបស់ព្រះមហាសត្វមើលមិនឃើញមុសិលៈព្រោះភ្នែកងងឹត គិតថា “ប្រហែលជាកណ្ដុរមកកាត់ពិណហើយមើលទៅ” ទើបពោលថា “កណ្ដុរកាត់ខ្សែពិណ”។

មុសិលៈក៏ដាក់ពិណចុះហើយថ្វាយបង្គំមាតាបិតារបស់ព្រះមហាសត្វ។

**មាតាបិតារបស់ព្រះពោធិសត្វសួរថា** “អ្នកមកអំពីណា?”

**មុសិលៈឆ្លើយថា** “ខ្ញុំមកអំពីក្រុងឧជ្ជេនី ដើម្បីសូមរៀនសិល្បៈក្នុងសម្នាក់អាចារ្យ”។

**មាតាបិតារបស់ព្រះពោធិសត្វទទួលថា** “ល្អហើយ”។

**មុសិលៈសួរថា** “លោកអាចារ្យទៅណា?” កាលបានស្ដាប់ថា “មិននៅទេ ប៉ុន្តែថ្ងៃនេះ ត្រឡប់មកវិញហើយ” ទើបគេអង្គុយនៅទីនោះ។ កាលព្រះពោធិសត្វត្រឡប់មក

បានទទួលបដិសណ្ឋារៈហើយ ក៏ប្រាប់ហេតុដែលខ្លួនមក។

ចំណែកព្រះពោធិសត្វចេះវិជ្ជាទាយលក្ខណៈមនុស្ស ដឹងថា "មុសិលៈនេះជាអសប្បុរស" ក៏បដិសេធថា "នែអ្នកដ៏ចម្រើន អ្នកទៅចុះ សិល្បៈមិនមានដល់អ្នកទេ"។

មុសិលៈចាប់ជើងមាតាបិតារបស់ព្រះពោធិសត្វប្របាច់ថ្នមៗ ឲ្យអាណិតខ្លួន ហើយអង្វរថា "សូមលោកទាំងពីរជួយឲ្យលោកអាចារ្យចែកសិល្បៈដល់ខ្ញុំផង"។

ព្រះពោធិសត្វត្រូវមាតាបិតាអង្វររឿយៗ មិនអាចជំទាស់ ទើបព្រមបង្រៀនសិល្បៈដល់មុសិលៈ។

មុសិលៈនោះទៅព្រះរាជនិវេសន៍ជាមួយនឹងព្រះពោធិសត្វ។

**ព្រះរាជាទតឃើញ ក៏ត្រាស់សួរថា** "បុរសនេះជាអ្នកណា លោកអាចារ្យ?"

**ព្រះពោធិសត្វក្រាបទូលថា** "បពិត្រមហារាជ បុរសនេះជាអន្តេវាសិករបស់ទូលបង្គំ"។

មុសិលៈក៏បានស្និទ្ធស្នាលជាមួយនឹងព្រះរាជាដោយលំដាប់។

ឯព្រះពោធិសត្វមិនបានបិទបាំងលាក់លៀមវិជ្ជា ឲ្យមុសិលៈនោះសិក្សាតាមបែបដែលខ្លួនចេះមករហូតដល់ចប់ ហើយពោលថា "នែអ្នកដ៏ចម្រើន អ្នករៀនសិល្បៈចប់ហើយ"។

មុសិលៈគិតថា "សិល្បៈ អញរៀនចប់ហើយ ទាំងនគរពារាណសីនេះ ក៏ជានគរធំជាងគេនៅក្នុងជម្ពូទ្វីប ប្រសិនបើអាចារ្យរបស់អញចាស់ អញគួរនៅក្នុងនគរពារាណសីនេះឯង"។ មុសិលៈប្រាប់អាចារ្យថា "បពិត្រលោកអាចារ្យ ខ្ញុំនឹងទទួលការងាររាជការ"។

**ព្រះពោធិសត្វពោលថា** "ប្រពៃហើយ យើងនឹងក្រាបទូលព្រះរាជា" ហើយនាំមុសិលៈនោះទៅគាល់ព្រះរាជា រួចក្រាបទូលថា "បពិត្រមហារាជ អន្តេវាសិករបស់ទូលបង្គំចង់ទទួលរាជការបម្រើព្រះអង្គ សូមទ្រង់ពិចារណាបៀវត្សឲ្យគេ"។

**កាលព្រះរាជាប្រាប់ថា** "បុរសនោះនឹងបានពាក់កណ្តាលអំពីបៀវត្សដែលអ្នកបាន" ទើបប្រាប់រឿងនោះដល់មុសិលៈ។

***មុសិលៈពោលថា*** *"កាលខ្ញុំបានបៀវត្សស្មើនឹងលោកអាចារ្យ ទើបខ្ញុំទទួលរាជការ កាលមិនបានស្មើ នឹងមិនទទួល"។*

***ព្រះពោធិសត្វសួរថា*** *"ព្រោះហេតុអ្វី?"*

***មុសិលៈពោលថា*** *"ខ្ញុំចេះសិល្បៈដែលលោកចេះទាំងអស់ មិនមែនឬ ?"*

***ព្រះពោធិសត្វពោលថា*** *"ត្រូវហើយ អ្នកចេះទាំងអស់"។*

***មុសិលៈពោលថា*** *"បើដូច្នោះ ព្រោះហេតុអ្វីទើបព្រះរាជាព្រះរាជទានបៀវត្សដល់ខ្ញុំ តែពាក់កណ្តាល"។*

*ព្រះពោធិសត្វក៏ក្រាបទូលរឿងនោះដល់ព្រះរាជា។*

***ព្រះរាជាត្រាស់ថា*** *"ប្រសិនបើអន្តេវាសិករបស់អ្នកអាចសម្តែងសិល្បៈស្មើនឹងអ្នក ក៏នឹងបានស្មើគ្នា"។*

*ព្រះពោធិសត្វឮដូច្នោះហើយក៏ប្រាប់មុសិលៈ កាលមុសិលៈនោះពោលថា "ប្រពៃហើយខ្ញុំនឹងសម្តែង" ទើបក្រាបទូលព្រះរាជា។*

***ព្រះរាជាត្រាស់ថា*** *"ប្រពៃហើយ ចូរសម្តែងចុះ តើ*

អ្នកនឹងសម្តែងប្រឡងប្រណាំងក្នុងថ្ងៃណា ?"

**ព្រះពោធិសត្វក្រាបទូលថា** "បពិត្រមហារាជ ទូលបង្គំនឹងសម្តែងប្រឡងប្រណាំងក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះទៅ"។

**ព្រះរាជាបានឲ្យហៅមុសិលៈមក ហើយត្រាស់សួរថា** "បានឮថា អ្នកនឹងធ្វើការប្រឡងប្រណាំងជាមួយនឹងអាចារ្យឬ ?"

**មុសិលៈក្រាបទូលថា** "បពិត្រព្រះសម្មតិទេព ពិតមែន"។

**សូម្បីព្រះរាជាទ្រង់ហាមឃាត់ថា** "ការប្រឡងប្រណាំងជាមួយនឹងអាចារ្យមិនសមគួរឡើយ"។

មុសិលៈនោះ ក៏នៅតែក្រាបទូលថា "ណ្ហើយចុះព្រះសម្មតិទេព ទុកឲ្យទូលបង្គំប្រឡងជាមួយនឹងអាចារ្យក្នុងថ្ងៃទី ៧ ចុះ នឹងបានដឹងថា អ្នកណាឈ្នះ"។

**ព្រះរាជាត្រាស់ថា** "បើដូច្នោះ ប្រពៃហើយ" ហើយទ្រង់បញ្ជាឲ្យវាយស្គរប្រកាសថា "ក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះ អាចារ្យនិងសិស្ស នឹងសម្តែងសិល្បៈប្រឡងប្រណាំងគ្នានៅ

ត្រង់ខ្លោងទ្វារព្រះរាជវាំង អ្នកនគរចូរមកមើលការប្រឡងប្រណាំងគ្នាចុះ"។

**ព្រះមហាសត្វគិតថា** "មុសិលៈនេះ នៅកំលោះមានកម្លាំងខ្លាំង ចំណែកអញចាស់ថយកម្លាំង ធម្មតាកិរិយារបស់មនុស្សចាស់រមែងមិនស្វាហាប់ ម្យ៉ាងទៀត កាលកូនសិស្សចាញ់ក៏មិនប្លែកអ្វីឡើយ តែបើកូនសិស្សឈ្នះវិញ (អញមុខតែវិនាស) អញចូលទៅស្លាប់ក្នុងព្រៃប្រសើរជាង"។

ព្រះពោធិសត្វចូលទៅក្នុងព្រៃ ហើយក៏ត្រឡប់វិញព្រោះខ្លាចស្លាប់ ហើយត្រឡប់ទៅព្រៃវិញទៀត ព្រោះខ្លាចខ្មាសគេ, កាលព្រះមហាបុរសដើរទៅត្រឡប់មកយ៉ាងនេះថ្ងៃក៏កន្លងទៅបាន ៦ ថ្ងៃ ស្មៅរាបក្លាយជាស្នាមផ្លូវ។

ពេលនោះ ភពរបស់សក្កទេវរាជក៏សម្តែងអាការក្តៅ សក្កទេវរាជពិចារណាមើល ក៏បានដឹងហេតុការណ៍នោះ ទើបត្រិះរិះថា "គុត្តិលគន្ធព្វបានទទួលទុក្ខធំក្នុងព្រៃព្រោះខ្លាចអន្តេវាសិក អញគួរជាទីពឹងរបស់គុត្តិលៈនោះ" ទើបប្រញាប់យាងទៅឈរខាងមុខហើយត្រាស់សួរថា "នៃអាចារ្យ អ្នកចូលព្រៃធ្វើអ្វី ?"

ព្រះពោធិសត្វសួរថា "លោកជាអ្នកណា ?"

សក្កទេវរាជត្រាស់ថា "ខ្ញុំជាសក្កទេវរាជ"។

ពេលនោះ ព្រះពោធិសត្វក៏ទូលសក្កទេវរាជថា "បពិត្រទេវរាជ ខ្ញុំចូលព្រៃយ៉ាងនេះ ក៏ព្រោះខ្លាចចាញ់អន្តេវាសិក" ហើយពោលគាថាទី ១ ថា

សត្តតន្តិំ សុមធុរំ,
រាមណេយ្យំ អវាចយឹ;
សោ មំ រង្គម្ហិ អវ្ហេតិ,
សរណំ មេ ហោតិ កោសិយ។

បពិត្រព្រះឥន្ទ្រកោសិយ ខ្ញុំបាន (ញុំាងសិស្សឈ្មោះមុសិលៈ) ឲ្យរៀននូវពិណមានខ្សែ ៧ មានសំឡេងពីរោះ ជាទីរីករាយនៃចិត្ត (ឥឡូវនេះ) សិស្ស ឈ្មោះមុសិលៈនោះ ហៅខ្ញុំក្នុងកណ្តាលរង្គមណ្ឌល (កន្លែងរាំ) សូមព្រះអង្គជាទីពឹងនៃខ្ញុំ។

សក្កទេវរាជស្តាប់ពាក្យរបស់ព្រះពោធិសត្វហើយ ត្រាស់ថា "កុំខ្លាចឡើយ ខ្ញុំនឹងជួយតតាំងការពារលោក" ហើយពោលគាថាទី ២ ថា

អហំ តំ សរណំ សម្ម,
អហមាចរិយបូជកោ;
ន តំ ជយិស្សតិ សិស្សោ,
សិស្សមាចរិយ ជេស្សសិ។

ម្នាលសម្លាញ់ ខ្ញុំនឹងជាទីពឹងរបស់អ្នក ខ្ញុំជាអ្នកបូជានូវអាចារ្យ សិស្សនឹងមិនឈ្នះអ្នក បពិត្រអាចារ្យ អ្នកនឹងឈ្នះនូវសិស្សវិញ។

សក្កទេវរាជត្រាស់ថា "កាលអ្នកដេញពិណ ចូរអ្នកផ្តាច់ខ្សែពិណាមួយ ដេញខ្សែ៦ សំឡេងពិណារបស់អ្នកនឹងដូចដើម សូម្បីមុសិលៈក៏នឹងផ្តាច់ខ្សែពិណាដែរ ប៉ុន្តែសំឡេងពិណារបស់មុសិលៈនោះនឹងមិនដូចដើម ពេលនោះ បុរសនោះនឹងដល់នូវការបរាជ័យ លុះដឹងថា បុរសនោះដល់នូវការបរាជ័យហើយ អ្នកគប្បីផ្តាច់ខ្សែទី២ ខ្សែទី៣ ខ្សែទី៤ ខ្សែទី៥ ខ្សែទី៦ ខ្សែទី៧ ដេញតែដងពិណាទទេ សំឡេងនឹងចេញអំពីកំណួចខ្សែពិណាដែលផ្តាច់ចោលនោះ លាន់ឮទូទៅពេញនគរពារាណសីទាំង ១២ យោជន៍"។ សក្កទេវរាជត្រាស់ដូច្នេះហើយ ក៏ប្រទានចិញ្ចៀន ៣ វង់ដល់ព្រះ

ពោធិសត្វ ហើយត្រាស់ថា "កាលសំឡេងពិណរបស់អ្នក លាន់ឮទូទាំងនគរហើយ អ្នកចូរបោះចិញ្ចៀន ១ វង់អំពីចំនួននេះ ទៅលើអាកាស ពេលនោះ ស្រីទេពអប្សរ ៣០០ នឹងចុះមករាំខាងមុខអ្នក ក្នុងពេលដែលស្រីអប្សរកំពុងរាំនោះ អ្នកគប្បីបោះចិញ្ចៀនទី ២ ទៅទៀត ស្រីទេពអប្សរ ៣០០ ទៀត នឹងចុះមករាំខាងមុខពិណរបស់អ្នកទៀត បន្ទាប់អំពីនោះ អ្នកគប្បីបោះចិញ្ចៀនទី ៣ ទៅទៀត ពេលនោះស្រីទេពអប្សរ ៣០០ ទៀតនឹងចុះមករាំលើកន្ទេងរាំ សូម្បីខ្ញុំក៏នឹងទៅរកអ្នកដែរ ដូច្នេះ ចូរអ្នកទៅចុះ កុំខ្លាចឡើយ"។

លុះព្រឹកឡើង ព្រះពោធិសត្វក៏ត្រឡប់មកផ្ទះវិញ។ ពួកអ្នកនគរធ្វើមណ្ឌបនៅជិតខ្លោងទ្វារព្រះរាជវាំង តាក់តែងទីប្រថាប់សម្រាប់ព្រះរាជា។ ព្រះរាជាស្ដេចចុះអំពីប្រាសាទហើយទ្រង់គង់លើបល្ល័ង្កនៅក្នុងរង្គមណ្ឌបដែលតាក់តែងហើយ។ ស្ត្រីដែលប្រដាប់តាក់តែងហើយ ១ ម៉ឺន ២ ពាន់ និងអាមាត្យ ព្រាហ្មណ៍ អ្នកដែនជាដើម មកគាល់ណែនណាន់តាន់តាប់។ អ្នកនគរក៏ប្រជុំគ្នាក្នុងលានព្រះ

រាជវាំង យករថតម្រួតលើរថ យកគ្រែតម្រួតលើគ្រែ។

ឯព្រះពោធិសត្វង្ងូតទឹកជម្រះកាយហើយ បរិភោគអាហារដែលមានរសប្រណីតផ្សេងៗ ហើយកាន់ពិណទៅអង្គុយលើអាសនៈសម្រាប់ខ្លួន។ សក្កទេវរាជមកឋិតនៅលើអាកាសដោយមិនប្រាកដកាយ។ ព្រះពោធិសត្វតែម្នាក់ប៉ុណ្ណោះដែលអាចមើលឃើញសក្កទេវរាជ។

ចំណែកមុសិលៈក៏មកអង្គុយលើអាសនៈរបស់ខ្លួនដែរ។ មហាជនចោមរោមហើយ។ ជនទាំងពីរក៏ដេញពិណតាំងអំពីដើមស្មើគ្នា។ មហាជនស្រែកហ៊ោត្រេកអររីករាយដោយការដេញពិណនៃអ្នកទាំងពីរ។ សក្កទេវរាជឋិតនៅលើអាកាស ប្រាប់ឲ្យឮតែព្រះពោធិសត្វម្នាក់ប៉ុណ្ណោះថា "ចូរអ្នកផ្ដាច់ខ្សែពិណទី១ ចេញ"។

ព្រះពោធិសត្វផ្ដាច់ខ្សែពិណទី១ ចោល សូម្បីផ្ដាច់ខ្សែទី១ ចេញហើយក៏ដោយ សំឡេងក៏នៅតែឮចេញអំពីកំណួច ដែលដាច់ហើយនោះ បីដូចជារបស់ទេពគន្ធព្វដូច្នោះ ឯមុសិលៈក៏ផ្ដាច់ខ្សែពិណខ្លះចោលដែរ ប៉ុន្តែសំឡេងមិនឮចេញមកទេ។

ព្រះពោធិសត្វបានផ្តាច់ខ្សែទី២ ទី៣ ទី៤ ទី៥ ទី៦ ទី៧។ កាលដេញតែជង់ពិណទទេ សំឡេងបានលាន់ឮពេញនគរ។ សម្រែកហ៊ោបានប្រព្រឹត្តទៅហើយ។ ព្រះពោធិសត្វបានបោះចិញ្ចៀនវង់ទី១ ទៅលើអាកាស ក្នុងពេលនោះស្រីទេពអប្សរ ៣០០ បានចុះមករាំ កាលបោះវង់ទី២ និង ទី៣ ទៅទៀត មានទេពអប្សរ ៩០០ បានចុះមករាំតាមន័យដូចពោលហើយនោះ។

កាលព្រះរាជាឲ្យសញ្ញាដល់មហាជន មហាជនក៏នាំគ្នាក្រោកឡើងគំរាមដល់មុសិលៈថា "អ្នកប្រឡងប្រណាំងនឹងអាចារ្យ ព្យាយាមធ្វើអាការស្មើនឹងអាចារ្យ អ្នកមិនស្គាល់ប្រមាណខ្លួន" គប់វាយដោយដុំដី ដុំថ្មនិងដំបងជាដើម តាមចាប់យកមក ឲ្យដល់នូវសេចក្តីស្លាប់ ហើយចាប់ជើងអូសយកទៅចោលនៅលើគំនរសំរាម។ ព្រះរាជាមានព្រះទ័យត្រេកអរ ព្រះរាជទានទ្រព្យជាច្រើនដល់ព្រះពោធិសត្វ ដូចភ្លៀងព្រឹលធ្លាក់ចុះមកដូច្នោះ។ អ្នកនគរក៏យ៉ាងនោះដែរ។

សក្កទេវរាជទ្រង់ធ្វើបដិសណ្ឋារៈនឹងព្រះពោធិសត្វថា "នែបណ្ឌិត ខ្ញុំនឹងឲ្យមាតលិទេវសារថីយករថទឹមដោយ

សេះអាជានេយ្យ១ពាន់ មកទទួលអ្នកនៅពេលខាងក្រោយ អ្នកគប្បីឡើងកាន់វេជយន្តរថដែលទឹមដោយសេះ១ពាន់ ទៅកាន់ទេវលោកចុះ" លុះត្រាស់ដូច្នេះហើយ ទ្រង់ក៏ត្រឡប់ទៅកាន់ទេវលោកវិញ។

គ្រានោះ ទេពធីតាទាំងឡាយក៏សួរសក្កទេវរាជដែលយាងមកដល់ហើយគង់លើបណ្ឌុកម្ពលសិលាសនៈថា "បពិត្រទេវរាជ ព្រះអង្គយាងទៅណា ទើបតែមក ?"

សក្កទេវរាជក៏ត្រាស់ប្រាប់ហេតុការណ៍នោះ ឲ្យពួកទេពធីតាស្តាប់ដោយពិស្តារហើយ ពណ៌នាសីលនិងគុណរបស់ព្រះពោធិសត្វ។

**ពួកទេពធីតាក្រាបទូលថា** "បពិត្រមហារាជ សូម្បីពួកខ្ញុំម្ចាស់ ក៏ប្រាថ្នាឃើញអាចារ្យនោះដែរ"។

**សក្កទេវរាជហៅមាតលិទេវបុត្តមកត្រាស់ថា** "នែបាទេពអប្សរ ចង់ឃើញគុត្តិលគន្ធព្វ អ្នកចូរទៅ ឲ្យគុត្តិល-គន្ធព្វនោះអង្គុយលើវេជយន្តរថហើយនាំមកទីនេះចុះ"។

មាតលិទេវបុត្តទទួលទេវឱង្ការហើយ ទៅនាំព្រះពោធិសត្វ។

សក្កទេវរាជទ្រង់រីករាយជាមួយនឹងព្រះពោធិសត្វ ហើយត្រាស់ថា "នៃអាចារ្យ ពួកទេពកញ្ញាប្រាថ្នានឹងស្តាប់ការលេងភ្លេងរបស់អ្នក"។

**ព្រះពោធិសត្វក្រាបទូលថា** "បពិត្រមហារាជ ខ្ញុំជាគន្ធព្វចិញ្ចឹមជីវិតអាស្រ័យសិល្បៈ កាលបានថ្លៃឈ្នួល ទើបសម្តែង"។

**សក្កទេវរាជត្រាស់ថា** "ចូរសម្តែងចុះ ខ្ញុំនឹងឲ្យថ្លៃឈ្នួល"។

**ព្រះពោធិសត្វក្រាបទូលថា** "ខ្ញុំមិនត្រូវការថ្លៃឈ្នួលយ៉ាងដទៃទេ សូមឲ្យតែស្រីទេពអប្សរទាំងនេះ ប្រាប់កល្យាណកម្មរបស់ខ្លួនដល់ខ្ញុំចុះ បើយ៉ាងនេះខ្ញុំនឹងលេងភ្លេងឲ្យស្តាប់"។

**គ្រានោះ ទេពធីតាទាំងនោះ បានពោលនឹងព្រះពោធិសត្វថា** "ពួកខ្ញុំនឹងប្រាប់កល្យាណកម្មរបស់ពួកខ្ញុំជាខាងក្រោយ សូមលោកអាចារ្យលេងភ្លេងមុនចុះ"។

ព្រះពោធិសត្វលេងភ្លេងឲ្យពួកទេវតាស្តាប់អស់ ៧ ថ្ងៃ សំឡេងនោះពីរោះលាន់រំពងជាងពិណទិព្វទៅទៀត។

លុះគ្រប់ ៧ ថ្ងៃ ព្រះមហាសត្វក៏ផ្ដើមសួរទេពធីតាទាំងឡាយអំពីកល្យាណកម្ម។

ទេពធីតាមួយអង្គ បានប្រគេនសំពត់យ៉ាងល្អដល់ភិក្ខុមួយអង្គក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ទើបបានមកកើតជាបាទបរិចារិការបស់សក្កទេវរាជ មានស្រីទេពអប្សរ ១ ពាន់ជាបរិវារ។

ព្រះពោធិសត្វក៏សួរទេពកញ្ញាដែលទ្រទ្រង់ពស្ត្រាភរណៈដ៏ប្រសើរថា "កាលពីជាតិមុននាងបានធ្វើកម្មអ្វីទុក?"

កាលដែលព្រះពោធិសត្វសួរនឹងទេពកញ្ញាដែលឆ្លើយនោះ បានមានមកហើយក្នុង**វិមានវត្ថុ**នោះឯង។ សេចក្ដីក្នុងវិមានវត្ថុនោះ ព្រះពោធិសត្វសួរថា

អភិក្កន្តេន វណ្ណេន,
យា ត្វំ តិដ្ឋសិ ទេវតេ;
ឱភាសេន្តី ទិសា សព្វា,
ឱសធី វិយ តារកា។
កេន តេតាទិសោ វណ្ណោ,

កេន តេ ឥធ មិជ្ឈតិ;
ឧប្បជ្ជន្តិ ច តេ ភោគា,
យេ កេចិ មនសោ បិយា។
បុច្ឆាមិ តំ ទេវិ មហានុភាវេ,
មនុស្សភូតា កិមកាសិ បុញ្ញំ;
កេនាសិ ឯវំ ជលិតានុភាវា,
វណ្ណោ ច តេ សព្វទិសា បភាសតិ។

*ម្នាលទេវតា នាងមានសម្បុរដ៏រុងរឿង ញ៉ាំងទិសទាំងពួងឲ្យភ្លឺ ដូចផ្កាយព្រឹក សម្បុររបស់នាងបែបនោះ តើសម្រេចដោយបុណ្យដូចម្តេច ផលសម្រេចដល់នាង ក្នុងទីនេះផង ភោគៈទាំងឡាយណានីមួយ ជាទីគាប់ចិត្ត ភោគៈទាំងនោះ ក៏កើតឡើងដល់នាងផង តើដោយហេតុដូចម្តេច?*

*ម្នាលទេវតា មានអានុភាពច្រើន ខ្ញុំសូមសួរនាង នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច នាងមានអានុភាពរុងរឿងយ៉ាងនេះ ទាំងសម្បុររបស់នាង ក៏ភ្លឺច្បាស់សព្វទិស តើដោយបុណ្យដូចម្តេច?*

*ទេពធីតានោះ ឆ្លើយថា*

វត្ថុត្តមទាយិកា នារី,
បវរា ហោតិ នរេសុ នារីសុ;
ឯវំ បិយរូបទាយិកា មនាបំ,
ទិព្វំ សា លភតេ ឧបេច្ច ឋានំ។
តស្សា មេ បស្ស វិមានំ,
អច្ឆរា កាមវណ្ណិនីហមស្មិ;
អច្ឆរាសហស្សស្សាហំ,
បវរា បស្ស បុញ្ញានំ វិបាកំ។
តេន មេតាទិសោ វណ្ណោ,
តេន មេ ឥធ មិជ្ឈតិ;
ឧប្បជ្ជន្តិ ច មេ ភោគា,
យេ កេចិ មនសោ បិយា។
តេនម្ហិ ឯវំ ជលិតានុភាវា;
វណ្ណោ ច មេ សព្វទិសា បភាសតិ។

*នារីឲ្យនូវសំពត់ដ៏ឧត្តម ជាស្ត្រីប្រសើរជាងជនប្រុស ស្រីទាំងឡាយ នារីនោះ ជាស្ត្រីឲ្យនូវវត្ថុមានសភាពជាទី*

ស្រឡាញ់ទើបទៅកាន់ឋាន មានវិមានជាដើម បាននូវរបស់ទិព្វ ជាទីគាប់ចិត្តយ៉ាងនេះ សូមលោករមិលមើលនូវវិមានរបស់ខ្ញុំនោះចុះ ខ្ញុំជាស្ត្រីអប្សរមានសម្បុរ ជាទីប្រាថ្នា ខ្ញុំជាស្រីប្រសើរជាងស្ត្រីអប្សរទាំងមួយពាន់ សូមលោកមើលនូវផលនៃបុណ្យទាំងឡាយ ព្រោះហេតុនោះ បានជាសម្បុររបស់ខ្ញុំប្រាកដដូច្នោះ។បេ។ ទាំងសម្បុររបស់ខ្ញុំ ក៏ភ្លឺច្បាស់សព្វទិស។

-ទេពធីតាមួយអង្គទៀត បានឲ្យនូវផ្កាដ៏ឧត្តមចំពោះភិក្ខុអ្នកត្រាច់បិណ្ឌបាតជាវត្តមួយរូប។

-ទេពធីតាមួយអង្គទៀត កាលគេប្រាប់ថា សូមអ្នកទាំងឡាយប្រគេនគ្រឿងក្រអូបដ៏ឧត្តម។

-មួយអង្គទៀតបានប្រគេនផ្លែឈើមានរសដ៏ឧត្តម។

-មួយអង្គទៀត បានប្រគេនអាហារមានរសដ៏ឧត្តម។

-មួយអង្គទៀត បានប្រគេនគ្រឿងប្រោះព្រំ មានក្លិនក្រអូបលើស្តូបនៃព្រះមានព្រះភាគទ្រង់ព្រះនាមកស្សបៈ។

-មួយអង្គទៀត បានឃើញនូវពួកភិក្ខុនិងពួកភិក្ខុនីដើរទៅកាន់ផ្លូវ បានស្តាប់ធម៌របស់ភិក្ខុនីទាំងឡាយនោះ

ហើយរក្សាឧបោសថអស់មួយថ្ងៃ។

-មួយអង្គទៀត ឈរក្នុងទឹកមានចិត្តជ្រះថ្លាបាន ប្រគេនទឹកដល់ភិក្ខុអ្នកឆាន់ចង្ហាន់លើទូក។

-មួយអង្គទៀត កាលនៅគ្រប់គ្រង់ផ្ទះមិនច្រើនទៅ ដោយសេចក្តីក្រោធ។

-មួយអង្គទៀត មិនមានសេចក្តីប្រណែន បានបម្រើម្តាយក្មេកនិងឪពុកក្មេកដែលកាចផង ខឹងច្រើនផង អាក្រក់ផង បែងចំណែកដែលខ្លួនបានចេញ ចែកចាយជាមុន ទើបបរិភោគទាំងជាអ្នកមិនប្រមាទក្នុងសីលរបស់ខ្លួន។

-មួយអង្គទៀត ជាទាសីធ្វើការបម្រើជនដទៃ ជាអ្នកមិនខ្ជិលច្រអូស ក្នុងកិច្ចការទាំងពួង ជាស្ត្រីមិនមានសេចក្តីក្រោធ មិនមើលងាយគេ ជាអ្នកចែករំលែកនូវចំណែករបស់ខ្លួនដល់ជនអ្នកត្រូវការ ទើបបានមកកើតជាបាទបរិចារិកានៃសក្កទេវរាជ។

សេចក្តីទាំងអស់នេះ នៅក្នុង**គុត្តិលវិមានវត្ថុ**។ នាងទេពធីតា ៣៦ អង្គ បានធ្វើកម្មណាទុក ទើបបានមកកើតក្នុងទេវលោកទាំងអស់ កាលព្រះពោធិសត្វសួរ បានពោល

គាថាទាំងឡាយសម្ដែងកម្មដែលខ្លួនបានធ្វើទុក។

ព្រះពោធិសត្វបានស្ដាប់ពាក្យនោះហើយពោលថា "ជាលាភរបស់ខ្ញុំពិតមែនហ្ន៎ ខ្ញុំបានល្អហើយហ្ន៎ ដំណើរមកទីនេះ បានស្ដាប់សម្បត្តិដែលបានមកដោយកម្ម សូម្បីមានប្រមាណតិច តាំងអំពីពេលនេះទៅ ខ្ញុំត្រឡប់ទៅកាន់មនុស្សលោកវិញ ខ្ញុំនឹងធ្វើតែកុសលកម្ម មានទានជាដើមប៉ុណ្ណោះ" ហើយបានបន្លឺឧទានដូច្នេះថា

ស្វាគតំ វត មេ អជ្ជ,
សុប្បភាតំ សុហុដ្ឋិតំ;
យំ អទ្ទសាមិ ទេវតាយោ,
អច្ឆរាកាមវណ្ណិយោ។
ឥមាសាហំ ធម្មំ សុត្វា,
កាហាមិ កុសលំ ពហុំ;
ទានេន សមចរិយាយ,
សំយមេន ទមេន ច;
ស្វាហំ តត្ថ គមិស្សាមិ,
យត្ថ គន្ត្វា ន សោចរេ។

ឱហ្ន៎ ដំណើរមកនៃអញក្នុងថ្ងៃនេះ ជាការល្អណាស់តើ ថ្ងៃនេះភ្លឺល្អណាស់ ការក្រោកឡើងអំពីដំណេកល្អណាស់ ព្រោះអញបានឃើញពួកទេវតាជាស្ត្រីអប្សរមានសម្បុរជាទីប្រាថ្នា អាត្មាអញនោះ បានស្តាប់ធម៌របស់ពួកទេវតាទាំងនោះ នឹងបានធ្វើកុសលច្រើន ដោយការឲ្យទានផង ដោយការប្រព្រឹត្តស្មើផង ដោយការសង្រួមផង ដោយការទូន្មានផង អ្នកផងទៅក្នុងទីណា ហើយមិនសោយសោក អាត្មាអញនោះនឹងនៅក្នុងទីនោះដែរ។

លុះគ្រប់ ៧ ថ្ងៃ សក្កទេវរាជឲ្យមាតលិទេវសារថីនាំព្រះមហាសត្វដែលអង្គុយលើរថមកកាន់នគរពារាណសីវិញ។ ព្រះពោធិសត្វកាលមកដល់នគរពារាណសីហើយ ក៏តំណាលរឿងនោះប្រាប់ដល់ពួកមនុស្ស។ មនុស្សទាំងនោះក៏ដល់នូវភាពឧស្សាហ៍ក្នុងបុណ្យគ្រប់ៗគ្នា។

## ជាតកសមោធាន

ព្រះបរមសាស្តាលុះទ្រង់នាំយកព្រះធម្មទេសនានេះមកសម្តែងហើយ ទើបទ្រង់ប្រជុំជាតកថា

-តទា មូសិលោ ទេវទត្តោ អហោសិ មុសិលៈ ក្នុងកាលនោះ បានមកជាទេវទត្ត

-សក្កោ អនុរុទ្ធោ សក្កទេវរាជបានមកជាអនុរុទ្ធ

-រាជា អានន្ទោ ព្រះរាជាបានមកជាអានន្ទ

-គុត្តិលគន្ធព្វោ បន អហមេវ អហោសិំ

ចំណែកគុត្តិលគន្ធព្វ គឺ**តថាគត**នេះឯង។

ចប់ គុត្តិលជាតក ៕

(ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទុកនិបាត សិង្គាលវគ្គ គុត្តិលជាតក បិដកលេខ ៥៨ ទំព័រ១៣២)

# ៤.ប្រជុំ ៣ នៃរឿងព្រះបាទនេមិរាជ
## ៤.១.មឃទេវសូត្រ



ខ្ញុំបានស្តាប់មកយ៉ាងនេះ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងមឃទេវម្ពវ័ន[៣] ជិតក្រុងមិថិលា។

គ្រានោះ ព្រះមានព្រះភាគ ទ្រង់ធ្វើអាការញញឹមព្រះឱស្ឋឲ្យប្រាកដ ក្នុងប្រទេសមួយ។

លំដាប់នោះ ព្រះអានន្ទមានអាយុ បានត្រិះរិះដូច្នេះ

---

[៣]. ព្រៃស្វាយរបស់ព្រះរាជាទ្រង់ព្រះនាមមឃទេវ:។

ថា "ហេតុអ្វីហ្ន៎ បច្ច័យអ្វីហ្ន៎ បណ្តាលឲ្យព្រះមានព្រះភាគ ទ្រង់ធ្វើអាការញញឹមព្រះឱស្ឋឲ្យប្រាកដ ព្រះតថាគតទាំងឡាយទ្រង់មិនធ្វើអាការញញឹមព្រះឱស្ឋឲ្យប្រាកដ ដោយការឥតហេតុអ្វីឡើយ"។

ខណៈនោះ ព្រះអានន្ទមានអាយុ ធ្វើចីវរឆៀងស្មាម្ខាង ប្រណម្យអញ្ជលីទៅរកព្រះមានព្រះភាគ ហើយក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា "បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វីហ្ន៎ បច្ច័យអ្វីហ្ន៎ បណ្តាលឲ្យព្រះមានព្រះភាគ ទ្រង់ធ្វើអាការញញឹមព្រះឱស្ឋឲ្យប្រាកដ ព្រះតថាគតទាំងឡាយទ្រង់មិនធ្វើអាការញញឹមព្រះឱស្ឋឲ្យប្រាកដ ដោយការឥតហេតុឡើយ"។

**ព្រះមានព្រះភាគត្រាស់ថា** ម្នាលអានន្ទ រឿងធ្លាប់មានមកហើយ ក្នុងនគរមិថិលានេះឯង មានព្រះរាជាទ្រង់ព្រះនាមថា **មឃទេវៈ** ជាធម្មរាជប្រកបដោយធម៌ ជាមហារាជ ទ្រង់ឋិតនៅក្នុងធម៌ ទ្រង់ប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទ ជាព្រាហ្មណជាតិ និងគហបតិជាតិ តែងចូលរក្សាឧបោសថ ក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ស។

ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំ កន្លងទៅហើយ ទើបព្រះបាទមឃទេវរាជ ទ្រង់ត្រាស់ហៅខ្មាន់ព្រះកេសមកថា "ម្នាលខ្មាន់ព្រះកេសសម្លាញ់ បើអ្នកឃើញសក់ស្កូវ លើក្បាលរបស់អញ ក្នុងកាលណាហើយ អ្នកគប្បីប្រាប់អញ ក្នុងកាលនោះ"។

ម្នាលអានន្ទ ខ្មាន់ព្រះកេស បានទទួលព្រះបន្ទូលនៃព្រះបាទមឃទេវរាជថា "ព្រះករុណាព្រះអង្គ"។

ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំ កន្លងទៅហើយ ទើបខ្មាន់ព្រះកេស បានឃើញសក់ស្កូវលើព្រះសិរនៃព្រះបាទមឃទេវរាជ លុះឃើញហើយទើបក្រាបទូលព្រះបាទមឃទេវរាជ ដូច្នេះថា "ទេវទូតប្រាកដច្បាស់ដល់ព្រះអង្គហើយ ព្រះកេសាស្កូវកើតលើព្រះសិរហើយ"។

**ព្រះបាទមឃទេវរាជត្រាស់ថា** "ម្នាលខ្មាន់ព្រះកេសសម្លាញ់ បើដូច្នោះ ចូរអ្នកដកសក់ស្កូវនោះ ដោយសណ្ដាសឲ្យស្រួល ហើយដាក់លើម្រាមដៃនៃអញមើល"។

ម្នាលអានន្ទ ខ្មាន់ព្រះកេសបានទទួលព្រះបន្ទូលនៃ

ព្រះបាទមឃទេវរាជថា "ព្រះករុណាព្រះអង្គ" ហើយបាន ដកសក់ស្កូវនោះ ដោយសណ្ដាសឲ្យស្រួល ហើយដាក់លើ ម្រាមព្រះហស្តនៃព្រះបាទមឃទេវរាជ។

ម្នាលអានន្ទ លំដាប់នោះ ព្រះបាទមឃទេវរាជ ទ្រង់ ព្រះរាជទានស្រុកសួយ ដល់ខ្មាន់ព្រះកេស ហើយទ្រង់ឲ្យ ហៅព្រះរាជកុមារ ជាបុត្តច្បងមក ទ្រង់មានព្រះបន្ទូល ដូច្នេះថា "ម្នាលកុមារកូន ទេវទូតប្រាកដច្បាស់ដល់បិតា ហើយ សក់ស្កូវក៏កើតមានលើក្បាលហើយ មួយទៀត កាម ដែលជារបស់មនុស្ស បិតាក៏បានបរិភោគស្កប់ស្កល់ហើយ ឥឡូវនេះ ជាសម័យគួរដើម្បីស្វែងរកនូវកាមជាទិព្វវិញ ម្នាលកុមារកូន កូនចូរមកគ្រប់គ្រងរាជសម្បត្តិនេះចុះ ចំណែកបិតា នឹងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់ សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ម្នាល កុមារកូន បើកូនឯង បានឃើញសក់ស្កូវលើក្បាលក្នុងកាល ណាហើយ កូនគប្បីឲ្យស្រុកសួយដល់ខ្មាន់ព្រះកេស ហើយ ប្រដៅនូវព្រះរាជកុមារ ដែលជាបុត្តច្បង ក្នុងរាជសម្បត្តិ ដោយប្រពៃ ហើយកោរសក់ ពុកមាត់ ពុកចង្កា ស្លៀក

ដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ក្នុងកាលនោះចុះ ព្រោះថា **កល្យាណវត្ត**នេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយជាងបិតាឡើយ ម្នាលកុមារកូន កាលបើគូនៃបុរស[២]ណាមានហើយ កល្យាណវត្ត មានសភាពយ៉ាងនេះ នឹងដាច់សូន្យទៅបាន បណ្ដាបុរសទាំងនោះ គូនៃបុរសនោះឯង ហៅថា បុរសថោកថយ។ ម្នាលកុមារកូន ព្រោះហេតុនោះ បានជាបិតានិយាយនឹងកូនឯងយ៉ាងនេះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយ ជាងបិតាឡើយ"។

ម្នាលអានន្ទ គ្រានោះ ព្រះបាទមឃទេវរាជ ទ្រង់ព្រះរាជទានស្រុកសួយ ដល់ខ្មាន់ព្រះកេសស្រេចហើយ ទ្រង់ប្រដៅព្រះរាជកុមារជាបុត្តច្បង ក្នុងរាជសម្បត្តិដោយប្រពៃហើយ ទ្រង់កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកសំពត់

---

[២]. បុរសដែលញ៉ាំងវង្សត្រកូល ឲ្យកើតនៅ ហៅថា គូនៃបុរសក្នុងទីនេះ។

កាសាយៈ ចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងមយទេវម្លវ័ន នេះឯង។ ព្រះបាទមឃទេវរាជនោះ មានចិត្តប្រកបដោយ មេត្តា ផ្សាយទៅកាន់ទិសទី១ សម្រេចសម្រាន្តនៅ ដោយ ឥរិយាបថទាំង៤ ផ្សាយទៅកាន់ទិសទី២ ផ្សាយទៅកាន់ ទិសទី៣ ផ្សាយទៅកាន់ទិសទី៤ ផ្សាយទៅកាន់ទិសខាង លើ ទិសខាងក្រោម និងទិសទទឹង[៩] មានចិត្តប្រកបដោយ មេត្តា ជាចិត្តទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោក ទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេច សម្រាន្តនៅ ដោយឥរិយាបថទាំង៤។

-មានចិត្តប្រកបដោយករុណា ។បេ។

-មានចិត្តប្រកបដោយមុទិតា ។បេ។

-មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទីកាន់ទិសទី១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤ ផ្សាយទីកាន់ ទិសទី២ ផ្សាយទីកាន់ទិសទី៣ ផ្សាយទីកាន់ទិសទី៤ ផ្សាយ ទីកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្ត

[៩].បានដល់ទិសតូចទាំង៤គឺទិសឦសាន អគ្នេយ៍ និរតី ពាយព្យ។

ប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវសភាពធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤។

ម្នាលអានន្ទ ក៏ឯព្រះបាទមឃទេវរាជ កាលនៅលេងល្បែងក្មេង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, សោយរាជ្យជាឧបរាជ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, សោយរាជ្យជាស្តេចធំ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ។ ព្រះបាទមឃទេវរាជនោះ ចម្រើនព្រហ្មវិហារទាំង៤ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោក។

ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំ កន្លងទៅហើយ ទើបបុត្តរបស់ព្រះបាទមឃទេវរាជត្រាស់ហៅខ្មាន់ព្រះកេសមកថា "ម្នាលខ្មាន់ព្រះកេសជាសម្លាញ់ បើអ្នកបានឃើញសក់ស្កូវ លើក្បាលរបស់អញ

ក្នុងកាលណាហើយ អ្នកគប្បីប្រាប់អញ ក្នុងកាលនោះ”។

ម្នាលអានន្ទ ខ្មាន់ព្រះកេស ទទួលព្រះបន្ទូលនៃបុត្ត របស់ព្រះបាទមឃទេវរាជថា “ព្រះករុណាព្រះអង្គ”។

ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំ កន្លងទៅហើយ ខ្មាន់ព្រះកេស បានឃើញសក់ស្កូវលើព្រះសិរនៃបុត្តរបស់ព្រះបាទមឃទេវរាជ លុះឃើញហើយ ទើបក្រាបទូលបុត្ត របស់ព្រះបាទមឃទេវរាជ ដូច្នេះថា “ទេវទូតប្រាកដច្បាស់ ដល់ព្រះអង្គហើយ ព្រះកេសស្កូវក៏កើតលើព្រះសិរហើយ”។

ព្រះរាជបុត្តត្រាស់ថា “ម្នាលខ្មាន់ព្រះកេសជាសម្លាញ់ បើដូច្នោះ អ្នកចូរដកសក់ស្កូវនោះ ដោយសណ្ដាសឲ្យស្រួល ហើយដាក់លើម្រាមដៃអញមើល”។

ម្នាលអានន្ទ ខ្មាន់ព្រះកេស បានទទួលព្រះបន្ទូលនៃបុត្តរបស់ព្រះបាទមឃទេវរាជថា “ព្រះករុណាព្រះអង្គ” ហើយបានដកសក់ស្កូវនោះ ដោយសណ្ដាសឲ្យស្រួល ដាក់លើម្រាមព្រះហស្ត នៃបុត្តរបស់ព្រះបាទមឃទេវរាជ។

ម្នាលអានន្ទ លំដាប់នោះ បុត្តនៃព្រះបាទមឃទេវ-

រាជ ទ្រង់ព្រះរាជទានស្រុកសួយ ដល់ខ្មាន់ព្រះកេស ហើយ ឲ្យហៅព្រះរាជកុមារ ជាបុត្តច្បងមក ទ្រង់មានព្រះបន្ទូលដូច្នេះថា "ម្នាលកុមារកូន ទេវទូតប្រាកដច្បាស់ ដល់បិតាហើយ សក់ស្កូវ ក៏កើតមាន លើក្បាលហើយ មួយទៀត កាមដែលជារបស់មនុស្ស បិតាក៏បានបរិភោគស្កប់ស្កល់ហើយ ឥឡូវនេះ ជាសម័យគួរដើម្បីស្វែងរកនូវកាមជាទិព្វវិញ ម្នាលកុមារកូន កូនចូរមកគ្រប់គ្រងរាជសម្បត្តិនេះចុះ ចំណែកបិតា នឹងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ម្នាលកុមារកូន បើកូនឯង បានឃើញសក់ស្កូវ កើតលើក្បាលក្នុងកាលណាហើយ កូនគប្បីឲ្យស្រុកសួយ ដល់ខ្មាន់ព្រះកេស ហើយប្រដៅព្រះរាជកុមារ ដែលជាបុត្តច្បង ក្នុងរាជ-សម្បត្តិ ដោយប្រពៃ ហើយកោរសក់ ពុកមាត់ ពុកចង្កាស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ក្នុងកាលនោះចុះ ព្រោះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយ ជាងបិតាឡើយ ម្នាលកុមារកូន កាលបើ

គូនៃបុរសណាមានហើយ កល្យាណវត្ត មានសភាពយ៉ាង នេះ នឹងដាច់សូន្យទៅបាន បណ្តាបុរសទាំងនោះ គូនៃ បុរសនោះឯង ហៅថា បុរសថោកថយ។ ម្នាលកុមារកូន ព្រោះហេតុនោះ បានជាបិតា និយាយនឹងកូនឯង យ៉ាង នេះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយ ជាង បិតាឡើយ៉។

ម្នាលអានន្ទ គ្រានោះ បុត្តរបស់ព្រះបាទមឃទេវរាជ ព្រះរាជទានស្រុកសួយ ដល់ខ្មាន់ព្រះកេសស្រេចហើយ ប្រដៅព្រះរាជកុមារ ជាបុត្រច្បង ក្នុងរាជសម្បត្តិដោយ ប្រពៃហើយ កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកសំពត់កា-សាយៈ ចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងមឃទេវម្ពវ័ន នេះឯង។ រាជបុត្តនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយ ទៅកាន់ទិសទី១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ផ្សាយទៅកាន់ទិសទី២ ផ្សាយទៅកាន់ទិសទី៣ ផ្សាយ ទៅកាន់ទិសទី៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាង ក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តា ជាចិត្ត

ទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤។

-មានចិត្តប្រកបដោយករុណា ។បេ។

-មានចិត្តប្រកបដោយមុទិតា ។បេ។

-មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤ ផ្សាយទៅកាន់ទិសទី២ ផ្សាយទៅកាន់ទិសទី៣ ផ្សាយទៅកាន់ទិសទី ៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤។

ម្នាលអានន្ទ ក៏ឯបុត្តនៃព្រះបាទមឃទេវរាជ នៅលេងល្បែងក្មេង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, សោយរាជ្យ

ជាឧបរាជ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, សោយរាជ្យជាស្ដេចធំ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, ចេញចាកផ្ទះ ចូលមកកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ។ ព្រះរាជបុត្តនោះចម្រើនព្រហ្មវិហារទាំង៤ លុះមានរាងកាយបែកធ្លាយទៅខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោក។

ម្នាលអានន្ទ ក៏ឯបុត្ត និងនត្តា របស់ព្រះបាទមឃទេវរាជនោះតៗ ព្រះវង្ស អស់ចំនួនប្រាំបីហ្មឺនបួនពាន់តំណក៏កោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងមឃទេវម្ពវ័ននេះឯង។ ឥសីទាំងអម្បាលនោះ មានចិត្តប្រកបដោយមេត្តាផ្សាយទៅកាន់ទិសទី១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤ ផ្សាយទៅកាន់ទិសទី២ ផ្សាយទៅកាន់ទិសទី៣ ផ្សាយទៅកាន់ទិសទី៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបានមិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោក

ទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤។

-មានចិត្តប្រកបដោយករុណា...

-មានចិត្តប្រកបដោយមុទិតា...

-មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤ ផ្សាយទៅកាន់ទិសទី២ ផ្សាយទៅកាន់ទិសទី៣ ផ្សាយទៅកាន់ទិសទី៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅ កាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤។ ឥសីទាំងអម្បាលនោះ នៅលេងល្បែងក្មេង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, សោយរាជ្យជាឧបរាជ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, សោយរាជ្យជាស្តេចធំ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, ចេញចាកផ្ទះ ចូលមកកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីហ្មឺនបួនពាន់

ឆ្នាំៗ ឥសីទាំងអម្បាលនោះ ចម្រើនព្រហ្មវិហារទាំង៤ លុះមានរាងកាយ បែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោកៗ

បណ្ដាព្រះរាជាទាំងអម្បាលនោះ ព្រះបាទនិមិរាជ ជាស្ដេចក្រោយបង្អស់ ជាធម្មរាជ ប្រកបដោយធម៌ ជាមហារាជ ឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទ ជាព្រាហ្មណជាតិ និងគហបតិជាតិ តែងរក្សាឧបោសថ ក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្សៗ

ម្នាលអានន្ទ រឿងនេះធ្លាប់មានមកហើយតើ ពាក្យជាចន្លោះនេះ បានកើតឡើងដល់ពួកទេវតាជាន់តាវត្តិង្ស ដែលអង្គុយប្រជុំគ្នា ក្នុងរោងសុធម្មាថា "អើហ្ន៎ ពួកជននៅក្នុងដែនវិទេហៈ ពេញហៅជាមានលាភ អើហ្ន៎ អត្តភាពជាមនុស្ស ពួកជននៅក្នុងដែនវិទេហៈ ពេញហៅបានដោយល្អ ព្រោះថា ព្រះបាទនិមិរាជ ជាធម្មរាជ ប្រកបដោយធម៌ ជាមហារាជ ទ្រង់ឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទ ជាព្រាហ្មណជាតិ និងគហបតិ-ជាតិ តែងរក្សាឧបោសថ ក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃ

បក្ស”។

ម្នាលអានន្ទ លំដាប់នោះ សក្កទេវរាជ ជាធំជាង ទេវតា បានហៅពួកទេវតា ជាន់តាវត្តិង្សមកថា “ម្នាលគ្នា យើងទាំងឡាយ អ្នកទាំងឡាយ ចង់ឃើញព្រះបាទនិមិរាជ ឬទេ?”

**ពួកទេវតាក្រាបទូលថា** “បពិត្រទ្រង់អ្នកនិទ៌ុក្ខ យើង ទាំងឡាយចង់ឃើញព្រះបាទនិមិរាជដែរ”។

ម្នាលអានន្ទ សម័យនោះឯង ព្រះបាទនិមិរាជជម្រះ ព្រះសិរ្ស ហើយរក្សាឧបោសថ ក្នុងថ្ងៃឧបោសថទី១៥ ហើយចូលទៅកាន់ប្រាសាទដ៏ប្រសើរ គង់នៅក្នុងជាន់លើ។

ម្នាលអានន្ទ លំដាប់នោះ សក្កទេវរាជជាធំ ជាង ទេវតាក៏បំបាត់ខ្លួនអំពីពួកទេវតាជាន់តាវត្តិង្ស ហើយមក ប្រាកដចំពោះព្រះភក្ត្រព្រះបាទនិមិរាជ ដូចជាបុរសមាន កម្លាំងលា នូវដៃដែលបត់ចូល ឬបត់នូវដៃ ដែលលាចេញ ដូច្នោះ។

ម្នាលអានន្ទ លំដាប់នោះ សក្កទេវរាជ ជាធំជាង ទេវតា មានព្រះបន្ទូលពាក្យនេះ នឹងព្រះបាទនិមិរាជថា

“បពិត្រមហារាជ ព្រះអង្គពេញហៅជាមានលាភ បពិត្រមហារាជ អត្តភាពជាមនុស្ស ព្រះអង្គពេញហៅបានដោយល្អ បពិត្រមហារាជ ដ្បិតពួកទេវតាជាន់តាវត្តិង្ស បានអង្គុយប្រជុំគ្នា និយាយសរសើរ ក្នុងរោងសុធម្មាថា ‘អើហ្ន៎ ពួកជននៅក្នុងដែនវិទេហៈ ពេញហៅជាមានលាភ អើហ្ន៎ អត្តភាពជាមនុស្សពួកជននៅក្នុងដែនវិទេហៈ ពេញហៅបានដោយល្អ ព្រោះថា ព្រះបាទនិមិរាជ ជាធម្មរាជ ប្រកបដោយធម៌ជាមហារាជ ទ្រង់ឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ចំពោះអ្នកនិគម និងអ្នកជនបទ ជាព្រាហ្មណជាតិ និងគហបតិជាតិ តែងរក្សាឧបោសថ ក្នុងថ្ងៃទី១៤ ទី១៥ និងទី៨នៃបក្ស’ ដូច្នេះ បពិត្រមហារាជ ពួកទេវតាជាន់តាវត្តិង្ស មានសេចក្តីប្រាថ្នា ដើម្បីឃើញព្រះអង្គ បពិត្រមហារាជ ខ្ញុំព្រះអង្គនឹងបញ្ជូនរថ សម្រាប់ទឹមសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់មកដើម្បីព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គកុំញញើត គប្បីឡើងកាន់ទិព្វយាន”។

ម្នាលអានន្ទ ព្រះបាទនិមិរាជ ទ្រង់ទទួលអញ្ជើញដោយតុណ្ហីភាព។

ម្នាលអានន្ទ គ្រានោះ សក្កទេវរាជ ជាធំជាងទេវតា ទ្រង់ជ្រាបថា ព្រះបាទនិមិរាជ ទទួលអញ្ជើញហើយ ក៏បំបាត់ខ្លួន អំពីចំពោះព្រះភក្ត្រនៃព្រះបាទនិមិរាជ ទៅប្រាកដ ក្នុងពួកទេវតាជាន់តាវត្តិង្សវិញ ដូចជាបុរសមានកម្លាំងលាដៃ ដែលបត់ចូល ឬបត់ចូលនូវដៃ ដែលលាចេញ ដូច្នោះ។

ម្នាលអានន្ទ លំដាប់នោះ សក្កទេវរាជ ជាធំជាងទេវតា បានត្រាស់ហៅមាតលិទេវបុត្ត ជាអ្នកសង្រ្គោះមកថា "ម្នាលមាតលិសម្លាញ់ អ្នកចូរមករៀបចំរថសេះអាជានេយ្យ ដែលទឹមដោយសេះមួយពាន់ ហើយចូលទៅថ្កានព្រះបាទនិមិរាជ រួចទូលយ៉ាងនេះថា បពិត្រមហារាជ រថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់នេះ សក្កទេវរាជ ជាធំជាងទេវតា ទ្រង់បញ្ជូនមកហើយ ដើម្បីព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គកុំញញើត គប្បីឡើងកាន់ទិព្វយានចុះ"។

ម្នាលអានន្ទ មាតលិទេវបុត្ត ជាអ្នកសង្រ្គោះ ក៏ទទួលព្រះបន្ទូលនៃសក្កទេវរាជ ជាធំជាងទេវតាថា "ព្រះ

ករុណា សេចក្តីចម្រើន ចូរមានដល់ព្រះអង្គ” ហើយរៀបចំរថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់ នាំចូលទៅឋាន ព្រះបាទនិមិរាជ ហើយទូលសេចក្តីនេះថា “បពិត្រមហារាជ រថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់នេះ សក្កទេវរាជ ជាធំជាងទេវតា ទ្រង់បញ្ជូនមកហើយ ដើម្បីព្រះអង្គ បពិត្រមហារាជសូមព្រះអង្គកុំញញើត ចូរឡើងកាន់ទិព្វយានចុះ បពិត្រមហារាជ មួយទៀត ពួកសត្វ ដែលមានកម្មអាក្រក់ តែងទទួលនូវផល នៃកម្មអាក្រក់ ដោយផ្លូវណាក្តី ពួកសត្វដែលមានកម្មល្អ តែងទទួលនូវផល នៃកម្មល្អ ដោយផ្លូវណាក្តី បណ្តាផ្លូវទាំងពីរនោះ ខ្ញុំនឹងនាំព្រះអង្គទៅតាមផ្លូវណា”។

**ព្រះបាទនិមិរាជត្រាស់ថា** “មាតលិទេវបុត្ត អ្នកចូរនាំយើង ទៅតាមផ្លូវទាំងពីរនោះចុះ”។

ម្នាលអានន្ទ មាតលិទេវបុត្ត ជាអ្នកសង្រ្គោះ បានញុំាងព្រះបាទនិមិរាជ ឲ្យទៅដល់វេរាងសុធម្មា។

ម្នាលអានន្ទ សក្កទេវរាជ ជាធំជាងទេវតា បាន

*ឃើញព្រះបាទនិមិរាជ ស្តេចមកអំពីចម្ងាយ លុះឃើញហើយ ទើបនិយាយពាក្យនេះ នឹងព្រះបាទនិមិរាជថា "បពិត្រមហារាជ សូមព្រះអង្គមកចុះ បពិត្រមហារាជ ព្រះអង្គស្តេចមកប្រពៃហើយ បពិត្រមហារាជ ពួកទេវតាជាន់តាវត្តិង្ស បានប្រជុំគ្នា និយាយក្នុងរោងសុធម្មាថា 'ឱហ្ន៎ ពួកជននៅក្នុងដែនវិទេហៈ ពេញហៅជាមានលាភ ឱហ្ន៎ អត្តភាពជាមនុស្ស ពួកជននៅក្នុងដែនវិទេហៈ ពេញហៅបានដោយល្អ ព្រោះថា ព្រះបាទនិមិរាជ ជាធម្មរាជប្រកបដោយធម៌ ជាមហារាជ ទ្រង់ឋិតនៅក្នុងធម៌ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទ ជាព្រាហ្មណជាតិ និងគហបតិជាតិ តែងរក្សាឧបោសថ ក្នុងថ្ងៃទី១៤ ទី១៥ និងទី៨ នៃបក្ស' ដូច្នេះ បពិត្រមហារាជ ពួកទេវតាជាន់តាវត្តិង្ស មានសេចក្តីប្រាថ្នា ដើម្បីឃើញព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គត្រេកអរ ចំពោះពួកទេវតា ដោយទេវានុភាពចុះ"។*

(*កាលបាននៅក្នុងទេវលោកល្មមសមគួរហើយ ព្រះបាទនិមិរាជត្រាស់ថា*)

"បពិត្រព្រះអង្គអ្នកនិទុក្ខ ល្មមហើយ សូមព្រះអង្គនាំខ្ញុំទៅ កាន់ក្រុងមិថិលា ក្នុងដែនវិទេហៈនោះវិញ ខ្ញុំនឹងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទ ជាព្រាហ្មណជាតិ និងគហបតិជាតិ និងរក្សាឧបោសថក្នុងថ្ងៃទី១៤ ទី១៥ និងទី៨ នៃបក្ស"។

ម្នាលអានន្ទ គ្រានោះឯង សក្កទេវរាជ ជាធំជាងទេវតា ទ្រង់ត្រាស់ហៅមាតលិទេវបុត្ត ជាអ្នកសង្គ្រោះមកថា "ម្នាលមាតលិទេវបុត្តសម្លាញ់ អ្នកចូរមករៀបចំរថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់ ហើយនាំព្រះបាទនិមិរាជទៅកាន់ក្រុងមិថិលា ក្នុងដែនវិទេហៈនោះវិញ"។

ម្នាលអានន្ទ មាតលិទេវបុត្ត ជាអ្នកសង្គ្រោះ បានទទួលព្រះបន្ទូល នៃសក្កទេវរាជ ជាធំជាងទេវតាថា "ព្រះករុណា សេចក្ដីចម្រើន ចូរមានដល់ព្រះអង្គ" ហើយរៀបចំរថសេះអាជានេយ្យ ដែលទឹមដោយសេះអាជានេយ្យមួយពាន់ ហើយនាំព្រះបាទនិមិរាជ ទៅកាន់ក្រុងមិថិលា ក្នុងដែនវិទេហៈនោះវិញ។

ម្នាលអានន្ទ បានឮថា មហារាជក្នុងក្រុងមិថិលា នោះ តែងប្រព្រឹត្តធម៌ ក្នុងពួកអ្នកនិគម និងអ្នកជនបទ ជាព្រាហ្មណជាតិ និងគហបតិជាតិ តែងរក្សាឧបោសថក្នុងថ្ងៃទី១៤ ទី១៥ និងទី៨ នៃបក្ស។

ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំកន្លងទៅហើយ ទើបព្រះបាទនិមិរាជ ត្រាស់ហៅខ្មាន់ព្រះកេសមកថា "ម្នាលខ្មាន់ព្រះកេសជាសម្លាញ់ បើអ្នកបានឃើញសក់ស្កូវ កើតមានលើក្បាលនៃអញ ក្នុងកាលណាហើយ អ្នកចូរប្រាប់អញ ក្នុងកាលនោះ"។

ម្នាលអានន្ទ ខ្មាន់ព្រះកេស ទទួលព្រះបន្ទូលព្រះបាទនិមិរាជថា "ព្រះករុណាព្រះអង្គ"។

ម្នាលអានន្ទ លុះច្រើនឆ្នាំ ច្រើនរយឆ្នាំ និងច្រើនពាន់ឆ្នាំ កន្លងទៅហើយ ខ្មាន់ព្រះកេស បានឃើញសក់ស្កូវកើតមានលើព្រះសិរ្ស នៃព្រះបាទនិមិរាជ លុះឃើញហើយ ទើបក្រាបទូលព្រះបាទនិមិរាជ ដូច្នេះថា "ទេវទូតប្រាកដច្បាស់ ដល់ព្រះអង្គហើយ ព្រះកេសស្កូវ កើតមានលើព្រះសិរ្សហើយ"។

ព្រះបាទនិមិរាជត្រាស់ថា "ម្នាលខ្មាន់ព្រះកេស ជាសម្លាញ់ បើដូច្នោះ អ្នកចូរដកសក់ស្កូវនោះ ដោយសណ្ដាសឲ្យស្រួល ហើយដាក់លើម្រាមដៃអញមើល"។

ម្នាលអានន្ទ ខ្មាន់ព្រះកេស បានទទួលព្រះបន្ទូលនៃព្រះបាទនិមិរាជថា "ព្រះករុណាព្រះអង្គ" ហើយដកសក់ស្កូវនោះ ដោយសណ្ដាសឲ្យស្រួល រួចដាក់លើម្រាមព្រះហស្ត នៃព្រះបាទនិមិរាជ។

ម្នាលអានន្ទ លំដាប់នោះ ព្រះបាទនិមិរាជ ទ្រង់ព្រះរាជទានស្រុកសួយ ដល់ខ្មាន់ព្រះកេស ហើយឲ្យហៅព្រះរាជកុមារ ជាបុត្តច្បងមក ទ្រង់មានព្រះបន្ទូល ដូច្នេះថា "ម្នាលកុមារកូន ទេវទូតប្រាកដច្បាស់ ដល់បិតាហើយ សក់ស្កូវ ក៏កើតមានលើក្បាលហើយ មួយទៀត កាមដែលជារបស់មនុស្ស បិតាក៏បានបរិភោគស្កប់ស្កល់ហើយ ឥឡូវនេះ ជាសម័យគួរដើម្បីស្វែងរកនូវកាមជាទិព្វវិញ ម្នាលកុមារកូន អ្នកចូរមកគ្រប់គ្រងរាជសម្បត្តិនេះចុះ ចំណែកបិតានឹងកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ម្នាលកុមារកូន

បើកូនឯង បានឃើញសក់ស្កូវ កើតមានលើក្បាល ក្នុងកាលណាហើយ កូនគប្បីឲ្យស្រុកសួយ ដល់ខ្មាន់ព្រះកេស ហើយប្រដៅនូវព្រះរាជកុមារ ដែលជាបុត្តច្បង ក្នុងរាជ-សម្បត្តិ ដោយប្រពៃ ហើយកោរសក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ក្នុងកាលនោះចុះ ព្រោះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយ ជាងបិតាឡើយ ម្នាលកុមារកូន កាលបើគូនៃបុរសណានៅមានហើយ កល្យាណវត្ត មានសភាពយ៉ាងនេះ នឹងដាច់សូន្យទៅបាន បណ្តាបុរសទាំងនោះ គូនៃបុរសនោះឯង ហៅថា បុរសថោកថយ។ ម្នាលកុមារកូន ព្រោះហេតុនោះ បានជាបិតានិយាយនឹងកូនឯងយ៉ាងនេះថា កល្យាណវត្តនេះ បិតាបានតាំងទុកស្រេចហើយ កូនគប្បីប្រព្រឹត្តតាមចុះ កូនកុំធ្វើជាបុរសថោកថយ ជាងបិតាឡើយ”។

ម្នាលអានន្ទ គ្រានោះ ព្រះបាទនិមិរាជ ទ្រង់ព្រះរាជទានស្រុកសួយ ដល់ខ្មាន់ព្រះកេសស្រេចហើយ ប្រដៅព្រះ

រាជកុមារ ជាបុត្តច្បង ក្នុងរាជសម្បត្តិឲ្យស្រួលហើយកោរ សក់ ពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលមកកាន់ផ្នួស ក្នុងមឃទេវម្ពវ័ននេះឯង។ ព្រះបាទនិមិរាជនោះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅ កាន់ទិសទី១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤ ផ្សាយទៅកាន់ទិសទី២ ផ្សាយទៅកាន់ទិសទី៣ ផ្សាយទៅ កាន់ទិសទី៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយមេត្តា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមាន ព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការ ទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយ ឥរិយាបថទាំង៤។

-មានចិត្តប្រកបដោយករុណា...

-មានចិត្តប្រកបដោយមុទិតា...

-មានចិត្តប្រកបដោយឧបេក្ខា ផ្សាយទៅកាន់ទិសទី ១ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង៤ ផ្សាយទៅ កាន់ទិសទី២ ផ្សាយទៅកាន់ទិសទី៣ ផ្សាយទៅកាន់ទិសទី

៤ ផ្សាយទៅកាន់ទិសខាងលើ ទិសខាងក្រោម និងទិសទទឹង មានចិត្តប្រកបដោយឧបេក្ខា ជាចិត្តទូលាយ ដល់នូវភាពជាធំ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយអាការទាំងពួង ក្នុងទីទាំងពួង សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤។

ម្នាលអានន្ទ ព្រះបាទនិមិរាជ នៅលេងល្បែងក្មេង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, សោយរាជ្យជាឧបរាជ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, សោយរាជ្យជាស្តេចធំ កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ, ចេញចាកផ្ទះ ចូលមកកាន់ផ្នួស ប្រព្រឹត្តព្រហ្មចរិយធម៌ ក្នុងមឃទេវម្ពវ័ននេះឯង កំណត់ប្រាំបីហ្មឺនបួនពាន់ឆ្នាំ។ ព្រះបាទនិមិរាជនោះ ចម្រើនព្រហ្មវិហារទាំង៤ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពីមរណៈ ក៏បានទៅកើតក្នុងព្រហ្មលោក។

ម្នាលអានន្ទ ក៏ឯព្រះបាទនិមិរាជ ព្រះអង្គមានព្រះរាជបុត្តមួយអង្គ ព្រះនាមថា**កឡារជនកៈ**។ ព្រះរាជបុត្តនោះ មិនចេញចាកផ្ទះ ចូលកាន់ផ្នួសឡើយ។ ព្រះរាជបុត្ត

នោះ ក៏ផ្ដាច់នូវកល្យាណវត្តនោះហើយ។ បណ្ដាក្សត្រិយ៍ទាំងនោះ ព្រះរាជបុត្តនោះ ជាបុរសឋោកថយជាងគេ។

ម្នាលអានន្ទ ប្រហែលជាអ្នកមានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រះបាទមឃទេវរាជណា ដែលបានតាំងទុកនូវកល្យាណវត្តនោះ ព្រះបាទមឃទេវរាជនោះឯង គឺបុគ្គលដទៃ ក្នុងសម័យនោះទេដឹង។

ម្នាលអានន្ទ រឿងនុ៎ះ អ្នកកុំគប្បីយល់យ៉ាងនេះឡើយ ។ តថាគតឯង ជាមឃទេវរាជ ក្នុងសម័យនោះ។ តថាគតបានតាំងទុកនូវកល្យាណវត្តនោះហើយ ប្រជុំជនជាខាងក្រោយ បានប្រព្រឹត្តតាមកល្យាណវត្តនោះ ដែលតថាគត បានតាំងទុកស្រេចហើយ។

ម្នាលអានន្ទ តែថាកល្យាណវត្តនោះ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាករាគៈ មិនប្រព្រឹត្តទៅ ដើម្បីរំលត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វានឡើយ បានត្រឹមតែកើតក្នុងព្រហ្មលោក ប៉ុណ្ណោះឯង។

ម្នាលអានន្ទ ចំណែកខាងកល្យាណវត្តនេះ ដែលតថាគតតាំងទុកហើយ ក្នុងកាលឥឡូវនេះ តែងប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ដោយពិត ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។

ម្នាលអានន្ទ កល្យាណវត្ត ដែលតថាគត តាំងទុកហើយ ក្នុងកាលឥឡូវនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីនឿយណាយ ដោយពិត ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន តើដូចម្តេច?

**-មគ្គប្រកបដោយអង្គ៨ ដ៏ប្រសើរនេះឯង គឺ**

| | |
|---|---|
| ១-សម្មាទិដ្ឋិ | សេចក្តីឃើញប្រពៃ |
| ២-សម្មាសង្កប្បោ | សេចក្តីត្រិះរិះប្រពៃ |
| ៣-សម្មាវាចា | វាចាប្រពៃ |
| ៤-សម្មាកម្មន្តោ | ការងារប្រពៃ |
| ៥-សម្មាអាជីវោ | ការចិញ្ចឹមជីវិតប្រពៃ |
| ៦-សម្មាវាយាមោ | សេចក្តីព្យាយាមប្រពៃ |

**៧-សម្មាសតិ** *សេចក្ដីរលឹកប្រពៃ*

**៨-សម្មាសមាធិ** *ការតាំងចិត្តប្រពៃ*

*ម្នាលអានន្ទ កល្យាណវត្តនេះឯង ដែលតថាគតតាំងទុកហើយ ក្នុងកាលឥឡូវនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្ដីនឿយណាយ ដោយពិត ដើម្បីប្រាសចាករាគៈ ដើម្បីរំលត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន។*

*ម្នាលអានន្ទ តថាគតពោលនូវកល្យាណវត្តនោះ ដល់អ្នកទាំងឡាយថា "កល្យាណវត្តនេះ តថាគត បានតាំងទុកហើយ អ្នកទាំងឡាយ គប្បីប្រព្រឹត្តតាមចុះ អ្នកទាំងឡាយ កុំជាបុរសថោកថយ ជាងតថាគតឡើយ ម្នាលអានន្ទ កាលបើគូនៃបុរសណាមាននៅ កល្យាណវត្តមានសភាពយ៉ាងនេះ នឹងដាច់សូន្យទៅ បណ្ដាបុរសទាំងនោះ គូនៃបុរសនោះឯង ហៅថា បុរសថោកថយ"។*

*ម្នាលអានន្ទ តថាគត ពោលនូវកល្យាណវត្តនោះ ដល់អ្នកទាំងឡាយយ៉ាងនេះថា "កល្យាណវត្តនេះ តថាគត បានតាំងទុកហើយ អ្នកទាំងឡាយ គប្បីប្រព្រឹត្តតាមចុះ អ្នក*

ទាំងឡាយ កុំជាបុរសហោកថយ ជាផតថាគតឡើយ"។

លុះព្រះមានព្រះភាគ បានត្រាស់សូត្រនេះចប់ហើយ ព្រះអានន្ទដ៏មានអាយុ ជាអ្នកមានសេចក្ដីត្រេកអរ ក៏បានត្រេកអរ ចំពោះភាសិត របស់ព្រះមានព្រះភាគ។

ចប់ មយទេវសូត្រ ៕

(បិដកលេខ ២៤ ទំព័រ ៣១១)

## ៤.២.នេមិរាជជាតក

(បិដកលេខ៦២ ទំព័រ៦៨)

(**អភិសម្ពុទ្ធគាថា**) *ក្នុងកាលដែលព្រះបាទនេមិ ជាបណ្ឌិត អ្នកត្រូវការដោយកុសល ជាព្រះរាជាអ្នកទូន្មាននូវសត្រូវ ទ្រង់តែងឲ្យទានដល់ជនអ្នកនៅក្នុងដែនវិទេហៈទាំងឡាយគ្រប់គ្នា។*

*គ្រានោះ (មនុស្សនិងទេវតាទាំងឡាយតែងសរសើរថា) ឱអស្ចារ្យណាស់ អ្នកប្រាជ្ញទាំងឡាយ មានប្រាជ្ញាជាគ្រឿងពិចារណា កើតឡើងក្នុងលោកហើយ។ កាលព្រះអង្គនោះ ទ្រង់ឲ្យទាននោះ សេចក្តីត្រិះកើតឡើងថា "ទានក្តី ព្រហ្មចរិយៈក្តី កុសលណាហ្ន៎ មានផលច្រើនជាង"។*

*ទេវរាជឈ្មោះមឃវៈ ជាទេវកុញ្ជរ ជាសហស្សនេត្រ បានជ្រាបព្រះតម្រិះរបស់ព្រះរាជានោះ ហើយមកប្រាកដ ហើយមកប្រាកដ (ក្នុងទីចំពោះព្រះភក្ត្រព្រះរាជា) កម្ចាត់បង់នូវងងឹតដោយវណ្ណៈ។*

*ព្រះបាទនេមិរាជជាធំ ជាងមនុស្ស ទ្រង់ព្រឺព្រះលោមា បានសួរទេវរាជឈ្មោះវាសវៈថា "អ្នកជាទេវតា*

ឬគន្ធព្វ ឬក៏សក្កបុរិន្ទទៈ រស្មីប្រាកដដូច្នោះ ខ្ញុំពុំដែលឃើញ ទាំងមិនធ្លាប់ឮឡើយ បពិត្រអ្នកដ៏ចម្រើន អ្នកចូរប្រាប់ខ្ញុំ ធ្វើម្ដេចយើងស្គាល់អ្នកបាន?"

**ទេវរាជ ឈ្មោះវាសវៈជ្រាបថា** "ព្រះបាទនេមិព្រឺព្រះលោមាហើយ" ទើបឆ្លើយថា "ខ្ញុំជាព្រះឥន្ទ្រ ជាធំជាងទេវតា មកកាន់សំណាក់ព្រះអង្គជាធំជាងមនុស្ស ទ្រង់កុំព្រឺព្រះលោមាឡើយ ព្រះអង្គមានសេចក្ដីប្រាថ្នាដើម្បីសួរនូវប្រស្នាណា សូមទ្រង់សួរចុះ"។

ចំណែកនេមិរាជអង្គនោះ លុះព្រះឥន្ទ្រាធិរាជធ្វើឱកាសហើយ ក៏ទ្រង់ត្រាស់សួរនូវទេវរាជឈ្មោះវាសវៈថា "បពិត្រទេវរាជជាឥស្សរៈជាងសព្វសត្វទាំងឡាយ ខ្ញុំសូមសួរព្រះអង្គថា ទានក្ដី ព្រហ្មចរិយៈក្ដី កុសលណាមានផលច្រើនជាង"។

ព្រះវាសវៈនោះដែលព្រះបាទនេមិ ជានរទេពសួរហើយ ក៏ឆ្លើយតបព្រះបាទនេមិវិញ ព្រះវាសវៈនោះ ប្រាប់នូវផលនៃព្រហ្មចរិយៈ បានទូលព្រះបាទនេមិ ដែលមិនជ្រាបថា បុគ្គលកើតក្នុងត្រកូលក្សត្រដោយព្រហ្មចរិយៈ

ថោកទាប, ដល់នូវភាពជាទេវតាដោយព្រហ្មចរិយៈជាកណ្តាល, បរិសុទ្ធស្អាតដោយព្រហ្មចរិយៈខ្ពង់ខ្ពស់។

ពួកអ្នកបួសប្រព្រឹត្តតបៈទាំងឡាយ ទៅកើតក្នុងពួកព្រហ្មណា ពួកព្រហ្មទាំងនុ៎ះ បុគ្គលអ្នកប្រកបក្នុងការសូមណាមួយមិនងាយបានសោះទេ។

ព្រះបាទទុទីបៈ ១ ព្រះបាទសាគរៈ ១ ព្រះបាទសេលៈ ១ ព្រះបាទមុចលិន្ទ ១ ព្រះបាទភគីរសៈ ១ ព្រះបាទឧសិន្នរៈ ១ ព្រះបាទអត្តកៈ១ ព្រះបាទអស្សកៈ ១ ព្រះបាទបថុទ្ធនៈ ១។

ព្រះរាជាទាំងឡាយអង្គនេះក្តី ព្រះរាជាទាំងឡាយដទៃ ពួកក្សត្រ ពួកព្រាហ្មណ៍ជាច្រើនក្តី ដែលបូជានូវគ្រឿងយ័ញ្ញយ៉ាងច្រើន មិនប្រព្រឹត្តកន្លងនូវ**បេតភាព** (កាមាវចរភូមិ) ឡើយ។

ជនទាំងឡាយណា មិនមានគូ ជាបុគ្គលម្នាក់ឯងរមែងមិនត្រេកអរ (ត្រេកអរតែងក្នុងការនៅប្រឡូកច្រឡំដោយពួក) ជនទាំងឡាយណា មិនមានបីតិ ដែលកើតអំពីវិវេកទេ ជនទាំងឡាយនោះ ទុកជាមានភោគៈ ស្មើដោយ

ព្រះឥន្ទ្រក៏ដោយចុះ ជនទាំងឡាយនោះ ក៏ឈ្មោះថាជាបុគ្គលកម្សត់មានសេចក្ដីសុខព្រោះកិរិយាអាស្រ័យនូវបុគ្គលដទៃដោយពិត។

ឥសី ៧ អង្គនេះ គឺឥសីឈ្មោះយាមហនុ ១ សោម-យាគៈ ១ មនោជវៈ ១ សមុទ្ទៈ ១ មាឃៈ ១ ភរតៈ ១ ឥសីឈ្មោះកាលបុរក្ខិតៈ ១ និងឥសីទាំងឡាយ ៤ អង្គ គឺ ឥសីឈ្មោះអង្គិរសៈ ១ កស្សបៈ ១ កីសវច្ឆៈ ១ អកន្តិ ១ ជាអនាគារបុគ្គលមានតបធម៌ បានកន្លង (កាមាវចរភូមិ) ដោយពិត។

នៅប្រទេសហិមវន្តខាងជើង មានស្ទឹងឈ្មោះសីទា មានជម្រៅដ៏ជ្រៅ អ្នកផងឆ្លងបានដោយកម្រ (ទាំងពីរខាងឆ្នេរស្ទឹងនោះ) មានភ្នំមាស ពណ៌ដូចភ្លើងខៀវ រុងរឿងសព្វ ៗ កាល។

(ទៀបឆ្នេរនៃស្ទឹងនោះ) សឹងមានដើមក្រឹស្នា លូតលាស់ទង្គំទង្គោល មានទាំងរុក្ខជាតិផ្សេងៗ មានគុម្ពលូតលាស់ (អំពីដើមបព៌ត) ក្នុងកាលមុន មានពួកឥសីចាស់ៗ មួយម៉ឺនអង្គ នៅក្នុងទីនោះឯង។

ខ្ញុំជាបុគ្គលប្រសើរដោយការឲ្យនិងការប្រព្រឹត្តវត្ត ដោយការសង្រួមនិងការទូន្មាន (នូវឥន្ទ្រិយ) ហើយប្រព្រឹត្ត (ម្នាក់ឯង) លះបង់ (ពួក) ជាអ្នកមានចិត្តតាំងមាំ ៗ ខ្ញុំមិនរិះគន់នូវជនអ្នកមានជាតិទាប និងមានជាតិខ្ពស់ នមស្ការចំពោះជន អ្នកមានចិត្តត្រង់ មិនមានកំណត់កាលវេលាឡើយ ព្រោះថា សត្វទាំងឡាយមានកម្មជាផៅពង្ស។

វណ្ណៈទាំងអស់ អ្នកមិនតាំងនូវក្នុងធម៌ រមែងធ្លាក់ចុះក្នុងនរក ជាខាងក្រោមវណ្ណៈទាំងអស់ បានប្រព្រឹត្តធម៌ដ៏ឧត្តមហើយ រមែងបរិសុទ្ធ។

មឃទេវរាជ សុជម្បតិ ទ្រង់ពោលពាក្យនេះ ទ្រង់ប្រៀនប្រដៅព្រះបាទនេមិជាធំក្នុងដែនវិទេហៈ រួចហើយទ្រង់ចៀសចេញ ទៅកាន់ពួកទេវតាក្នុងស្ថានសួគ៌។

(ព្រះឥន្ទ្រ...) ម្នាលអ្នកទាំងឡាយដ៏ចម្រើន អ្នកទាំងឡាយទាំងប៉ុន្មានដែលបានមកប្រជុំគ្នា ហើយក្នុងទីនេះ ចូរចាំស្តាប់នូវគុណខ្ពស់ និងទាបមានប្រមាណច្រើននេះ របស់មនុស្សទាំងឡាយ អ្នកប្រកបដោយធម៌ ៗ ដូចជាព្រះបាទនេមិអង្គនេះរបស់មនុស្សទាំងឡាយ ជាបណ្ឌិត

អ្នកត្រូវការដោយកុសល ជាព្រះរាជា ទូន្មាននូវសត្រូវ បាន ឲ្យទានដល់អ្នកដែនវិទេហៈទាំងឡាយគ្រប់ៗ គ្នា។

កាលដែលព្រះរាជាអង្គនោះ កំពុងឲ្យនូវទាននោះ សេចក្តីត្រិះរិះកើតឡើងថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណា មានផលច្រើនជាង។

**(មហាជន...)** ឱហ្ន៎ សេចក្តីព្រឺរោម មិនធ្លាប់កើតមាន ក៏កើតឡើយហើយ ក្នុងលោក រថទិព្វកើតប្រាកដហើយ ដល់ព្រះបាទវិទេហៈ មានយស។

**(អភិសម្ពុទ្ធគាថា)** មាតលិទេវបុត្រ អ្នកមានឫទ្ធិច្រើន ជាទេវសារថី បានអញ្ជើញព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលាថា បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គយាងមក ទ្រង់ស្តេចឡើងកាន់រថនេះ ដ្បិតទេវតាទាំងឡាយនៅស្ថានតាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយនោះ តែងរលឹក (ព្រះអង្គ) កំពុងនៅប្រជុំក្នុងធម្មសភា ឈ្មោះសុធម្មា។

លំដាប់នោះ ព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលា ទ្រង់មិ្ឌមា្នក្រោកចាកអាសនៈ បែរព្រះភក្ត្រកាន់រថ។

មាតលិទេវបុត្រ ទូលសួរព្រះបាទនេមិរាជនុ៎ះ ដែលស្តេចឡើងកាន់រថទិព្វហើយ ដូច្នេះថា បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំនាំព្រះអង្គ ទៅតាមផ្លូវណា តាមផ្លូវដែលសត្វមានបាបកម្ម ឬតាមផ្លូវដែលសត្វមានបុញ្ញកម្ម។

**(ព្រះបាទនេមិ...)** ម្នាលមាតលិទេវសារថី អ្នកចូរនាំខ្ញុំទៅតាមផ្លូវទាំងពីរ គឺផ្លូវដែលសត្វមានបាបកម្មផង ផ្លូវដែលសត្វមានបុញ្ញកម្មផង។

**(មាតលិ...)** បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំនាំព្រះអង្គទៅតាមផ្លូវណាមុន តាមផ្លូវដែលសត្វមានបាបកម្មមុនឬ ឬតាមផ្លូវដែលសត្វមានបុញ្ញ-កម្មមុន។

**(ព្រះបាទនេមិ...)** ខ្ញុំចង់ឃើញនរកជាទីនៃសត្វអ្នកមានបាបកម្មទាំងឡាយ ខ្ញុំចង់ឃើញស្ថាននៃសត្វអ្នកមានកម្មលាមក និងគតិនៃសត្វទ្រុស្តសីលទាំងឡាយមុន។

**(អភិសម្ពុទ្ធគាថា)** មាតលិទេវសារថី បង្ហាញព្រះរាជានូវស្ទឹងឈ្មោះវេតរណីដែលសត្វឆ្លងបានដោយកម្រ

ប្រកបព្រមដោយទឹកផ្សា ប្រែ កំពុងពុះ ក្តៅដូចអណ្តាតភ្លើង។

**១-ព្រះបាទនេមិ ទ្រង់ឃើញសត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី ជាទីធ្ងង់ឡើង បានដោយកម្រក្រៃលែង ហើយត្រាស់សួរមាតលិទេវសារថីថា**

ម្នាលទេវបុត្រ អ្នកបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ (សត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី) ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយនេះធ្លាក់ទៅកាន់ស្ទឹងវេតរណី តើពួកសត្វនេះ បានធ្វើបាបកម្មអ្វី?

**-មាតលិទេវសារថីដែលព្រះបាទនេមិសួរហើយក៏ព្យាករផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយទូលព្រះរាជានោះ ដែលទ្រង់មិនជ្រាបថា**

ពួកសត្វណាមានកម្លាំង មានធម៌ដ៏លាមក បៀតបៀនប្រទេចផ្តាសានូវពួកសត្វដែលមានកម្លាំងខ្សោយ ក្នុងជីវលោក ពួកសត្វមានកម្មលាមករមែងវង់បាប ពួកសត្វទាំងនោះឯង តែងធ្លាក់ទៅកាន់ស្ទឹងវេតរណី។

**២-(ព្រះបាទនេមិ...)** ពួកឆ្កែព្រៃសម្បុរសក្រហម និងពពាល ពួកត្មាតពួកក្អែក ជាសត្វគួរខ្លាច តែងទំពាស៊ី

(សត្វនរកដែលវាប្រទះឃើញ) ម្នាលទេវបុត្រ អ្នកបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ហ្វូងក្អែកតែងជញ្ជែងស៊ីនូវសត្វទាំងឡាយនេះ តើសត្វទាំងឡាយនេះ បានធ្វើបាបដូចម្តេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃកម្មដែលខ្លួនដឹង ទូលព្រះរាជាដែលមិនទ្រង់ជ្រាបថា**

សត្វទាំងឡាយណានីមួយ មានសេចក្តីកំណាញ់ស្វិតស្វាញ មានធម៌លាមកពេក អ្នកជេរប្រទេចបៀតបៀនប្រទូស្តសមណព្រាហ្មណ៍ សត្វអ្នកមានអំពើលាមកទាំងនោះ រមែងរងបាប ទើបហ្វូងក្អែក ជញ្ជែងស៊ីសត្វទាំងឡាយនោះ។

**៣-(ព្រះរាជា...)** សត្វនរកទាំងឡាយ មានសរីរៈឆេះសន្ធោសន្ធៅ ដើរលើផែនដីដែក ថែមទាំងនាយនិរយបាលសំពងដោយដំបងដែកទាំងឡាយ ដែលភ្លើងឆេះ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិ ទេវសារថីខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាលវាយដោយដំបង

ដួលដេកនេះ តើពួកសត្វទាំងនេះបានធ្វើបានដូចម្តេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹង ទូលព្រះរាជាដែលមិនទ្រង់ជ្រាបថា**

ជនទាំងឡាយមានបាបធម៌ ពេញបន្ទុក បៀតបៀនប្រទេចផ្តាសា នូវបុរសស្ត្រីដែលឥតបាបធម៌ ក្នុងជីវលោកឈ្មោះជា អ្នកមានបាបធម៌ពេញបន្ទុក ជនអ្នកមានកម្មលាមកទាំងនោះ រមែងរងបាប ជនទាំងឡាយនោះឯងហើយ ដែលនាយនិរយបាល បៀតបៀនដោយដំបង ដួលដេកនៅៗ

៤-(**ព្រះរាជា...**) ពួកសត្វនរកដទៃមានខ្លួនឆេះជុំវិញកំពុងទួញយំ (ធ្លាក់ទៅ)កាន់រណ្តៅរងើកភ្លើងហើយថ្ងូរ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយដែលធ្លាក់ទៅកាន់រណ្តៅរងើកភ្លើង ហើយថ្ងូរ តើសត្វទាំងឡាយនោះ បានធ្វើបាបដូចម្តេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏**

**ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជា ដែលមិនទ្រង់ជ្រាបថា**

ជនទាំងឡាយណានីមួយ ពោលអាងសាក្សី (កោង) ក្នុងហេតុនៃទ្រព្យរបស់ប្រជុំជន ហើយញុំាងទ្រព្យជា បំណុលនោះឲ្យវិនាស បពិត្រព្រះអង្គជាធំជាងជន ជនទាំង នោះញុំាងពួកជនឲ្យវិនាសហើយ ជនទាំងឡាយអ្នកមាន កម្មដ៏លាមកនោះ រមែងរងបាប ទើបជនទាំងឡាយនោះ ឯង (ធ្លាក់ទៅ) កាន់រណ្ដៅរងើកភ្លើងហើយថ្ងូរដូច្នេះៗ

**៥-(ព្រះរាជា)** ខ្ទះទង់ដែងធំ មានភ្លើងឆេះសន្ធោ សន្ធៅ រន្ទាលប្រចាលឆ្អៅប្រាកដជាក់ស្ដែង ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរ អ្នកពួកសត្វទាំងនេះ (មានក្បាលសំយុងចុះ) ធ្លាក់ទៅកាន់ ខ្ទះពេញដោយទឹកទង់ដែង តើពួកសត្វទាំងនេះធ្វើបាបដូច ម្ដេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយក៏ ព្យាករនូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា**

ជនទាំងឡាយណាមានធម៌ដ៏លាមកពេក បៀត បៀនប្រទេចផ្តាសានូវសមណៈ ឬព្រាហ្មណ៍ អ្នកមានសីល ជនអ្នកមានកម្មដ៏លាមកទាំងឡាយនោះ តែងរងនូវបាប ជនទាំងនោះ (មានក្បាលសំយុងចុះ) ធ្លាក់ទៅកាន់ខ្ទះ ពេញទៅដោយទឹកទង់ដែង។

៦-(**ព្រះរាជា...**) ពួកនាយនិរយបាល ត្របែងកនៃ សត្វនរក ហើយកាប់ពន្ទះបោះទៅក្នុងទឹកក្តៅ ម្នាលទេព បម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ចុះពួកសត្វដែលមានក្បាលដាច់ ហើយដេកនៅ នេះ តើសត្វពួកនេះ បានធ្វើបាបដូចម្តេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ ព្យាករនូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលទ្រង់មិនជ្រាបថា**

ជនទាំងឡាយណា ក្នុងជីវលោកមានបាបធម៌ពេញ បន្ទុក តែងចាប់បៀតបៀននូវសត្វស្លាបទាំងឡាយ បពិត្រ ព្រះអង្គជាធំជាងជន ជនទាំងឡាយនោះ បៀតបៀនហើយ នូវសត្វស្លាប ពួកជនមានកម្មលាមកនោះ រមែងរងនូវបាប

ជនទាំងឡាយនោះ មានក្បាលដាច់ហើយដេកនៅដូច្នោះ។

**៧-(ព្រះរាជា...)** ស្ទឹងនេះ មានទឹកច្រើន មានច្រាំងមិនជ្រៅ មានកំពង់ល្អរាបទាបហូរទៅ សត្វដែលមានសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយតែងផឹក ស្រាប់តែទឹកដែលសត្វទាំងឡាយនោះផឹកហើយក្លាយទៅជាអង្កាម ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ចុះទឹកដែលសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជាអង្កាមវិញ តើពួកសត្វទាំងនេះបានធ្វើនូវបាបអ្វី?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា**

ជនទាំងឡាយណា អ្នកមានកិច្ចការមិនបរិសុទ្ធលាយនូវស្រូវសុទ្ធដោយអង្កាម ឲ្យដល់អ្នកទិញ បានជាទឹកដែលជនទាំងឡាយនោះ កំពុងមានសេចក្តីក្តៅបៀតបៀនមានសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ ផឹកទៅក្លាយជាអង្កាមវិញ។

*៨-(ព្រះរាជា...) នាយនិរយបាលទាំងឡាយ ចាក់នូវសរីរៈទាំងពីរខាងនៃសត្វនរក ដែលកំពុងកន្ទក់កន្ទេញ ដោយព្រួញទាំងឡាយក៏មាន ដោយលំពែងទាំងឡាយក៏មាន ដោយលំពែងស្នែងក្របីទាំងឡាយក៏មាន ម្នាលទេពបម្រើ សេចក្តីភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាលបៀតបៀនហើយដោយលំពែង ដេកនៅដូច្នេះ តើពួកសត្វទាំងនេះបានធ្វើនូវបាបដូចម្តេច?*

***-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា***

*ជនទាំងឡាយណា ក្នុងជីវលោក ជាអ្នកមានកម្មមិនល្អ លួចយកនូវស្រូវ ទ្រព្យ ប្រាក់ មាស ទាំងសត្វចិញ្ចឹម ពពែ ចៀមនិងក្របី ដែលគេមិនឲ្យ ហើយធ្វើនូវការចិញ្ចឹមជីវិត ជនអ្នកមានកម្មដ៏លាមកទាំងនោះ រមែងរងនូវបាប ទើបពួកជនទាំងនោះ ត្រូវនាយនិរយបាលបៀតបៀនហើយ ដោយលំពែងដេកនៅដូច្នេះ។*

*៩-(**ព្រះរាជា...**) ហេតុអ្វី សត្វនរកទាំងឡាយនេះ មួយពួកត្រូវនាយនិរបាលចងកអូស ពួកដទៃត្រូវនាយនិរយបាលចិញ្រ្ចាំ ពួកដទៃទៀតត្រូវនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទី ដួលដេកនៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ជនទាំងឡាយដែលនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទី ហើយដួលដេកនៅ តើពួកជនទាំងនោះ បានធ្វើនូវបាបដូចម្តេច?*

***-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា***

*ជនទាំងឡាយណា ជាអ្នកសម្លាប់ទ្រាយ សម្លាប់ជ្រូក សម្លាប់ត្រី សម្លាប់សត្វចិញ្ចឹម គឺក្របី ពពែនិងចៀម ហើយដាក់លក់ឰដ៏រានផ្សារលក់សាច់  ជនអ្នកមានកម្មអាក្រក់ទាំងនោះ តែងរងបាប បានជាជនទាំងនោះ ត្រូវនាយនិរយបាលធ្វើឱ្យខ្ទេចខ្ទី ហើយដេកនៅ។*

*១០-(**ព្រះរាជា...**) អន្លង់នេះ ពេញពោរដោយមូត្រនិងករីស មានក្លិនអាក្រក់មិនស្អាតស្អុយផ្សាយទៅ ពួកជន*

អ្នកមានសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ ស៊ី (នូវមូត្រ និងករីសនេះ) ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនអ្នកបរិភោគនូវមូត្រ និងករីសនេះ តើពួកជនទាំងនេះបានធ្វើនូវបាប ដូចម្តេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា**

ជនទាំងឡាយណានីមួយជាអ្នកបង្កសេចក្តីទុក្ខ អ្នកបៀតបៀនមិត្រសម្លាញ់ អ្នកតាំងនូវក្នុងការបៀតបៀន នូវជនដទៃសព្វៗកាល ពួកជទាំងឡាយ មានអំពើលាមកនោះរមែងរងបាប ជនពាលទាំងឡាយជាអ្នកទ្រុស្តមិត្តនោះ តែងស៊ីអាហារចាស់ៗ

**១១-(ព្រះរាជា...)** អន្ទង់នេះ ពេញពោរទៅដោយឈាមនិងខ្ទុះ មានក្លិនអាក្រក់ មិនស្អាត ស្អុយផ្សាយទៅ ពួកសត្វដែលត្រូវកម្តៅបៀតបៀនហើយ ផឹក(ឈាមនិងខ្ទុះនោះ) ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាល

មាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលមានឈាមនិងខ្ទុះជាអាហារនេះ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជាដែលមិនជ្រាបថា**

ជនទាំងឡាយណា ក្នុងជីវលោកនេះ សម្លាប់ព្រះអរហន្ត គឺមាតាឬបិតា ឈ្មោះថាបារាជិក (ក្នុងភាពជាគ្រហស្ថ) ពួកជន អ្នកមានអំពើលាមកនោះ តែងរងបាប ជនទាំងនោះមានឈាមនិងខ្ទុះជាអាហារ។

**១២-(ព្រះរាជា...)** អ្នកចូរមើលនូវសត្វនរក មានអណ្តាតមុតដោយសន្ទូច បីដូចស្បែកដែលគេខ្ទារដោយកង្វេរ ញាប់ញ័រដូចត្រី ដែលជនបោះទៅលើគោក ព្រោះហេតុអ្វីហ្ន៎ បានជាសត្វនរកទាំងនោះ យំបង្ហៀរទឹកមាត់ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលស៊ីសន្ទូចដេកនៅ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច?

-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជាដែលមិនជ្រាបថា

មនុស្សទាំងឡាយណានីមួយ ឋិតនៅក្នុងតំណែងជាអ្នកកាត់ថ្លៃទំនិញ ញុំាងទំនិញដែលមានថ្លៃ ឲ្យសាបសូន្យចាកថ្លៃ (បន្ថោកទំនិញគេ) ប្រកបដោយអំពើកោង ធ្វើអំពើកោង ព្រោះហេតុចង់បានទ្រព្យ បីដូចជាសន្ទូចដែលគេបិទបាំង (ដោយនុយ) ដើម្បីសម្លាប់ត្រី។

ទីពឹងរបស់អ្នកធ្វើនូវអំពើកោង ជាបុគ្គលដែលកម្មរបស់ខ្លួនរួបរឹតហើយមិនមានទេ ពួកជនអ្នកមានអំពើលាមកនោះ តែងរងបាប បានជាពួកជនទាំងនោះ ជាអ្នកស៊ីសន្ទូចដេកនៅ។

**១៣-(ព្រះរាជា...)** ពួកស្ត្រីទាំងនេះ មានខ្លួនដាច់ខ្ទេចខ្ទី មានជាតិអាក្រក់ មានខ្លួនប្រឡាក់ ពាសពេញដោយឈាមនិងខ្ទុះ មានខ្លួនដាច់រយះរយាយ បីដូចគោទាំងឡាយ ដែលគេពន្ទះក្នុងទីសម្លាប់ ផ្គងដើមដៃទាំងឡាយយំកន្ទក់កន្ទេញពួកស្ត្រីទាំងនោះ (មានខ្លួនត្រឹមចង្កេះ) លិច

ចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំរមៀលកិន សព្វៗកាល ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិជាទេវសារថី ខ្ញុំសួរអ្នក ពួកស្ត្រីដែលមាន (ខ្លួន ត្រឹមចង្កេះ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំរមៀលកិនសព្វ ៗ កាល តើពួកស្ត្រីទាំងនេះ បានធ្វើ បាបដូចម្តេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជា ដែលមិនជ្រាបថា**

ពួកស្ត្រីត្រកូលក្នុងជីវលោកនេះ មានអំពើមិន បរិសុទ្ធ បានប្រព្រឹត្តនូវអំពើជារបស់អសប្បុរស ពួកស្ត្រីទាំង នោះ មានសភាពជាអ្នកលេងលះបង់ស្វាមីហើយ ត្រាច់ទៅ រកបុរសដទៃ ព្រោះហេតុតែកាមគុណនឹងល្បែងពាល ពួក ស្ត្រីទាំងនោះក្នុងជីវលោក លុះញ៉ាំងបុរសដទៃឲ្យត្រេក ត្រអាល ទើបមានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំរមៀលកិន ដូច្នេះៗ

**១៤-(ព្រះរាជា...)** ព្រោះហេតុអ្វី បានជាសត្វនរក

មួយពួកទៀតនេះ ត្រូវនាយនិរយបាលចាប់ជើង ឲ្យមានក្បាលសំយុងចុះ ហើយទម្លាក់ទៅក្នុងរណ្ដៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកសត្វទាំងនេះ ដែលមានក្បាលសំយុងចុះ នាយនិរយបាលទម្លាក់ទៅក្នុងរណ្ដៅនរក តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្ដេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជាដែលមិនជ្រាបថា**

ជនទាំងឡាយណា ក្នុងជីវលោកនេះ អ្នកមានអំពើជារបស់អសប្បុរស ប្រព្រឹត្តកន្លងនូវប្រពន្ធទាំងឡាយនៃជនដទៃ សត្វទាំងឡាយប្រាកដដូច្នោះនោះ ឈ្មោះថាជាអ្នកលួចនូវរបស់ដ៏ថ្លៃថ្លា បានជាសត្វទាំងនោះ (មានក្បាលសំយុងចុះ) ត្រូវនាយនិរយបាលទម្លាក់ទៅក្នុងរណ្ដៅ។

សត្វទាំងឡាយនោះ តែងរងនូវទុក្ខវេទនា ក្នុងនរកទាំងឡាយនោះ អស់ប្រជុំនៃឆ្នាំដ៏ច្រើន ព្រោះថាទីពឹងទាំងឡាយ របស់បុគ្គលអ្នកធ្វើបាប ជាបុគ្គលដែលកម្មរបស់ខ្លួន

រូបរឹតហើយ មិនមានទេ ពួកសត្វអ្នកមានអំពើលាមកនោះ រមែងរងនូវបាប ទើបបានជាពួកជនទាំងនោះ (មានក្បាលសំយុងចុះ) ត្រូវនាយនិរយបាលទម្លាក់ទៅក្នុងរណ្តៅ។

**១៩-(ព្រះរាជា...)** ពួកសត្វទាំងឡាយនេះ ខ្ពស់និងទាបផ្សេងៗគ្នា ជាអ្នកត្រដាបត្រដួស មានរូបគួរខ្លាចពន់ពេក ប្រាកដនៅក្នុងនរកទាំងឡាយ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលមានសេចក្តីទុក្ខវេទនា ក្តៅក្រហាយក្រៃលែងនេះ តើពួកសត្វទាំងនេះ បានធ្វើបាបដូចម្តេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្ម ដែលខ្លួនដឹងហើយ ទូលព្រះរាជាដែលមិនជ្រាបថា**

ជនទាំងឡាយណា ក្នុងជីវលោកនេះ មានទិដ្ឋិលាមកក្រៃលែង តែងធ្វើអំពើដ៏ស្និទ្ធ ព្រោះមោហៈ ទាំងបបួលអ្នកដទៃ (ឲ្យយល់) ក្នុងទិដ្ឋិទាំងឡាយនោះផង ជនទាំងឡាយនោះ មានទិដ្ឋិបាប រមែងរងបាប ទើបបានជា

ពួកជនទាំងនោះរងទុក្ខវេទនា ដ៏ក្លៀវក្លា ខ្លោចផ្សា ក្តៅក្រហាយក្រៃលែង។

បពិត្រព្រះរាជា ទីលំនៅរបស់សត្វអ្នកមានបាបកម្មទាំងឡាយ ស្ថានរបស់សត្វអ្នកមានអំពើអាក្រក់ទាំងឡាយ និងគតិរបស់សត្វ អ្នកទ្រុស្តសីលទាំងឡាយ ព្រះអង្គទ្រង់បានជ្រាបហើយ បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ធំ សូមទ្រង់ស្តេចទៅ ក្នុងសំណាក់ទេវរាជ ឥឡូវនេះ ៗ

**១-(ព្រះបាទនេមិ...)** វិមាននេះ មានកំពូលប្រាំ ដែលយើងឃើញប្រាកដ មាននាងនារី មានអានុភាពធំ ប្រដាប់ដោយកម្រងផ្កា សំដែងនូវទេវឫទ្ធិមានប្រការផ្សេង ៗ នៅកណ្តាលដំណេក ក្នុងវិមាននោះ ម្នាលទេពបម្រើ សេចក្តីរីករាយមានប្រាកដដល់ខ្ញុំ ក្នុងវិមាននោះ។

ម្នាលទេពបម្រើ សេចក្តីរីករាយមានប្រាកដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក នារីដែលបានដល់ស្ថានសួគ៌ហើយ រីករាយក្នុងវិមាន តើនារីនេះបានធ្វើនូវកុសលដូចម្តេច?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏**

ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា

ពិរណីដែលទ្រង់ធ្លាប់ជ្រាបហើយ ជាទាសីកើតហើយក្នុងផ្ទៃនៃទាសី ក្នុងផ្ទះនៃព្រាហ្មណ៍ ក្នុងជីវលោក នាងពិរណីនោះដឹងថា ភិក្ខុជាភ្ញៀវ មានកាលដល់ហើយ (ហើយក៏អង្គាសចង្ហាន់ប្រគេនភិក្ខុនោះ) ហាក់ដូចជាមាតាដែលត្រេកអរចំពោះបុត្តរបស់ខ្លួន នាងជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនាងរីករាយក្នុងវិមាន។

**២-(ព្រះបាទនេមិ...)** វិមានមាសទាំង ៧ ដែលបុញ្ញកម្ម តាក់តែងហើយ មានពន្លឺរុងរឿងផ្សព្វផ្សាយទៅ មានទេវបុត្រមានឫទ្ធិច្រើន ប្រដាប់ហើយដោយអាភរណៈគ្រប់បែប មានពួកនាងទេពធីតា ចោមរោមហើយ ដើរប្រទក្សិណដោយជុំវិញ ក្នុងវិមានទាំង ៧ នោះ។

ម្នាលទេពបម្រើ ខ្ញុំមានសេចក្តីត្រេកអរព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្តនេះ បានធ្វើនូវកុសលដូចម្តេច ទើបដល់នូវស្ថានសួគ៌ ហើយរីករាយក្នុងវិមាន?

-មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា

ទេវបុត្រនេះ ជាគហបតី ឈ្មោះសោណទិន្ន ជាម្ចាស់នៃទាន (ក្នុងដែនកាសី) គាត់បានសាងកុដិសម្រាប់នៅ ៧ ខ្នង ឧទ្ទិសចំពោះបព្វជិត។

គាត់បានបម្រើភិក្ខុទាំងឡាយ ដែលអាស្រ័យក្នុងកុដិនោះ ដោយគោរព បានប្រគេនចីវរសម្រាប់ស្លៀកដណ្តប់ផង ភត្តាហារផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះលោក អ្នកមានចិត្តត្រង់ទាំងឡាយ ដោយចិត្តជ្រះថ្លា។

គាត់រក្សាឧបោសថប្រកបដោយអង្គប្រាំបី អស់តិថីទី១៤ ផង តិថីទី១៥ ផង តិថីទី៨ នៃបក្ខផង បាដិហារិយ-បក្ខផង គាត់ជាអ្នកសង្រួមក្នុងសីលទាំងឡាយសព្វ ៗ កាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបគាត់រីករាយក្នុងវិមាន។

៣-(**ព្រះរាជា...**) វិមាននេះដែលបុញ្ញកម្មនិម្មិត

*ហើយ ដ៏រុងរឿងដោយជញ្ជាំង ជាវិការៈនៃកែវផលិក ពាស ពេញដោយពួកនារីដ៏ប្រសើរ រុងរឿងដោយផ្ទះកំពូល ប្រកបដោយទឹកនិងភោជន ដោយកិរិយារាំនិងច្រៀងទាំង ពីរ។*

*ម្នាលទេពបម្រើ ខ្ញុំមានសេចក្តីត្រេកអរព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើនារីទាំងនេះ បានធ្វើ កុសលកម្មដូចម្តេច ទើបដល់ស្ថានសួគ៌ហើយរីករាយក្នុង វិមាន?*

***-មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា***

*ពួកនារីណានីមួយក្នុងជីវលោកនេះមានសីល ជា ឧបាសិកា ត្រេកអរក្នុងទាន មានចិត្តជ្រះថ្លាជានិច្ច តាំងនៅ ក្នុងសច្ចធម៌ មិនប្រហែសធ្វេសក្នុងឧបោសថ ជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនារីទាំងនោះរីករាយក្នុងវិមាន។*

*៤-(**ព្រះរាជា...**) វិមានដែលបុញ្ញកម្មនិម្មិតហើយ ដ៏ រុងរឿងដោយជញ្ជាំងជាវិការៈនៃកែវពៃទូរ្យ ប្រកបដោយ*

*ភូមិភាគ ចែករាស់ដោយចំណែកៗ (ក្នុងវិមាននេះ) មានសូរសំឡេងទិព្យលាន់ឮគឺស្គរ សម្ភោរ កិរិយារាំ ច្រៀង និងប្រគំគួរស្ដាប់ ជាទីរីករាយនៃចិត្ត។*

*សំឡេងដែលប្រព្រឹត្តទៅយ៉ាងនេះពីរោះ យ៉ាងនេះពីមុនមក ខ្ញុំមិនដែលឃើញ ទាំងមិនដែលឮឡើយ ទើបតែបានដឹង។*

*ម្នាលទេពបម្រើ សេចក្ដីត្រេកអរមានដល់ខ្ញុំ ព្រោះបានឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើពួកទេវ-បុត្រទាំងនេះ ធ្វើកុសលកម្មដូចម្ដេច ទើបដល់ស្ថានសួគ៌ហើយរីករាយក្នុងវិមាន?*

***-មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា***

*ជនទាំងឡាយណា មានសីល ជាឧបាសក ក្នុងជីវ-លោកនេះ បានកសាងសួនច្បារ ស្រះ អណ្ដូងទឹក និងស្ពានប្រតិបត្តិព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រជាក់ ដោយគោរព ព្រមទាំងបានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង*

(គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយអ្នកមានចិត្ត ត្រង់ដោយចិត្តជ្រះថ្លា។

ជនទាំងឡាយនោះបានរក្សាឧបោសថ ប្រកបដោយអង្គប្រាំបី អស់តិថីទី១៤ ផង តថីទី១៥ ផង តិថីទី៨ នៃបក្ខផង បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វ ៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ និងជាអ្នកចែកទាន ទើបជនទាំងឡាយនោះរីករាយក្នុងវិមាន។

**៥-(ព្រះរាជា...)** វិមាននេះដែលបុញ្ញកម្មនិម្មិតល្អហើយ រុងរឿងដោយជញ្ជាំង ជាវិការៈនៃកែវផលិក ដេរដាសពួកនាងនារីដ៏ប្រសើរ ចម្រើនដោយផ្ទះកំពូល ប្រកបដោយទឹកនិងភោជន ដោយកិរិយារាំនិងច្រៀងទាំងពីរយ៉ាង មានស្ទឹងប្រកបដោយរុក្ខជាតិ មានផ្កាផ្សេងៗ ហួរព័ទ្ធជុំវិញ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានប្រាកដដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្រនេះបានធ្វើនូវកុសលកម្មដូចម្តេច ទើបដល់ស្ថានសួគ៌ ហើយរីករាយក្នុងវិមាន?

-មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា

ទេវបុត្រអង្គនុ៎ះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រជាក់ ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះពួកព្រះអរហន្តអ្នកមានចិត្តត្រង់ ដោយជ្រះថ្លា។

បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថីទី ១៤ ផង តិថីទី១៥ ផង តិថីទី៨ នៃបក្ខផង អស់បាដិហារិយ-បក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមនូវឥន្រ្ទិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន។

**៦-(ព្រះរាជា...)** វិមាននេះដែលបុញ្ញកម្មនិម្មិតល្អ ហើយ ដ៏រុងរឿងដោយជញ្ជាំងជាវិការៈនៃកែវផលិក ដេរដាសដោយពួកនារីដ៏ប្រសើរ ចម្រើនដោយផ្ទះកំពូល

ប្រកបដោយទឹកនិងភោជន ដោយការច្រៀងនិងការរាំទាំងពីរយ៉ាង មានស្ទឹងប្រកបដោយឈើ មានផ្កាផ្សេងៗ ហូរព័ទ្ធជុំវិញ មានឈើទាំងឡាយជាច្រើនគឺ ដើមកេស ខ្វិត ស្វាយ សាលព្រឹក្ស ព្រីង ទន្ទាប់ មាក់ប៉ែន សុទ្ធសឹងមានផ្លែជានិច្ច។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានប្រាកដដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្រអង្គនេះ បានធ្វើនូវកុសលកម្មដូចម្តេច ទើបដល់ស្ថានសួគ៌ រីករាយក្នុងវិមាន?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា**

ទេវបុត្រអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងមិថិលា បានកសាងសួនច្បារ ស្រះ អណ្តូងទឹក បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលជាអ្នកមានចិត្តត្រជាក់ បានថ្វាយនូវចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា។

គហបតីនោះបានទាំងរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថីទី១៤ ផង តិថីទី១៥ ផង តិថីទី៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗកាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន។

**៧-(ព្រះរាជា...)** វិមាននេះដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងហើយ ដោយជញ្ជាំងជាវិការៈនៃកែវពៃទូរ្យ ប្រកបដោយភូមិភាគចែក វាស់ដោយចំណែក (ក្នុងវិមាននោះ) មានសូរសព្ទជាទិព្យលាន់ឮ គឺស្គរ សម្ភោរ កិរិយារាំច្រៀង នឹងប្រគំ គួរស្តាប់ ជាទីរីករាយនៃចិត្ត។

សំឡេងដែលប្រព្រឹត្តទៅយ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែលឃើញ ទាំងមិនដែលឮឡើយ ទើបតែនឹងបានដឹង។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ស្ថានសួគ៌ ហើយរីករាយក្នុងវិមាន?

-មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា

ទេវបុត្រអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងពារាណសី បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលមានចិត្តត្រជាក់ បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា។

ទេវបុត្រនោះ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថីទី១៤ ផង តិថីទី១៥ ផង តិថីទី៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗកាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបទេវ-បុត្រនោះ រីករាយក្នុងវិមាន។

**៨-(ព្រះរាជា...)** វិមាននេះ ជាវិការនៃមាសដែលបុញ្ញកម្មនិម្មិតហើយ ដូចព្រះអាទិត្យទើបរះឡើង មានពណ៌ក្រហម មានមណ្ឌលធំ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានប្រាកដដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន?

**-មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ព្យាករនូវផល នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា**

ទេវបុត្រអង្គនេះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងសាវត្ថី បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលមានចិត្តត្រជាក់ បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា។

គហបតីនោះ បានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់តិថីទី១៤ ផង តិថីទី១៥ ផង តិថីទី៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗកាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើប

គហបតីនោះ រីករាយក្នុងវិមាន។

៩-(**ព្រះរាជា...**) វិមានទាំងឡាយនេះ ជាវិការនៃមាស មានប្រមាណច្រើន ដែលបុញ្ញកម្មនិម្មិតហើយ តាំងនៅក្នុងអាកាស មានពន្លឺដ៏រុងរឿង ដូចជាផ្លេកបន្ទោរ ក្នុងចន្លោះនៃមេឃ ក្នុងវិមានទាំងឡាយនោះ មានពួកទេវតាមានឫទ្ធិច្រើន សឹងប្រដាប់ដោយគ្រឿងអាភរណៈគ្រប់បែប មានពួកនាងទេពអប្សរចោមរោមហើយ ប្រទក្សិណ វិលវង់ដោយជុំវិញ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិ ទេវសារថី ខ្ញុំសួរអ្នក ទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន?

**-មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា**

ពួកទេវបុត្រទាំងនោះ ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធតាំងនៅស៊ប់ ដោយសទ្ធាក្នុងព្រះសទ្ធម្មដែល

ព្រះមានព្រះភាគទ្រង់ប្រកាសទុកល្អហើយ បានធ្វើតាមនូវពុទ្ធវចនៈរបស់ព្រះសាស្តា បពិត្រព្រះរាជា ឋានទាំងឡាយដែលទ្រង់ក្រឡេកឃើញហើយ គឺជាឋានរបស់ទេវបុត្រទាំងឡាយនោះ។

បពិត្រមហារាជ ស្ថានរបស់សត្វអ្នកមានបាបកម្ម ទ្រង់បានជ្រាបហើយ ព្រោះទ្រង់ទតឃើញនូវលំនៅ (របស់សត្វ) ទាំងឋានរបស់សត្វអ្នកមានកល្យាណកម្ម ក៏ទ្រង់ជ្រាបហើយ បពិត្រព្រះរាជាទ្រង់ស្វែងរកកុសលធម៌ ឥឡូវនេះ សូមទ្រង់យាងទៅក្នុងសំណាក់នៃទេវរាជ។

(**អភិសម្ពុទ្ធគាថា**) ព្រះបាទនេមិមហារាជ ទ្រង់ឋិតនៅលើទិព្វយាន មានសេះជាវាហនៈ ដែលទឹមដោយសេះសិន្ធព ១ ពាន់ កាលស្តេចកំពុងយាងទៅ ទ្រង់ក្រឡេកឃើញភ្នំទាំងឡាយ ក្នុងចន្លោះសីទន្តរសមុទ្ទ លុះទ្រង់ទតឃើញហើយ ទ្រង់ត្រាស់ហៅទេវសារថីសួរថា ភ្នំទាំងនោះតើឈ្មោះអ្វី?

(**មាតលិ...**) ភ្នំធំៗទាំងឡាយនេះ ក្នុងសមុទ្ទសីទន្តរ គឺភ្នំសុទស្សនៈ ១ ករវិក ១ ឥសិន្ធរ ១ យុគន្ធរ ១ នេមិន្ធរ ១

*វិនតក ១ អស្សកណ្ណ ១ ជាភ្នំមានកំពូលខ្ពស់ឡើងតាមលំដាប់រៀងគ្នា[៦] បពិត្រមហារាជទាំងឡាយ ភ្នំដែលទ្រង់*

---

*[៦]. ខ្ញុំព្រះករុណាឈ្មោះថា* ***ព្រះពុទ្ធរក្ខិតាចារ្យ*** *នឹងសូមធ្វើព្រះបាលី និងអដ្ឋកថា ឲ្យសមគ្នាតាមសេចក្ដីពិត គឺកាល**មាតលីទេវសារថី**នាំ**ព្រះបាទនេមិរាជ**ទៅទស្សនាឋាននរក។* ***សក្កទេវរាជ*** *ទ្រង់ត្រិះរិះថា ហេតុអ្វី បានជា**មាតលី**យឺតយូរ ទើបទ្រង់បញ្ជូនទេវបុត្រមួយអង្គទៀតទៅតាម ។*

*គ្រានោះ* ***មាតលីទេវសារថីបររថ*** *ហោះឆ្ពោះទៅទេវលោក តពីនោះ ក្នុងវេលាដែល**មាតលីទេវសារថីបររថ**នោះ ទៅដល់កំពូល**ភ្នំសុទស្សនៈ*** ***ព្រះបាទនេមិរាជ****ទតព្រះនេត្រខាងមុខ និងខាងក្រោយ ទ្រង់ឃើញភ្នំទាំងនោះ ឋិតនៅជាលំដាប់គ្នា ទើបត្រាស់សួរ* ***មាតលីទេវសារថី****ថា "ភ្នំទាំងនេះឈ្មោះអ្វី ?"។*

*ភ្នំដែលឋិតនៅត្រង់កណ្ដាលភ្នំទាំង៧គឺភ្នំឈ្មោះ**សុទស្សនៈ*** ***មាតលីទេវសារថី****កាលក្រាបទូលប្រាប់ភ្នំដែលឋិតនៅខាងមុខបន្ទាប់ពី**ភ្នំសុទស្សនៈ** ទើបក្រាបទូលតាមលំដាប់ទៅខាងមុខថា "**ភ្នំសុទស្សនៈ, ករវីកៈ, ឥសិន្ធរ, យុគន្ធរ**" កាលនឹងក្រាបទូលប្រាប់ភ្នំដែលហួសពីនោះ ទើបក្រាបទូលតាមលំដាប់តាំងពីភ្នំដែលឋិតនៅថា "**នេមិន្ធរ, វិនតកៈ, អស្សកណ្ណៈ**" ។*

*ក្រឡេក សឹងជាលំនៅនៃមហារាជទាំងឡាយ។*

***(ព្រះរាជា...)*** *(ទ្វារ) មានរូបជាអនេក ដ៏រុងរឿង វិចិត្រដោយរតនវត្ថុផ្សេង ៗ ដ៏ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ បីដូចជា (ព្រៃធំ) ដែលពួកខ្លាធំចាំនៅ*

---

*កាលបើដូច្នេះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងដោយទំនងតាមដែល**មាតលីទេវសារថី**ពោល ទើបត្រាស់យ៉ាងនោះដែរ ចំណែកក្នុង**គម្ពីរវិសុទ្ធិមគ្គ ព្រះពុទ្ធឃោសាចារ្យ**មានបំណងនឹងពោលតាមលំដាប់ តាំងតែពីភ្នំដែលនៅក្នុងចន្លោះ ទើបពោលគាថាថា "**យុគន្ធរោ**" ជាដើម ។*

*ព្រះបាលីក្នុង**នេមិរាជជាតក និងវិសុទ្ធិមគ្គអដ្ឋកថា** រមែងចុះសម្រុងគ្នាស្មើគ្នាដោយពិត ព្រោះហេតុនេះ ដូចដែលពោលមកនេះ ដូចទឹកក្នុង**ទន្លេយមុនា**ចូលគ្នានឹងទឹកក្នុង**ទន្លេគង្គា** ។*

*ចំណែកពាក្យណា ដែលលោកពោលទុកក្នុង **អដ្ឋកថានេមិរាជជាតក**ថា* "សុទស្សនោ ឥតិ អយំ មហារាជ ឯតេសំ សព្វពាហិរោ សុទស្សនបព្វតោ នាម" *ពាក្យថា **សុទស្សនៈ** សេចក្តីថា បពិត្រមហារាជ ភ្នំដែលតាំងនៅខាងក្រៅទាំងអស់នៃភ្នំទាំងនោះ ឈ្មោះថា **ភ្នំសុទស្សនៈ** ពាក្យនោះ គប្បីយល់ថា លោកពោលទុកដោយភ្ជាត់មាត់។*

ហើយ។

ម្នាលទេពបម្រើ សេចក្ដីត្រេកអរកើតមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិ ទេវសារថី ខ្ញុំសួរអ្នក គេហៅថាទ្វារនេះ ឈ្មោះអ្វី ទើបជាទីរីករាយនៃចិត្ត ប្រាកដអំពីចម្ងាយ?

**-មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ព្យាករនូវផល នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា**

ទ្វារនេះឈ្មោះថាចិត្តកូដ ជាទីចេញចូលនៃទេវរាជ (ជាទ្វារនៃទេពនគរ ដែលតាំងនៅត្រង់ ទីបំផុតនៃភ្នំព្រះសុមេរុ) ជាភ្នំគួរឲ្យចង់មើលប្រាកដ (ទ្វារនេះ) មានរូបជាអនេក ដ៏រុងរឿង វិចិត្រដោយរតនវត្ថុផ្សេងៗ ប្រាកដជាទ្វារដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ បីដូចជា (ព្រៃធំ) ដែលពួកខ្លារក្សាហើយ បពិត្រព្រះរាជា ទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅតាមទ្វារនុ៎ះ សូមទ្រង់ជាន់នូវផែនដីទិព្វដ៏រាបស្មើ។

(**អភិសម្ពុទ្ធគាថា**) ព្រះបាទនេមិមហារាជ ទ្រង់បិត

*នៅលើទិព្វយាន មានសេះជាវាហនៈ ដែលទឹមដោយសេះសិន្ធព ១ ពាន់ទ្រង់យាងទៅ បានទតឃើញនូវទេវសភា (ត្រាស់សួរថា) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដោយជញ្ជាំងជាវិការនៃកែវពៃទូរ្យ ឃើញច្បាស់ ដូចអាកាសមានពន្លឺខៀវ ក្នុងសរទកាល។*

**(ព្រះរាជា...)** *ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំ ព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក គេហៅវិមានទុំះឈ្មោះអ្វី?*

***-មាតលិទេវសារថី ដែលព្រះបាទនេមិ សួរហើយ ក៏ព្យាករនូវផល នៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា***

*ទេវសភា ដែលព្រះអង្គទតឃើញទុំះឯង គេហៅថា សុធម្មា (ទេវសភាទុំះ) រុងរឿងដោយកែវពៃទូរ្យដ៏វិចិត្រ ដែលបុញ្ញានុភាពនិម្មិតដោយប្រពៃតាំងនៅ សសរមានជ្រុងប្រាំបី ដែលបុញ្ញកម្មតាក់តែងល្អ សុទ្ធសឹងជាវិការនៃកែវពៃទូរ្យទាំងអស់ ពួកទេវតានៅជាន់តាវត្តិង្សគ្រប់អង្គ សឹងមានព្រះឥន្ទ្រជាប្រមុខ តែងប្រជុំគ្នាគិតគូរសេចក្តីចម្រើនរបស់ទេវតា*

និងមនុស្សទាំងឡាយ បពិត្រព្រះរាជា ទ្រង់ស្វែងរកគុណ-ធម៌ សូមទ្រង់ចូលទៅកាន់ទីអនុមោទនារបស់ទេវតាទាំងឡាយ តាមទ្វារនេះ។

(**អភិសម្ពុទ្ធគាថា**) ពួកទេពនិករ បានឃើញព្រះរាជានោះ ស្តេចយាងមកដល់ហើយ ត្រេកអរទទួលថា

បពិត្រមហារាជ ដំណើរដែលព្រះអង្គយាងមកនេះ ប្រពៃហើយ មិនមែនទ្រង់យាងមកអាក្រក់ទេ បពិត្រព្រះរាជា ទ្រង់ស្វែងរកនូវគុណធម៌ដ៏ប្រសើរ ឥឡូវនេះ សូមព្រះអង្គគង់ក្នុងទីជិតនៃទេវរាជចុះ។

សក្កទេវរាជ ទ្រង់ត្រេកអរទទួលព្រះបាទវិទេហៈគ្រប់គ្រងក្រុងមិថិលានោះ ព្រះបាទវាសវៈអញ្ជើញព្រះអង្គដោយកាមទាំងឡាយ ដោយអាសនៈផងថា

ព្រះអង្គស្តេចមកដល់លំនៅនៃទេវតាទាំងឡាយ ជាដំណើរប្រពៃណាស់ ព្រះរាជាទ្រង់ស្វែរកនូវគុណដ៏ប្រសើរ សូមព្រះអង្គគង់នៅក្នុងទេវលោកទាំងឡាយ ជាទីញុំាងសេចក្តីប្រាថ្នាទាំងពួងឲ្យសម្រេច សូមព្រះអង្គបរិភោគកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្ស ក្នុងតាវត្តិង្សទេវ-

លោកចុះ។

**(ព្រះបាទនេមិ...)** វត្ថុណាដែលបានដោយអ្នកដទៃឲ្យជាបច្ច័យ ដូចយានរបស់សូមគេ ដូចទ្រព្យជារបស់សូមគេ វត្ថុនុ៎ះ ក៏មានឧបមេយ្យយ៉ាងនេះឯង។

ខ្ញុំឥតចង់បានវត្ថុ ដែលបានមកដោយអ្នកដទៃឲ្យជាបច្ច័យនោះទេ បុណ្យទាំងឡាយ ដែលខ្ញុំបានធ្វើហើយដោយខ្លួនឯង នោះទើបជាទ្រព្យសម្រេចដល់ខ្ញុំ។

ខ្ញុំនឹងត្រឡប់ទៅធ្វើ ជាកុសលដែលបុគ្គលធ្វើហើយរមែងដល់សេចក្ដីសុខ មិនក្ដៅក្រហាយខាងក្រោយ ឲ្យមានប្រមាណច្រើន ដោយការឲ្យផង ដោយការប្រព្រឹត្តស្មើផង ដោយសង្រួមឥន្ទ្រិយផង ដោយការទូន្មានទូវឥន្ទ្រិយផងក្នុងពួកមនុស្ស។

មាតលិជាទេវសារថីដ៏ចម្រើន ជាអ្នកមានឧបការៈច្រើនដល់យើង ព្រោះបានបង្ហាញនូវឋាននៃសត្វអ្នកមានបុញ្ញកម្ម និងស្ថាននៃសត្វអ្នកមានបាបកម្មទាំងឡាយ។

ព្រះបាទនេមិ ទ្រង់ជាឥស្សរៈក្នុងដែនវិទេហៈ គ្រប់គ្រងក្រុងមិថិលា ទ្រង់បានពោលដូច្នេះហើយ (ទើបទ្រង់លាសក្កទេវរាជត្រឡប់មកមនុស្សវិញ) ទ្រង់បានបូជាយញ្ញៈដ៏ច្រើនហើយទ្រង់ចូលទៅកាន់ការសង្រួម (បព្វជ្ជា)។

ចប់ នេមិរាជជាតក។

(បិដកលេខ ៦២ ទំព័រ ៦៨)

## ៤.៣.នេមិរាជចរិយា

ចរិយាដទៃទៀត កាលដែលតថាគតកើតជាស្តេចធំ ឈ្មោះនេមិ ជាបណ្ឌិត អ្នកត្រូវការដោយកុសល នៅក្នុងក្រុងដ៏ប្រសើរ ឈ្មោះមិថិលា។

កាលនោះ តថាគត បានឱ្យគេស្ថាបនាសាលាបួនខ្នង មានមុខ ៤ ហើយញ៉ាំងទាន ឱ្យប្រព្រឹត្តទៅ ដល់ពួកម្រឹគ បក្សី និងមនុស្សជាដើម ក្នុងសាលានោះ។

តថាគតបាន ធ្វើនូវសំពត់សម្រាប់ស្លៀកដណ្តប់ ទីដេក បាយ ទឹក និងភោជន ឱ្យជារបស់ប្រព្រឹត្តទៅមិនដាច់ ហើយញ៉ាំងមហាទាន ឱ្យប្រព្រឹត្តទៅ។

សេវកាមាត្យ ចូលទៅរកចៅហ្វាយនាយ ព្រោះហេតុចង់បានទ្រព្យ ហើយស្វែងរកហេតុ ដែលគួររីករាយដោយកាយ ឬដោយវាចា ចិត្ត ( ផ្គាប់ចិត្តចៅហ្វាយនាយ ) យ៉ាងណា។ តថាគតនឹងស្វែងរកនូវពូជនៃពោធិញ្ញាណក្នុងភពទាំងពួង ញ៉ាំងសត្វឱ្យស្កប់ស្កល់ដោយទាន ហើយប្រាថ្នានូវពោធិញ្ញាណដ៏ឧត្តម យ៉ាងនេះឯង។

ចប់ នេមិរាជចរិយា ។

(បិដកលេខ ៧៧ ទំព័រ ២៤៨)

## ៥.ធម្មសោណ្ឌកមហារាជវត្ថុ

សម្តែងរឿងព្រះបាទធម្មសោណ្ឌកមហារាជក្នុងវគ្គទី១ តាមបទបាលីដូច្នេះថា ៖

**អម្ហាកំ ភគវតោ** ជាដើម អធិប្បាយ កាលពីមុនព្រះមានព្រះភាគជាព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់នៃយើង ពុំទាន់បានត្រាស់ដឹងនៅឡើយ គ្រានោះ ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈ ព្រះអង្គបានត្រាស់ឡើងប្រាកដ ក្នុងភទ្ទកប្បនេះ តែងសម្តែងធម៌ទេសនាប្រោសវេនេយ្យសត្វឲ្យបានសម្រេចដល់ព្រះនិព្វាន តាមកំណត់ដូចព្រះសម្មាសម្ពុទ្ធអំពីបុរាណរៀងមក ហើយព្រះអង្គទ្រង់ចូលបរិនិព្វានទៅ។

លុះដល់សាសនារបស់ព្រះមានព្រះភាគអង្គនោះវិនាសសាបសូន្យបាត់បង់ទៅមិនយូរប៉ុន្មាន កាលនោះ ព្រះបរមពោធិសត្វជាអម្ចាស់នៃយើង ព្រះអង្គកំពុងកសាងសន្សំបន្ទុំបារមីនៅឡើយ ព្រះអង្គបានច្យុតចុះចាកទេវ-លោក មកចាប់បដិសន្ធិក្នុងផ្ទៃព្រះអគ្គមហេសីនៃស្តេចពារាណសី ជាស្តេចឧត្តមខ្ពង់ខ្ពស់ប្រសើរជាងស្តេចទាំងពួង

ក្នុងជម្ពូទ្វីប។

ក្នុងកាលដែលព្រះបរមពោធិសត្វនៅក្នុងផ្ទៃព្រះមាតា គ្រប់ ១០ ខែបរិបូណ៌ហើយ ក៏ប្រសូតចេញចាកផ្ទៃព្រះមាតានោះក៏ជាអស្ចារ្យ មានធម្មសញ្ញា សេចក្ដីសំគាល់ក្នុងធម៌ បណ្ដាលឲ្យកើតឡើងក្នុងចិត្តនៃសត្វរាល់រូបសត្វទាំងនោះ សឹងមានប្រាថ្នាចង់ស្ដាប់ធម៌គ្រប់ ៗ គ្នា ក្នុងកាលនោះដែរ។

ព្រោះហេតុនោះ ព្រះបរមក្សត្រិយ៍ជាព្រះវរមាតាបិតា ព្រមទាំងព្រះរាជវង្សានុវង្សបានសន្មតព្រះនាមថា **ធម្មសោណ្ឌកកុមារ** ក្នុងកាលនោះឯង។ ព្រះរាជកុមារនោះបានចម្រើនដោយយសបរិវារជាច្រើន លុះដល់វ័យធំឡើងហើយ ក៏បានសិក្សារៀនសិល្បសាស្ត្រទាំងពួងចេះចាំស្ទាត់សម្ដេចព្រះវររាជបិតា ទ្រង់ប្រទានឋានន្តរសក្តិជាព្រះមហាឧបរាជ។ ព្រះធម្មសោណ្ឌកឧបរាជ ព្រះអង្គតែងបំពេញកុសលកម្មបថទាំង ១០ និងបុញ្ញកិរិយាវត្ថុ ១០ មានទានជាដើម លុះអំណឹះពីសម្ដេចវររាជបិតាហើយ ក៏សេនាបតីនិងព្រាហ្មណ៍បុរោហិត ចាត់ចែងថ្វាយរាជសម្បត្តិអភិសេក

ឧបរាជជាព្រះបរមក្សត្រិយ៍ស្នងសម្ដេចព្រះវររាជបិតា ក្នុងកាលនោះ។

ចំណែកឯព្រះឧបរាជបរមពោធិសត្វបានសោយរាជសម្បត្តិជាស្ដេចដ៏ប្រសើរ ទ្រង់ព្រះនាមព្រះបាទ **ធម្ម-សោណ្ឌកមហារាជ** មានព្រះកិត្តិគុណ ល្បីល្បាញប្រាកដស្មើដោយស្ដេចព្រះបរមចក្រពត្តិ ក្នុងនគរពារាណសី។ នគរនោះក៏រុងរឿងប្រាកដដូចទេវនគរ លុះព្រះអង្គគ្រងរាជសម្បត្តិកន្លងទៅបានកន្លះខែហើយ ស្ដេចគង់នៅលើទីក្រឡាព្រះបន្ទំដ៏មានសិរីសួស្ដី ហើយទ្រង់រំពឹងពិចារណានូវហេតុផ្សេង ៗ ជាដើមថា ៖

១. បុញ្ញេន សីលាធិមយេន បុព្វេ,
កតេន បត្តោស្មិ អតន្ទិតេន,
មសក្កសារេ វិយ ទេវរាជា;
រាជត្តមិទ្ធេ បុរមុត្តមម្ហិ។

២. រូបេន ហារីនយនុស្សវេន,
សទ្ទេន សម្មា សវណាមតេន,
គន្ធេន ឃានុស្សវសោភនេន,
រសេញ្ញបុញ្ញេន រសេនចាបិ។

៣. ផស្សេន គត្តស្ស សុខស្សទេន,

សមិទ្ធិបត្តោស្មិ មហិទ្ធិកោហំ,
នេវត្ថិកោនេវ បមាទការ,
មា បដ្ឋិតុំ យុត្តរូបន្តិ ញត្វា។
៤. នស្សាមិ អង្គអបិ ជីវិតញ្ច,
នញ្ញំ ជនំ ចាបិ បសន្នចិត្តោ,
សោស្សាមិ ធម្មំ សិរមាទធានំ,
ជិនេរិតំ ជាតិជរាបហាណំ។
៥. ន សោភតិ យថាកាសំ, ជលំ ធាមបតីវិនា,
រជ្ជការណំ តថា មយ្ហំ, វិនា ធម្មា ន សោភតិ។
៦. ន សោភតិ ហថា រត្តិ, និសានាថំ វិនា សទា,
រជ្ជការណំ តថា មយ្ហំ, វិនា ធម្មា ន សោភតិ។
៧. អលង្កតោបិ ចេ ហត្ថី, វិនា ទាហា ន សោភតិ,
រជ្ជការណំ តថា មយ្ហំ, វិនា ធម្មា ន សោភតិ។
៨. យថា កល្លោលមាលីយំ,
វិនា វេលា ន សោភតិ,
រជ្ជការណំ តថា មយ្ហំ,
វិនា ធម្មា ន សោភតិ។
៩. យថា សុមណ្ឌិតោ រាជា,
កុបជោ នេវ សោភតិ,
រជ្ជការណំ តថា មយ្ហំ,
វិនា ធម្មា ន សោភតិ។

១០. ជម្មមេវ សុណិស្សាមិ, ជម្មេ មេ រមតី មនោ,
ន ហិ ជម្មា បរំ អត្ថិ, ជម្មមូលំ តិសម្បទន្តិ។

*កិរិយាដែលអាត្មាអញបានសោយរាជសម្បត្តិ ដ៏មានសិរីយ៉ាងនេះ ហើយប្រាសចេញចាកព្រះធម៌ពុំបានស្តាប់ព្រះធម៌ដូច្នេះ ដូចជាអាកាសដែលប្រាសចាកព្រះអាទិត្យពុំមានវត្ថុអ្វីអាចបំភ្លឺលោក ដូច្នោះដែរ។*

*លុះទ្រង់រំពឹងដូច្នេះហើយ ក៏រំពឹងតទៅទៀតថា*

*អាត្មាអញបានរាជសម្បត្តិប្រសើរយ៉ាងនេះ ព្រោះតែបុណ្យ ដែលពុំបានខ្ជិលច្រអូស ខំឧស្សាហ៍ ខ្វល់ខ្វាយបំពេញបុញ្ញកិរិយាវត្ថុ មានទានសីលជាដើមពីមុនមក គឺដោយរាជឫទ្ធិដ៏ស្តុកស្តម្ភដូចជាទេវរាជ ដែលបានសោយសម្បត្តិទិព្វក្នុងទេវនគរដោយពិត។*

*ម្យ៉ាងទៀត អាត្មាអញមានអានុភាពបានសម្រេចដោយសម្បត្តិទាំងឡាយគឺរូបជាទីគាប់ចិត្ត សំឡេងពីរោះគួរចង់ស្តាប់ដោយប្រពៃ គ្រឿងក្រអូបគួរដល់កិរិយាហិតស្រូបយកក្លិនជាទីពេញចិត្ត រសអាហារឆ្ងាញ់ពិសាគួរជញ្ជាប់ជ្រួតជ្រាបដោយអណ្តាត សម្ផស្សដ៏ទន់ត្រជាក់ស្រួល*

គួរប៉ះពាល់ដោយកាយ ដូច្នេះអាត្មាអញនឹងកាន់សេចក្តីប្រមាទ ដោយសម្បត្តិមានប្រមាណប៉ុណ្ណេះពុំគួរសោះឡើយ គួរតែលះបង់ឲ្យទានខ្លួន ឬនឹងឲ្យទានជីវិត ឲ្យទានស្រូវអង្ករ ព្រមទាំងសម្បត្តិទ្រព្យដល់ស្មូមទាំងឡាយ ទើបប្រពៃ។

តមក ព្រះអង្គមានព្រះរាជហឫទ័យ ជ្រះថ្លាប្រាថ្នាចង់ស្តាប់ព្រះធម៌ទេសនាដែលព្រះជិនស្រីទ្រង់សម្តែងតែងតាំងទុកមក ជាធម៌ឲ្យនូវព្រះនិព្វានជាទីក្សេមចាកយោគៈ ជាធម៌អាចប្រហារបង់នូវជាតិជរាព្យាធិនិងមរណៈឲ្យអស់ទៅដោយពិត។

ម្យ៉ាងទៀត អណ្តូងស្រះប្រាសចាកទឹកភ្លៀង មិនមានទឹកដក់នៅ មិនរុងរឿងល្អមានឧបមាយ៉ាងណា កិរិយាដែលអាត្មាអញសោយរាជ្យជាស្តេច ហើយប្រាសចាកព្រះធម៌ ពុំបានស្តាប់ធម៌ទេសនា ក៏ពុំរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ។

រាត្រីប្រាសចាកព្រះចន្ទជាទីពឹង ទិសមិនរុងរឿងល្អមានឧបមាយ៉ាងណា កិរិយាដែលអាត្មាអញសោយរាជ្យជា

ស្ដេច ហើយប្រាសចាកព្រះធម៌ ពុំបានស្ដាប់ធម៌ទេសនា ក៏មិនរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ។

ដំរីអាជានេយ្យដ៏ប្រសើរដែលចងគ្រឿងប្រដាប់ ហើយប្រាសចាកក្ដុក មិនរុងរឿងល្អមានឧបមាយ៉ាងណា កិរិយាដែលអាត្មាអញសោយរាជ្យជាស្ដេច ហើយប្រាសចាកព្រះធម៌ ពុំបានស្ដាប់ធម៌ទេសនា ក៏មិនរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ។

ទឹកសមុទ្រប្រាសចាកត្រើយ មិនរុងរឿងល្អមានឧបមាយ៉ាងណា កិរិយាដែលអាត្មាអញសោយរាជ្យជាស្ដេចហើយប្រាសចាកព្រះធម៌ ពុំបានស្ដាប់ព្រះធម៌ទេសនា ក៏មិនរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ។

ព្រះបរមក្សត្រិយ៍មានគ្រឿងប្រដាប់ដ៏ល្អហើយទ្រង់ព្រះពស្ត្រដាចអាក្រក់ មិនរុងរឿងល្អមានឧបមាយ៉ាងណា កិរិយាដែលអាត្មាអញសោយរាជ្យជាស្ដេច ហើយប្រាសចាកព្រះធម៌ ពុំបានស្ដាប់ធម៌ទេសនា ក៏មិនរុងរឿងល្អមានឧបមេយ្យយ៉ាងនោះដែរ។

បើដូច្នេះ គួរតែអញស្វែងរកស្ដាប់ព្រះធម៌ទេសនា

ត្រាតែបាន លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏មានព្រះហឫទ័យចង់ស្តាប់ព្រះធម៌ដែលជាធម៌បណ្តុះបណ្តាលឲ្យបានសម្បត្តិទាំង ៣ ប្រការគឺសម្បត្តិមនុស្ស ១ ទេវតា ១ ព្រះនិព្វាន ១ ពុំចេះដាច់ឡើយ។

**ឯវំ ចិន្តេត្វា ចាតោវ** ព្រះនរិន្ទ្រាធិបតី បរមពោធិសត្វ ព្រះអង្គទ្រង់ពិចារណាយ៉ាងនេះហើយ លុះវេលាព្រឹកព្រាងស្វាងព្រះសុរិយា ព្រះអរុណភ្លឺច្បាស់ស្រឡះហើយ ព្រះអង្គទ្រង់យាងចេញអំពីទីសេយ្យាសន៍ដ៏មានសិរីសួស្តី ចេញទៅប្រថាប់នាចុងព្រះរាជរោង ដ៏មានពួកអាមាត្យចោមរោមគាល់បម្រើដោយជុំវិញ ស្តេចគង់នៅលើរាជបល្ល័ង្កដ៏ប្រសើរ ដែលមានស្វេតច្ឆត្រ គឺបុគ្គលលើកឡើងបើកបាំងពីលើ ដ៏ប្រដាប់ដោយកែវទាំង ៧ ប្រការដ៏រុងរឿងដូចព្រះឥន្ទ្រាធិរាជជាស្តេចនៃទេវតា ហើយស្តេចមានព្រះរាជឱង្ការទៅនឹងអាមាត្យទាំងឡាយថា **ភោន្តោ** ម្នាលអ្នកទាំងឡាយដ៏ចម្រើនអើយ បណ្តាធម៌ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងតែងតាំងទុកមកហើយ បើអ្នកណាបានចេះដឹងនូវព្រះធម៌នោះខ្វះ អ្នកនោះត្រូវសម្តែងព្រះ

ធម៌នោះមកឲ្យយើងបានស្ដាប់ផង ដ្បិតយើងមានសេចក្ដីប្រាថ្នាចង់ស្ដាប់ព្រះធម៌ទេសនាពន់ពេកណាស់។

ឯអាមាត្យទាំងអស់ក៏ក្រាបបង្គំទូលព្រមគ្នាថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គទាំងឡាយពុំបានដឹង ពុំបានចេះចាំដល់ព្រះធម៌នោះដល់តិចតួចឡើយ សូមព្រះអង្គទ្រង់ជ្រាប។

ព្រះបរមពោធិសត្វ កាលបើទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ មានសេចក្ដីទោមនស្សតូចព្រះហឫទ័យហើយ ទ្រង់ពិចារណាថា បើដូច្នេះ គួរតែអញឲ្យតម្កល់នូវប្រាក់មួយពាន់កហាបណៈ លើ-កនៃដំរីឲ្យបុរសវាយស្គរត្រាច់ទៅក្នុងនគរទាំងអស់ គង់មានបុគ្គលណាមួយលោភចង់បានទ្រព្យរបស់អញ សម្ដែងធម៌ទេសនាដោយបទព្រះគាថាប្រកបដោយបាទបួនដល់អញ ពុំលែងឡើយ កិច្ចដែលអញបានស្ដាប់ព្រះធម៌នោះនឹងមានសេចក្ដីសុខ សេចក្ដីចម្រើនអស់កាលជាយូរអង្វែងទៅអនាគតដោយពិត។

លុះព្រះពោធិសត្វទ្រង់គិតដូច្នេះហើយ ក៏ឲ្យសេវ-

កាមាត្យទាំងឡាយធ្វើដូចព្រះតម្រិះនោះ លុះបានធ្វើទៅ ហើយ ក៏ពុំមានបុគ្គលណាមួយអាចនឹងសម្ដែងធម៌បាន ឡើយ ទើបព្រះអង្គត្រាស់បង្គាប់ឲ្យបង្កើនកហាបណៈច្រើន ឡើងជាលំដាប់តាំងពី ពីរពាន់ បីពាន់ បួនពាន់ឡើងទៅ ដរាបដល់មួយកោដិជាកំណត់ថា អ្នកណាអាចសម្ដែងធម៌ ទេសនាតែមួយព្រះគាថា ដែលមានបាទបួន ឲ្យយើងស្ដាប់ យើងនឹងឲ្យប្រាក់មួយកោដិ សូម្បីទ្រង់ផ្សាយដូច្នេះក្ដី ក៏គង់ ពុំមានបុគ្គលណាមួយអាចសម្ដែងធម៌ទេសនាថ្វាយព្រះអង្គ បានឡើយ លំដាប់ជាខាងក្រោយមក ព្រះអង្គចាត់សេវកា- មាត្យឲ្យវាយស្គរត្រាច់ទៅក្នុងនគរទាំងអស់ទៀតថា បើអ្នក ណាអាចសម្ដែងធម៌ទេសនាឲ្យយើងស្ដាប់ យើងនឹងឲ្យធ្វើ ជាធំក្នុងស្រុកនិគមនិងជនបទ ពុំនោះសោតយើងនឹងឲ្យធ្វើ ជាសេដ្ឋី ជាសេនាបតីឬជាឧបរាជ មួយទៀតយើងឲ្យស្វេត- ច្ឆត្ររាជសម្បត្តិទាំងមូល ឯចំណែកយើងនឹងលះបង់ភាព ជាស្ដេចហើយធ្វើខ្លួនឲ្យជាខ្ញុំបម្រើអ្នកនោះហោង។ ទោះបី ព្រះអង្គត្រាស់បង្គាប់ដូច្នេះក្ដី ក៏ពុំមានជួបប្រទះបុគ្គលណា មួយចេះចាំធម៌អាចនឹងសម្ដែងថ្វាយព្រះអង្គបានឡើយ។

បពិត្រសប្បុរសទាំងឡាយ យើងគួរតែមានសម្បជញ្ញៈភ្ញាក់ខ្លួនថា ការដែលបានជួបប្រទះនឹងធម៌ទេសនាម្តង ៗ នេះ ជាការក្រពន់ពេកណាស់ បើបានប្រទះបានស្តាប់ធម៌ទេសនាហើយ ឈ្មោះថាជាបុគ្គលមានភ័ព្វមានវាសនាធំបំផុតនឹងរកអ្វីប្រៀបផ្ទឹមគ្មានឡើយ។

ចំណែកឯព្រះបរមពោធិសត្វ កាលបើព្រះអង្គរកបុគ្គលអ្នកសម្តែងធម៌ទេសនាពុំបានហើយ ក៏ដល់នូវសង្វេគស្លុតស្លប់ក្នុងព្រះរាជហឫទ័យថា អញប្រាសចាកធម៌ទេសនាហើយ ប្រយោជន៍អ្វីនឹងសោយរាជសម្បត្តិតទៅទៀត លុះទ្រង់ព្រះចិន្តាដូច្នេះហើយ ក៏លះបង់រាជសម្បត្តិប្រគល់ដល់អាមាត្យទាំងឡាយ ស្រេចហើយព្រះអង្គចេញចាកព្រះនគរទៅក្នុងកាលនោះឯង។ ព្រះបាទធម្មសោណ្ឌកមហារាជ កាលដែលព្រះអង្គចេញស្វែងរកព្រះសទ្ធម្ម តាមលំដាប់ស្រុក និគម ជនបទ រាជធានី ហូរហែទៅ ក៏បានទៅដល់ព្រៃហិមពាន្ត។

ព្រោះហេតុនោះ ព្រះអរហន្តទាំងឡាយបាននាំរឿងនិទាននេះយកមកស្តែងទុកក្នុងគម្ពីរមធុរសវាហិណីនេះ

*លោកពោលជាបទព្រះគាថាថា*

១១. បុរេ ភេរឹ ចរាបេត្វា,
ធម្មសោណ្ឌោ នរាធិបោ;
សទ្ធម្មជ្ឈេសកំ សត្ថុ,
អលទ្ធា ធនកោដិហិ។

១២. ទាសោ ហោមិ បហាយាហំ,
រាជត្តំ ទេសកស្ស មេ;
ឥច្ចាហ សោ មហីចាលោ,
អហោ ធម្មេសុ លោលតា.

១៣. វជ្ជំ នីយ្យាតយិត្វាន, អមច្ចានំ មនោរមំ,
វជំ ចារិសិ សោ រាជា, តវេសំ ធម្មមុត្តមន្តិ។

*ព្រះបាទធម្មសោណ្ឌកពោធិសត្វ ជាទីពឹងនៃជនទាំងឡាយ ព្រះអង្គចាត់សេវកាមាត្យឲ្យវាយស្គរត្រាច់ទៅក្នុងនគរស្វែងរកអ្នកប្រាជ្ញចេះសម្ដែងធម៌ទេសនា ទ្រង់នឹងព្រះរាជទានរង្វាន់តាំងពីពីរពាន់កហាបណៈដរាបដល់មួយកោដិ ក៏ពុំមានបុគ្គលណាមួយអាចហ៊ានទទួលយកឡើយ ហើយស្ដេចឲ្យតម្លើងថ្លៃតាំងពីឲ្យធ្វើជាធំក្នុងស្រុកជនបទដរាបដល់ឲ្យសោយរាជសម្បត្តិជាស្ដេច ព្រះអង្គនឹងធ្វើជាខ្ញុំបម្រើវិញ ក៏ពុំមានបុគ្គលណាមួយ អាចទទួលសម្ដែងធម៌*

ទេសនាថ្វាយព្រះអង្គបានឡើយ។

ព្រះបរមក្សត្រិយ៍នោះ កាលបើព្រះអង្គរកបុគ្គលអ្នកសម្ដែងធម៌ពុំបានហើយ ក៏ទ្រង់លះបង់រាជសម្បត្តិក្រោមស្វេតច្ឆត្រជាទីតម្រេកប្រគល់ឲ្យអាមាត្យទាំងឡាយពុំមានព្រះហឫទ័យអាល័យឡើយ ហើយស្ដេចចេញទៅកាន់ព្រៃហិមពាន្ត ក្នុងកាលនោះហោង។

ដោយតេជះបុណ្យព្រះមហាសត្វទីអាសនៈសម្ដេចអម្រិន្ទ្រាធិរាជ ក៏បណ្ដាលឡើងឲ្យក្ដៅក្រហាយគួរជាទីអស្ចារ្យ ព្រះឥន្ទ្រស្ដេចគង់ពុំបានកើតរំខានក្នុងព្រះទ័យ ក្នុងខណៈដែលព្រះអង្គចូលទៅដល់ព្រៃមហាវ៉ននោះឯង។

គ្រានោះ សក្កទេវរាជទ្រង់ព្រះចិន្ដាថា បណ្ឌុកម្ពលសិលាសនៈរបស់អញកើតជាក្ដៅក្រហាយ[១] នឹងអង្គុយពុំ

---

(១)-បណ្ឌុកម្ពលសិលាសនៈមានសភាពក្ដៅដោយហេតុ៤យ៉ាង

១-សក្កស្ស អាយុក្ខយេន វា ឧណ្ហំ ហោតិ បណ្ឌុកម្ពលសិលាសនៈមានសភាពក្ដៅ ដោយការអស់អាយុរបស់សក្កទេវរាជ។

២-បុញ្ញក្ខយេន វា, ដោយការអស់បុណ្យរបស់សក្កទេវរាជ។

៣-អញ្ញស្មឹ វា មហានុភាវសត្តេ តំ ឋានំ បត្ថេន្តេ, កាលមានសត្វដទៃដែលមានអានុភាពធំប្រាថ្នាបណ្ឌុកម្ពលសិលាសនៈនោះ។

បាន តើព្រោះហេតុអ្វីហ្ន៎? ព្រះអង្គទ្រង់រំពឹងគិតដូច្នេះ ហើយ ក៏បើកទ្វារចក្ខុប្រមើលមើលមនុស្សលោក ហើយ ពិនិត្យមើលជម្ពូទ្វីបទាំងអស់ បានឃើញព្រះបាទធម្ម-សោណ្ឌកមហារាជ ស្ដេចស្វែងរកបុគ្គលអ្នកចេះសម្ដែងធម៌ទេសនាពុំបាន ហើយទ្រង់លះបង់រាជសម្បត្តិឥតអាល័យ ស្ដេចចូលមកកាន់ព្រៃហិមពាន្ត។

លុះព្រះឥន្ទ្រាធិរាជទ្រង់បានឃើញដូច្នេះហើយ ក៏គិតពិចារណាតទៅទៀតថា ព្រះបាទធម្មសោណ្ឌកមហា-រាជអង្គណាដែលទ្រង់លះបង់រាជសម្បត្តិ ព្រមទាំងព្រះញាតិវង្សទាំងជីវិតនៃខ្លួនដើម្បីស្វែងរកស្ដាប់ព្រះសទ្ធម្មក្នុងគ្រានេះ ព្រះបាទធម្មសោណ្ឌកមហារាជអង្គនោះមិនមែនជាសាមញ្ញសត្វដទៃផ្ដេសផ្ដាសទេ គឺជាអង្គពោធិសត្វនឹងបានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធមួយព្រះអង្គក្នុងភទ្ទកប្បនេះដោយពិត ព្រះអង្គមានព្រះហឫទ័យចង់ស្ដាប់ធម៌

---

៤-ឥទ្ធិកានំ វា មហិទ្ធិកសមណព្រាហ្មណានំ សីលតេជេន ដោយសីលតេជះរបស់សមណព្រាហ្មណ៍អ្នកមានឫទ្ធិដែលប្រកបដោយធម៌។

*(ចាក ជាតក-អដ្ឋកថា ទសកនិបាត កណ្ហជាតក)*

ទេសនា ប៉ុន្តែស្វែងរកអ្នកប្រាជ្ញបេះសម្តែងធម៌ពុំបាន ហើយទ្រង់ចូលមកកាន់ព្រៃធំនេះ បើទ្រង់ពុំបានស្តាប់ធម៌ ហើយ ក៏នឹងដល់នូវសេចក្តីទុក្ខធំដោយពិត បើអញមិនទៅសង្គ្រោះផងទេ យល់ឃើញជាពុំសមហេតុផលឡើយ, គួរតែអញទៅក្នុងទីនោះនៅថ្ងៃនេះ ដើម្បីស្រោចស្រង់ព្រះពោធិសត្វនោះ ដោយទឹកអម្រឹតរសគឺព្រះធម៌ ហើយនាំយកទៅតម្កល់ទុកក្នុងរាជសម្បត្តិដដែលវិញទើបគួរ។

សម្តេចព្រះសហស្សនេត្រទ្រង់គិតយ៉ាងនេះហើយ ក៏ហោះចុះមកពីស្ថានតាវត្តិង្សទេវលោកនាយមកកាន់ស្ថានមនុស្សលោក ទ្រង់លះបង់អត្តភាពប្រក្រតីហើយ កាន់យកភេទជាយក្សអារក្សទឹកយ៉ាងធំ គួរខ្លាចស្ញប់ស្ញែងពន់ពេកដើរចូលមក មានមុខឆ្ពោះទៅកាន់សំណាក់ព្រះមហាសត្វ ហើយសម្តែងខ្លួនឲ្យប្រាកដស្ថិតនៅក្នុងទីពុំឆ្ងាយពីព្រះបរមពោធិសត្វនោះឡើយ។

ព្រោះហេតុនេះ បានជាព្រះអរហន្តទាំងឡាយលោកសម្តែងជាបទព្រះគាថាដូច្នេះថា

១៤. ព្យគ្ឃច្ឆសីហមហិសោ រតហត្ថិទីបិ,
មិគាកុលំ កណ្ដកសេលរុក្ខំ;

នរានមិន្ទោ បរិសិត្វកាននំ,
ឥតោចិតោ វិក្កមិ ជម្មកាមោ។
១៥. តស្សានុភាវេន បុរិន្ទទស្ស,
សិលាសនំ ឧណ្ហមហោសិ កាមំ;
តេនេវ សោ លោកមុនិក្ខមានោ,
អន្វក្ខិ ជីរំ វិបិនេ ចរន្តំ។
១៦. មយដ្ឋ តំ ធម្មរសេន សម្មា,
សន្តប្បយិត្វា តមនំ វរន្តិ;
មន្ទា សុភីមញ្ជនក្ខជវណ្ណំ,
មហាមុខំ និក្កត ភីមធាបំ។
១៧. និត្តក្កិសង្កាស វិសាលនេត្តំ,
មង្គេន ភក្កំ ចិបិដក្កនាសំ;
ខរតម្ពនាបឹ ឃនមស្សុវន្តំ,
នីលោទរំ កដ្ឋិតភីមឃោសំ។
១៨. កាភេរុហំ តិក្ខសលោហិតាយតំ,
វិសាលជោតាយតខក្កហត្តំ;
តនាយុជេនដ្ឋីតមញ្ញពាហុំ,
នដ្ឋោដ្ឋភីមំ សវលីលលាជំ។
១៩. មនុស្សមំសាននរត្តថានំ,
ភយានកាំ កក្ខលយក្ខវណ្ណំ;
សុមាបយិត្វាន វនន្តរស្មិំ,
នស្សេសិ អត្តំ ស នរាធិបស្សាតិ។

*ព្រះនរិន្ទ្រាធិបតីធម្មសោណ្ណក ព្រះអង្គមានសេចក្តី*

អផ្សុក មានប្រាថ្នាចង់ស្ដាប់ធម៌ ហើយស្ដេចចេញទៅអំពីនគរពារាណសី ត្រាច់ចូលទៅក្នុងព្រៃសាលព្រឹក្ស ប្រកបដោយញាតស្បាតដ៏ជិតសុទ្ធតែបន្ទាដ៏ប្រទ្បៀកវរដោយសត្វសាហាវ មានខ្លាធំ ខ្លាឃ្មុំ សត្វសីហៈ និងក្របីព្រៃ គោព្រៃ, ដំរី ខ្លាដំបងជាដើម, នៅអាស្រ័យក្នុងព្រៃនោះឯង ដោយតេជះអានុភាពបុណ្យបារមីព្រះពោធិសត្វនោះ អាសនៈថ្មកែវដ៏មានពណ៌ល្អដូចសំពត់កម្ពលក្រហមលឿងរបស់ព្រះឥន្ទ្រាធិរាជ ក៏បង្កើតក្ដៅក្រហល់ក្រហាយនឹងគង់ពុំបាន នារំខានក្នុងព្រះទ័យ ទើបបើកទិព្វចក្ខុរមិលមើលស្ថានមនុស្សលោក លុះបានជ្រាបហេតុនោះសព្វគ្រប់ហើយ ក៏ហោះចុះមកពីស្ថានទេវលោកនាយ មកកាន់ស្ថានមនុស្ស ហើយក៏និម្មិតអាត្មាជាយក្សកាចរបឹងរឹងរូសគួរខ្លាចពន់ពេក មានសម្បុរខៀវស្រងាត់ដូចជាកំពូលភ្នំអញ្ជ័ន មានមាត់ធំ មានចង្កូមគួរខ្លាច លៀនចេញមកខាងក្រៅ មានភ្នែកទាំងពីរធំក្រហមប្រាលដូចជាគំនរសំរាមដែលភ្លើងឆេះ ហើយមានទ្រូងខ្ពស់កណ្ដាល មានចុងច្រមុះក្រហម មានសក់ និងពុកមាត់ជាតម្រឹម មានពណ៌ក្រហមដូចអណ្ដាតភ្លើង មាន

ផ្ទៃពោះពណ៌ខៀវ មានសំឡេងឮសន្ធឹកដូចផ្គរលាន់គួរស្បើម មានក្រចករឹងប្រឡាក់ដោយឈាមជាប់ជានិច្ច មានបាតដៃធំពុំដែលលាងទឹកម្ដង មានដំបង និងគ្រឿងអាវុធក្នុងដៃជាប់មិនដាច់ មានចង្កូម និងធ្មេញបបូរមាត់គួរស្បើម មានថ្ងាសប្រកបដោយសរសៃជ្រួញ ៗ ដូចជាវល្លិ មានតែសាច់មនុស្សជាអាហារបរិភោគប្រក្រតី មានជើងទាំងពីរក្រហមដូចរងើកភ្លើង សម្ដែងខ្លួនឈរនៅក្នុងចន្លោះភ្នំ ឲ្យប្រាកដដល់ព្រះនរាធិបតីធម្មសោណ្ឌកមហារាជនោះឯង។

គ្រានោះ ព្រះមហាសត្វបានឃើញឥន្ទយក្សស្ថិតនៅក្នុងទីជិតនៃខ្លួនដូច្នោះហើយ ក៏ពុំបានខ្លាចញាប់ញ័រ តក់ស្លុតចិត្ត និងព្រឺព្រួចរោមឡើយ ព្រោះព្រះអង្គបានរំពឹងគិតថា យក្សដែលមានសភាពយ៉ាងនេះ មុខជាចេះសម្ដែងធម៌ទេសនាដោយពិត, បើដូច្នោះ ត្រូវតែអញចូលទៅជិតក្នុងសំណាក់អារក្សទឹកនោះហើយនឹងស្ដាប់ធម៌ទេសនា ដ្បិតកិរិយាដែលបានស្ដាប់ធម៌ទេសនានោះជាទីនាំមកនូវសេចក្ដីសុខនិងប្រយោជន៍ដល់អញអស់កាលជាយូរអង្វែងទៅឯអនាគតពុំលែងឡើយ លុះព្រះបរមពោធិសត្វទ្រង់គិត

ដូច្នេះហើយ ក៏ទ្រង់រំពឹងតទៅទៀតថា ថ្ងៃនេះត្រូវតែអញ ចូលទៅជិតយក្សនោះហើយសួរយក្សទើបគួរ ទើបព្រះអង្គយាងចូលទៅជិតនិយាយសន្ទនាជាមួយនឹងយក្សនោះ ពោលជាបទព្រះគាថាដូច្នេះថា

២០. អស្មិ វនស្មិំ តរុសណ្ឌមណ្ឌិតេ;
សុផុល្លិតានេកលតាកុលាកុលេ;
អជិត្តហីតោ សិ មហានុភាវ,
បុច្ឆាមិ តំ នេវ វនេហិ កាដ្ឋំ។

២១. ជម្ពុ កវេសំ វនមាគតោម្ហិ,
បហាយ រដ្ឋំ អបិ ញាតិសង្ឃំ;
ជានាសិចេ សម្ម វនេហិ មយ្ហំ,
ឯកម្បិ គាថំ សុគតេន ទេសិតំ។

បពិត្រមហាយក្ស ! ដ៏មានខ្លួនប្រដាប់ដោយទ្រង់ទ្រាយពេញជំទង់ តួអ្នកមានអានុភាពច្រើន សឹងប្រដាប់ដោយគ្រឿងអាភរណៈផ្សេង ៗ ស្ថិតនៅក្នុងព្រៃនេះ អ្នកជាបុគ្គលមានចិត្តពុំបានតក់ស្លុតខ្លាចអ្វីឡើយ ចំណែកខាងយើងបានលះបង់រាជសម្បត្តិ និងពួកញាតិទាំងឡាយដើរស្វែងរកបុគ្គលអ្នកសម្តែងធម៌ទេសនា បានចូលមកកាន់ព្រៃនេះ បើយើងសួរនូវសេចក្តីសង្ស័យឯណាចំពោះអ្នក

*សូមអ្នកសម្ដែងប្រាប់សេចក្ដីសង្ស័យនោះដល់យើង បពិត្រយក្ស! ថា បើអ្នកបានចេះព្រះធម៌ សូមអ្នកសម្ដែងធម៌ក្នុងបទព្រះគាថាមួយដែល ព្រះសុគតបានសម្ដែងហើយ ដល់យើងឥឡូវនេះផង។*

*លំដាប់នោះ ឥន្ទយក្សតបវិញថា*

២២. ធម្មំ បជានាមហាមេកទេសំ,
ជិនេរិតំ សាធុតរំ រសានំ,
ទេសេមិ ចេហំ តវ ធម្ម មគ្គំ,
តុវញ្ហិ កិំ កាហសិ ទេសកស្សាតិ។

*បពិត្រមហារាជ! យើងបានចេះព្រះធម៌ដែលព្រះជិនស្រីទ្រង់សម្ដែងទុកមកដោយចំណែកមួយ ជាធម៌ដ៏ប្រសើរវិសេសជាងរសទាំងពួងមែន តែបើយើងសម្ដែងធម៌នោះដល់ព្រះអង្គហើយ តើព្រះអង្គនឹងបូជាវត្ថុអ្វីដល់យើងជាអ្នកសម្ដែងធម៌វិញ។*

*គ្រានោះ ព្រះមហាសត្វតបថា*

២៣. រជ្ជេ បិតោ អស្សមហំ សចេ ភោ,
អនប្បរូបំ បកាហេមិ បូជំ;
ឥមានិ ឃកោ វេមជ្ឈបត្តោ,
កាហេមិ កិំ ទេហមិមំ បបេត្វា។

២៨. យទិច្ឆសិ ត្វំ មម មំសលោហិតំ,
កាមេហំ សព្ពំ ហ មជ្ជ តេន,
ន ចត្ថិ អញ្ញំ តវ អច្ចនីយំ,
ទេសេហិ ធម្មំ សុគត ប្បសត្ថំ។

*បពិត្រមហាយក្សដ៏ចម្រើន! បើយើងស្ថិតនៅក្នុងរាជសម្បត្តិទៅវិញ យើងនឹងបូជាដល់អ្នកឲ្យវិសេសច្រើនទៅបាន ឥឡូវយើងចូលមកក្នុងព្រៃនេះតែម្នាក់ឯង បើវៀរលែងតែរាងកាយរបស់យើងចេញហើយ យើងនឹងរកវត្ថុវិសេសបូជាដូចម្ដេចបាន ប្រសិនបើ អ្នកប្រាថ្នាចង់បរិភោគសាច់ឈាមរបស់យើង ៗ នឹងលះរាងកាយនេះបូជាព្រះធម៌ឲ្យអ្នកបរិភោគជាអាហារក្នុងថ្ងៃនេះឯង ដ្បិតស្បៀងអាហារដទៃរបស់អ្នកក៏ពុំមានដែរ អ្នកត្រូវសំដែងធម៌ទេសនាឲ្យយើងស្ដាប់ជាមុនសិនចុះ យើងនឹងលះរាងកាយនេះបូជាដល់អ្នក បរិភោគក្នុងកាលជាខាងក្រោយដោយពិត។*

*ឥន្ទយក្សបានស្ដាប់ហើយពោលតបថា*

២៩. កុត្វាន មំសំ សុហិតោវ សន្តោ,
ហន្ត្វា បិចាសំ រុធិរំ បិវិត្វា;
ធម្មំ កថេតុំ បភវាមិ តុយ្ហំ,
វត្តុំ ន សក្កោមិ ខុធាបរេតោតិ។

បពិត្រមហារាជ ! យើងមានសេចក្តីស្រេកឃ្លានពេកណាស់ ដរាបណាយើងបានបរិភោគសាច់ និងផឹកឈាមឲ្យឆ្អែតស្រួលខ្លួន បន្ទាបង់នូវសេចក្តីក្រវល់ក្រវាយក្នុងកាយជាមុនសិន ដរាបនោះទើបអាចនឹងសម្តែងធម៌ទេសនាឲ្យព្រះអង្គស្តាប់បាន ដ្បិតយើងអត់អាហារយូរថ្ងៃណាស់ហើយ សេចក្តីស្រេកឃ្លានតែងបៀតបៀនញាប់ញ័រសព្វសព៌ាង្គកាយ នឹងសម្តែងធម៌ទេសនាដូចម្តេចបាន។

លំដាប់នោះ ព្រះមហាសត្វបានស្តាប់ហើយក៏ពោលថា

២៦. កុត្វា តុវំ មំ បឋមញ្ហិ យក្ខ,
បច្ឆា តុ ទេសេស្សសិ កាស្ស ធម្មំ;
ធម្មស្ស មយ្ហំ តវ មំសលាភំ,
ត្វមេវ ជានាហិ យថា ភវេយ្យាតិ។

បពិត្រយក្ស ! ប្រសិនបើ អ្នកបរិភោគយើងមុនហើយ សឹមសម្តែងធម៌ទេសនាជាខាងក្រោយ តើនឹងសម្តែងធម៌ឲ្យអ្នកណាស្តាប់ បើយើងស្លាប់ទៅហើយចំណែកអ្នកមានលាភបាននូវសាច់បរិភោគ ព្រោះតែការបានសម្តែងធម៌ឲ្យយើងស្តាប់ប៉ុណ្ណោះឯង ដូច្នេះត្រូវអ្នក

ពិចារណាឲ្យបានដឹងដោយសមគួរតាមពិតចុះ។

លុះព្រះបរមពោធិសត្វទ្រង់ត្រាស់យ៉ាងនេះហើយ ឥន្ទយក្សក៏ទទួលតបវិញថា

បពិត្រមហារាជ ! ពាក្យនេះប្រពៃហើយ បើដូច្នោះ ត្រូវព្រះអង្គស្ដេចឡើងទៅលើភ្នំនេះហើយ ស្ថិតនៅលើកំពូលភ្នំទម្លាក់ព្រះកាយចុះមកសំដៅមាត់ខ្ញុំ កាលបើព្រះអង្គទម្លាក់ព្រះកាយចុះមកហើយ ខ្ញុំនឹងសម្ដែងធម៌ទេសនាឲ្យព្រះអង្គស្ដាប់បណ្ដើរកាលនោះឯង បើព្រឹត្តិការណ៍បែបនេះសមហេតុហើយលាកដ៏ប្រសើរ ដែលព្រះអង្គបានស្ដាប់ធម៌ទេសនាក្ដី លាកដែលខ្ញុំបានបរិភោគសាច់ឈាមក្ដី នឹងបានស្មើគ្នាតាមពិត កាលដែលខ្ញុំបរិភោគនូវសាច់ និងឈាមសោត ក៏នឹងមានប្រាកដដូច្នេះឯង។

ព្រះមហាសត្វទ្រង់បានស្ដាប់ពាក្យយក្សហើយ ទ្រង់ពិចារណាថា អាត្មាអញបានអន្ទោលទៅមកក្នុងវដ្ដសង្សារជាយូរអង្វែង ដែលរាប់នូវជាតិកំណើតត្រូវសត្វសាហាវទាំងឡាយ មានសីហៈ ខ្លាធំ ខ្លាឃ្មុំ ត្រី អណ្ដើក និងសត្វស្វាបជាដើម ខាំពាំយកទៅស៊ីជាចំណីអាហាររបស់វា ជាតិ

*កំណើតទាំងនោះនឹងរាប់ពុំបានឡើយ ថ្ងៃនេះ ត្រូវអាត្មាអញលះបង់ជីវិតខ្លួន ដើម្បីប្រយោជន៍បូជាព្រះធម៌ទេសនារបស់ព្រះសម្មាសម្ពុទ្ធទើបគួរ លុះព្រះបរមពោធិសត្វទ្រង់រំពឹងគិតដូច្នេះហើយ ក៏ទ្រង់ត្រាស់នឹងមហាយក្សថា*

២៧. សំសារវដ្ដេសុ វិវដ្ដមានា,
បប្បោន្តិ ទុក្ខំ ជនតា អនេកា;
ឯតញ្ហិ កោ អត្តនោ វា បរស្ស,
អត្ថាយ ជាហោសិ អហោសិ តុច្ឆំ។
២៨. ត្វមជិន្នហារី តិច ចារជារិកោ,
ចាណាតិចាតីសិ មុសា អភាសិ;
ត្វំ មជ្ជចាយីតិ អកាសិ ទោសំ,
បត្តុយ្ហ ទុក្ខំ ពហុសោ ជនន្តិ។
២៩. ឯតញ្ហិ កោ អត្តនោ វា បរស្ស,
អត្ថាយ ជាហោសិ អហោសិ តុច្ឆំ;
រុក្ខា បចាតា បបតិត្វា កោចិ,
ទុព្ពន្ធិយា ទុក្ខវិសាទនេន។
៣០. ព្យាធីហិ នានាខរវេទនាហិ,
មរន្តិ សត្តា ឧតុវេទនាហិ;
ឯតញ្ហិ កោ អត្តនោ វា បរស្ស,
អត្ថាយ ជាហោសិ អហោសិ តុច្ឆំ។

៣១. ព្យគ្ឃច្ឆមច្ឆោ រតកុច្ឆិយញ្ហិ,
មតស្ស មេ នត្ថិ បមាណសង្ខា;
ឯតញ្ហិ ភោ អត្តនោ វា បរស្ស,
អត្ថាយ នាហោសិ អហោសិ តុច្ឆំ។
៣២. ឯតជ្ជ មេ ទុច្ច ជ មត្តបានំ,
ន ហោតិ នេរិស្សរិយាធិកាយ;
សព្វញ្ញុការំ បន ចាបុណិត្វា,
សំសារតោ និត្ថរណាយ សត្តេ។
៣៣. តុំ សម្ម មយ្ហំ ពហុសោ បការី,
តស្មា តវេតំ វចនំ ករោមិ;
អសំកិតោ នេសយ មយ្ហធម្មំ,
សមិជ្ឈតេ ជានិ មនោរថោ តេតិ។

*បពិត្រមហាយក្សដ៏ចម្រើន ! ជនទាំងឡាយក្នុងសង្សារវដ្តដែលវិនាសអន្តរាយ ដល់នូវសេចក្តីទុក្ខវេទនាជាទម្ងន់ច្រើនពេកណាស់ សេចក្តីពិតថា បុគ្គលប្រព្រឹត្តសម្លាប់សត្វ លួចទ្រព្យគេ សេពប្រពន្ធកូនគេ ពោលពាក្យកុហកបញ្ឆោតឲ្យគេវិនាសចាកប្រយោជន៍ ផឹកទឹកស្រវឹង គឺសុរានិងមេរ័យនេះ ជាវេរាសូន្យទទេ បានតែសេចក្តីទុក្ខលំបាកមិនជាប្រយោជន៍ដល់ខ្លួន និងបុគ្គលដទៃឡើយ អំពើ*

បាណាតិបាតជាដើមនោះ គ្រាន់តែផ្តល់ឡើងនូវទោស ដោយពិត បពិត្រមហាយក្ស មួយទៀត អំពើដែលបុគ្គល វង្វេងទម្លាក់ខ្លួនចុះពីដើមឈើឲ្យស្លាប់ក្តី ចងកសម្លាប់ខ្លួន ឯងក្តី ផឹកថ្នាំពិសសម្លាប់ខ្លួនក្តី ឬស្លាប់ដោយព្យាធិជំងឺឈឺ ចាប់ដោយសេចក្តីទុក្ខវេទនាដ៏ក្តៅក្រហាយផ្សេង ៗ ដោយប្រែ ប្រួលរដូវពុំស្មើក្តី អំពើទាំងអស់នេះ មិនជាប្រយោជន៍ដល់ ខ្លួន និងបុគ្គលដទៃឡើយ បពិត្រមហាយក្ស! យើងដែល អន្ទោលទៅក្នុងសង្សារភព គ្រាន់តែស្លាប់ហើយ បានជា ចំណីនៃខ្លាធំ ខ្លាដំបង ត្រី ក្រពើ ឆ្មាម មករ នេះរាប់ពុំបាន ឡើយ ការស្លាប់ទាំងអស់នេះ សឹងសោះសូន្យទទេ ពុំបាន ជាប្រយោជន៍ដល់ខ្លួន និងបុគ្គលដទៃឡើយ ទើបតែថ្ងៃនេះ យើងបានស្តាប់ធម៌ទេសនា បានឲ្យទានជីវិតខ្លួន ដែលជា ទាន គឺបុគ្គលដទៃឲ្យបានដោយកម្រនេះ បានឈ្មោះថា ស្លាប់មានផលប្រយោជន៍យ៉ាងធំបំផុត មុខជាខ្ញុំនឹងបាន សម្រេចនូវសម្បត្តិសព្វញ្ញុតញ្ញាណ ដើម្បីនឹងញុំាងសត្វ- លោកទាំងឡាយ ឲ្យរលាស់ចេញចាកសង្សារទុក្ខដោយពិត បពិត្រយក្សជាសម្លាញ់ដ៏មានធុរៈស្មើ! អ្នកបានឈ្មោះថា

ជាបុគ្គលមានគុណឧបការៈច្រើនដល់យើង ព្រោះហេតុនោះខ្ញុំនឹងអាចធ្វើតាមពាក្យរបស់អ្នកឥឡូវនេះឯង សូមអ្នកកុំមានសេចក្តីរង្កៀសសង្ស័យឡើយ ត្រូវតែសម្តែងធម៌ទេសនាមកឲ្យយើង សេចក្តីប្រាថ្នារបស់យើង មុខជានឹងបានសម្រេចបរិបូណ៌ក្នុងកាលឥឡូវនេះឯង។

លុះព្រះមហាសត្វទ្រង់ទទួលប្តេជ្ញាយ៉ាងនេះស្រេចហើយ ក៏ស្តេចឡើងទៅលើកំពូលភ្នំហើយទ្រង់ត្រាស់ថា ថ្ងៃនេះអាត្មាអញបានឲ្យទានជីវិតផង ឲ្យទានសាច់ទាំងអស់ក្នុងសរីរៈ ព្រមទាំងរាជសម្បត្តិផង ដើម្បីបូជាធម៌ទេសនាដោយស្មោះចំពោះ រួចហើយព្រះអង្គក៏ដល់នូវសេចក្តីសោមនស្សជ្រះថ្លា បានពោលផ្ទួនទៀតនឹងមហាយក្សថា នៃយក្ស ! ត្រូវអ្នកសំដែងធម៌ទេសនាមកចុះ យើងប្រុងនឹងស្តាប់ហើយទម្លាក់ខ្លួនចុះឥឡូវនេះឯង។

ឥន្ទយក្សនោះស្ថិតនៅឰដ៏ខាងក្រោម បើកមាត់ហាឡើងដ៏មានចង្កូមធំពន្លឹកប្រុងនឹងសម្តែងធម៌ទេសនា។

ព្រះមហាសត្វក៏បែរព្រះភក្ត្រទៅត្រង់មហាយក្សនោះហើយលោតទម្លាក់ព្រះកាយចុះមកក្នុងវេលានោះដែរ។

កាលនោះ សក្កទេវរាជជាធំជាងពួកទេវតា ក៏មានព្រះហឫទ័យសោមនស្សជ្រះថ្លាដល់នូវសេចក្ដីស្ងើចគួរជាទីអស្ចារ្យពន់ពេក ទើបលះបង់នូវអត្តភាពជាយក្សហើយនិម្មិតអត្តភាពជាទិព្វវិញ សឹងមានគ្រឿងប្រដាប់សុទ្ធតែកែវដ៏រុងរឿងភ្លឺថ្លា បីដូចជាព្រះអាទិត្យពេញកម្លាំងរះឡើងកណ្ដាលអាកាស ហើយយកព្រះហស្តទាំងពីរចាប់ទ្រព្រះមហាសត្វដែលលោតចុះពីលើអាកាសវេហាយ៉ាងមាំ នាំហោះឡើងទៅកាន់ស្ថានតាវត្តិង្សសួគ៌ទេវលោកនាយ ទើបដាក់ព្រះអង្គឲ្យគង់លើថ្មបណ្ឌុកម្ពលសិលាសនៈដ៏ប្រសើរស្រេចហើយបូជាព្រះមហាសត្វដោយគ្រឿងសក្ការៈទាំងឡាយ មានគ្រឿងក្រអូប និងផ្កាកម្រងទិព្វជាដើម ហើយស្ដាប់ធម៌ទេសនាព្រះបរមពោធិសត្វដោយព្រះអង្គឯង ក៏ដល់នូវអាការដ៏ជ្រះថ្លាក្រៃពេក។

បន្ទាប់អំពីនោះសម្ដេចព្រះអម្រិន្ទ្រាធិរាជទ្រង់សំដែងព្រះធម៌ទេសនាមានអនិច្ចលក្ខណៈជាដើម តាមលម្អានដែលព្រះសម្ពុទ្ធទ្រង់ព្រះនាមកស្សបៈសម្ដែងទុកមកហើយថ្វាយព្រះបរមពោធិសត្វដោយបទព្រះគាថាដូច្នេះថា ៖

៣៤. អនិច្ចា វត សង្ខារា, ឧប្បាទវយធម្មិនោ;
ឧប្បជ្ជិត្វា និរុជ្ឈន្តិ, តេសំ វូបសមោ សុខោ។

ប្រែថា (យើងទាំងឡាយគួរមានសេចក្ដីសង្វេគថា) សង្ខារធម៌ទាំងឡាយជារបស់មិនទៀង តែងតែកើតឡើងហើយវិនាសទៅវិញជាធម្មតា គ្រាន់តែកើតឡើងហើយតែងរលត់សូន្យទៅវិញ ឥតមានវត្ថុអ្វីឃាត់បាន លុះតែរម្ងាប់នូវសង្ខារធម៌ទាំងឡាយនោះបាន ទើបនាំមកនូវសេចក្ដីសុខក្សេមក្សាន្ត។

សម្ដេចព្រះចមត្រៃត្រិង្សរភព ទ្រង់បានសម្ដែងធម៌ទេសនានេះចប់ហើយ ព្រះអង្គញុំាងសេចក្ដីប្រាថ្នានៃព្រះមហាសត្វឲ្យដល់នូវសេចក្ដីសម្រេចសមតាមចំណង់ ហើយទ្រង់សម្ដែងប្រាប់នូវសម្បត្តិដ៏មានសិរីសួស្ដីដ៏ប្រសើរក្នុងស្ថានទេវលោក រួចហើយក៏នាំព្រះបរមពោធិសត្វហោះចុះត្រឡប់មកកាន់ស្ថានមនុស្សលោកវិញ ថ្វាយព្រះមហាសត្វឲ្យស្ថិតនៅក្នុងរាជសម្បត្តិរបស់ព្រះអង្គដដែលវិញ ព្រមទាំងថ្វាយឱវាទ មិនឲ្យព្រះអង្គប្រមាទប្រហែសធ្វេសក្នុងការជាកុសលឡើយ លុះស្រេចកិច្ចហើយ ព្រះឥន្ទ្រាធិរាជក៏ហោះឡើងទៅកាន់ស្ថានទេវលោកនាយវិញហោង។

ព្រោះហេតុនោះ ព្រះអរហន្តទាំងឡាយដែលបាន
សម្តែងរឿងនិទានជាតកនេះលោកពោលថា

**៣៨. ឥតិ អមិតសិរិំ វា ជីវិតំ វាបិ សន្តោ,**
**ន សុមរិយ បសត្ថំ ធម្មមេវា ចរន្តិ;**
**តទុតរ វិភវាធំ អប្បមាយូធមគ្គោ,**
**ឥហ កុសលបមាទោ កោ នុ តុម្ហាធិសាធន្តិ។**

អ្នកប្រាជ្ញជាសប្បុរសពីបុរាណកាល លោកពុំមាន
ព្រះទ័យអាល័យទ្រព្យសម្បត្តិដ៏មានសិរី និងជីវិតរបស់
លោកឡើយ អាចលះបង់ហើយចេញទៅស្វែងរកព្រះធម៌
ដែលព្រះអរិយៈទាំងឡាយតែងសរសើរដោយពិត សត្វ
ទាំងឡាយក្នុងលោកនេះ ដែលមានទ្រព្យសម្បត្តិតិច មាន
អាយុខ្លី មានជំងឺឈឺចាប់ក៏ច្រើន ព្រោះតែខ្វនកាន់សេចក្តី
ប្រមាទក្នុងការជាកុសលពីជាតិមុនមកនោះឯង។

សម្តែងរឿងនិទាន ព្រះបាទធម្មសោណ្ឌកមហារាជ
ទី១ ក្នុងវគ្គជាបឋម ដែលមានក្នុងគម្ពីរមធុរសវាហិណីនេះ
ក៏ចប់ដោយសង្ខេបតែប៉ុណ្ណោះឯង។

*****

ចប់

# ឯកសារយោង

១. បបញ្ចសូទនី អដ្ឋកថា មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសក រាជវគ្គ មឃទេវសូត្រ
២. មន្ធាតុជាតក (របស់អាចារ្យ គី-គឹមស៊ីវ ប្រែនិងរៀបរៀង)
៣. មធុរសវាហិណីប្រែដោយសម្ដេចព្រះធម្មលិខិត ល្វី ឯម
៤. ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក បកិណ្ណកនិបាត អធិប្បាយបិដកលេខ ៦០ ទំព័រ ៤៤
៥. ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទុកនិបាត សិង្គាលវគ្គ អធិប្បាយបិដកលេខ ៥៨ ទំព័រ ១៣២
៦. បិដកលេខ ២៤ ទំព័រ ៣១១
៧. បិដកលេខ ៦២ ទំព័រ ៦៨
៨. បិដកលេខ ៧៧ ទំព័រ ២៤៨



"បពិត្រមហាយក្ស ! យើងដែលអន្ទោលទៅក្នុងសង្សារភព គ្រាន់តែស្លាប់ហើយ បានជាចំណីនៃខ្លាធំ ខ្លាដំបង ត្រី ក្រពើ ឆ្មាម មករ នេះរាប់ពុំបានឡើយ ការស្លាប់ទាំងអស់នេះ សឹងសោះសូន្យទទេ ពុំបានជាប្រយោជន៍ដល់ខ្លួន និងបុគ្គលដទៃឡើយ ទើបតែថ្ងៃនេះយើងបានស្តាប់ធម៌ទេសនា បានឲ្យទានជីវិតខ្លួន ដែលជាទាន គឺបុគ្គលដទៃឲ្យបានដោយកម្រនេះ បានឈ្មោះថា ស្លាប់មានផលប្រយោជន៍យ៉ាងធំបំផុត មុខជាខ្ញុំនឹងបានសម្រេចនូវសម្បត្តិសព្វញ្ញុតញ្ញាណ ដើម្បីនឹងញ៉ាំងសត្វលោកទាំងឡាយ ឲ្យរលាស់ចេញចាកសង្សារទុក្ខដោយពិតៗ"


PUC
Press